សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ភាគបម្រុង

ស្រាវជ្រាវពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៦ ដល់ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៦


ពាក់តែងឡើងដោយ
និស្សិតឈ្មោះ **ម៉ក់ ខ្មែត**
**មុត សារីរត្ន**

សាស្ត្រាចារ្យណែនាំ
លោកស្រី **ប៊ួយ ធីតា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ១៦

ឆ្នាំចូលសិក្សា ២០១២
ឆ្នាំសរសេរសារណា ២០១៦

# សេចក្តីថ្លែងអំណរគុណ


យើងខ្ញុំទាំងពីរនាក់ **ម៉ក់ ខ្មែត** និង **មុត សារីរត្ន** ជានិស្សិតបរិញ្ញាបត្រនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី១៦ (ថ្នាក់បង់ថ្លៃ) ឆ្នាំសិក្សា២០១២-២០១៦ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

**សូមលំឱនកាយគោរពប្រណិបតន៍ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះ ៖**

**លោកឪពុក និងអ្នកម្តាយ** ដែលលោកទាំងទ្វេរជាអ្នកមានគុណដ៏សែនមហាធំធេង ចំពោះរូបកូនដែលមិនអាចគណនាបាន ។ លោកទាំងទ្វេរបានផ្តល់កំណើតដល់រូបកូន ព្រមទាំងខិតខំចិញ្ចឹមបីបាច់ថែរក្សាតាំងពីកូន ចាប់កំណើតក្នុងឧទររហូតដល់កូនធំពេញវ័យក៏លោកនៅតែមានការព្រួយបារម្ភពីសុខភាពកូន ។ លោកបានអប់រំប្រៀនប្រដៅកូនឲ្យចេះដឹងសព្វបែបយ៉ាងទាំងសីលធម៌ សុជីវធម៌ ឲ្យក្លាយខ្លួនទៅជាមនុស្សល្អជាទីស្រឡាញ់នៃអ្នកដទៃ ។ លោកបានទំនុកបម្រុងកូន និងលើកទឹកចិត្តកូនឲ្យបានរៀនសូត្រតាំងពីថ្នាក់បឋមសិក្សារហូតដល់មហាវិទ្យាល័យ ។ លោកទាំងទ្វេ ពិតជាព្រះរស់សម្រាប់ជីវិតកូន ។

**ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការង លោកសាស្ត្រាចារ្យ និងបុគ្គលិកការិយាល័យស្រាវជ្រាវ ការិយាល័យសិក្សានិងបណ្ណារក្ស នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានខិតខំអស់ពីកម្លាំងកាយចិត្តក្នុងការដឹកនាំ គ្រប់គ្រង ជ្រោមជ្រែង និងបង្ហាត់បង្រៀនយើងខ្ញុំឲ្យទទួលបានចំណេះវិជ្ជាដើម្បីបានសរសេរសារណានេះឡើង ។

**ថ្នាក់ដឹកនាំ លោក លោកស្រីសាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាល័យសេដ្ឋកិច្ច** ដែលបានបង្រៀនដល់យើងខ្ញុំយ៉ាងយកចិត្តទុកដាក់ ប្រើអស់កម្លាំងកាយ ប្រាជ្ញា រាល់មុខវិជ្ជា ទើបអាចធ្វើឲ្យយើងខ្ញុំអាចទទួលបាននូវចំណេះដឹងដ៏ថ្លៃថ្លា ដើម្បីបោះជំហាន ទៅមុខទៀត ។

ជាពិសេស **លោកស្រីសាស្ត្រាចារ្យ ប៊ូយ ធីតា** ដែលបានចំណាយពេលវេលាដ៏មានតម្លៃ និងកម្លាំងប្រាជ្ញា ដើម្បីដឹកនាំសារណា ដោយធ្វើការកែតម្រូវនូវមាតិកា ខ្លឹមសារដែលមានការខ្វះចន្លោះ និងពន្យល់បន្ថែមលើសពីនេះទៅទៀតនោះ បានផ្តល់ជាគំនិត នៅក្នុងការសរសេរសារណាបញ្ចប់ការសិក្សារបស់នាងខ្ញុំ ។

ជាទីបញ្ចប់ យើងខ្ញុំសូមបួងសួងឲ្យទេវតា និងវត្ថុស័ក្តិសិទ្ធិក្នុងលោក ជួយថែរក្សាអ្នកមានគុណទាំងទ្វេរនិងថ្នាក់ដឹកនាំ លោក លោកស្រីសាស្ត្រាចារ្យ ឲ្យជួបប្រទះតែនឹងពុទ្ធពរទាំង ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ ព្រមទាំងសុភមង្គលគ្រប់ប្រការ ។

# អារម្ភកថា

ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី សាស្ត្រាចារ្យ ជាទីគោរព!

ប្រិយមិត្តអ្នកអាន អ្នកសិក្សាស្រាវជ្រាវ ពិសេសប្អូនៗ និស្សិត ជាទីស្រឡាញ់!

សារណាដែលកំពុងស្ថិតនៅក្នុងដៃនេះ គឺជាសមិទ្ធផលដែលបានកើតពីខិតខំ ប្រឹងប្រែងសិក្សា ស្រាវជ្រាវ ស្របតាមគោលការណ៍របស់សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចដែលបានអនុញ្ញាតឲ្យនិស្សិតពូកែ តាមថ្នាក់នីមួយៗ អាចជ្រើសរើសប្រធានបទណាមួយដើម្បីសរសេរជា សារណាសម្រាប់ការបញ្ចប់ការសិក្សា ថ្នាក់បរិញ្ញាបត្ររបស់ខ្លួន ។ ជាឱកាសដ៏ល្អរបស់យើងខ្ញុំជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ត្រូវបានសាកលវិទ្យាល័យលើកទឹកចិត្តឲ្យយើងខ្ញុំចងក្រងនូវស្នាដៃ នេះឡើងស្របតាមគោលការណ៍សាលា ។

តាមរយៈការសិក្សា ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ អស់រយៈពេល៤ ឆ្នាំ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចរួចមក ពួកខ្ញុំបានទទួលនូវចំណេះដឹង និងបទពិសោធន៍យ៉ាងច្រើន លើសពីនេះទៅទៀតនោះ ពួកខ្ញុំបានស្រាវជ្រាវទ្រឹស្តី ស្តីពីភាគបម្រុងដែលជាសកម្មភាពមួយតែងតែកើតមានក្នុងសង្គមយើងជាក់ស្តែង ។ ឆ្លងកាត់ការរៀននូវមុខវិជ្ជាជាច្រើនរួចមក គឺមុខវិជ្ជានីតិរដ្ឋប្បវេណីវាឆ្លុះបញ្ចាំងពីទិដ្ឋភាពនៃសកម្មភាពគ្រប់បែបយ៉ាងរវាងបុគ្គល និងបុគ្គល មិនថាតែការរស់នៅ ការប្រកបរបរ និងវិស័យផ្សេងៗ ទៀតមាននៅក្នុងមុខវិជ្ជានេះទាំងអស់ ។

ការជ្រើសរើសយកប្រធានបទនេះ ដោយមើលឃើញសារណាជាច្រើនដែលតាក់តែងឡើងដោយនិស្សិតជំនាន់មុន មានតិចតួចបំផុត នឹងមិនបកស្រាយស៊ីជម្រៅផងដែរនោះ ទើបយើងខ្ញុំជ្រើសប្រធានបទនេះ ។ វាហាក់បីដូចជាពិបាកមែនពិត ព្រោះវាមានលក្ខណៈស្មុគ្រស្មាញបន្តិច ប៉ុន្តែយើងទាំងពីរនឹងខិតខំប្រឹងប្រែងស្វែងរកប្រភពឯកសារតាមលទ្ធភាព ។

ជាមួយនឹងការចងក្រងស្នាដៃមួយនេះ យើងខ្ញុំសូមអភ័យទោសទុកជាមុន ពីសំណាក់ប្រិយមិត្តអ្នកអាន ពីព្រោះយើងខ្ញុំជឿជាក់ផងដែរថា សារណាមួយនេះ ពិតជាមានចំណុចខ្វះខាតកំហុសឆ្គងទាំងពាក្យពេចន៍ អក្ខរាវិរុទ្ធជាក់ជាពុំខាន ។

ជាចុងក្រោយ សូមគោរពជូនពរនិងសូមបួងសួងឲ្យទេវតា និងវត្ថុស័ក្តិសិទ្ធិក្នុងលោកជួយថែរក្សាអ្នកមាន គុណទាំងទ្វេរនិងថ្នាក់ដឹកនាំ លោក លោកស្រីសាស្ត្រាចារ្យ ឲ្យជួបប្រទះតែនឹងពុទ្ធពរទាំង ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ ព្រមទាំងសុភមង្គលគ្រប់ប្រការ។

# មាតិកា

ទំព័រ

**សេចក្តីផ្តើម**...............................................................................................................១

## ជំពូកទី ១
## សញ្ញាណទូទៅនៃការផ្ទេរទ្រព្យសម្បត្តិនៃញាតិ និង
## ចំណែកអប្បរមាដែលធានាដោយច្បាប់

**ផ្នែកទី១. សញ្ញាណទូទៅនៃការផ្ទេរទ្រព្យសម្បត្តិ**.................................................................៣
កថាខណ្ឌទី១ សន្តតិកម្មតាមច្បាប់..........................................................................................៤
កថាខណ្ឌទី២ សន្តតិកម្មតាមមតកសាសន៍...............................................................................៤
កថាខណ្ឌទី៣ ភាពដូចគ្នានិងខុសគ្នារវាងសន្តតិកម្មតាមច្បាប់និងមតកសាសន៍.............................៨
**ផ្នែកទី ២ ចំណែកទ្រព្យអប្បរមាដែលត្រូវធានាដោយច្បាប់**.........................................................៩
កថាខណ្ឌទី១ សញ្ញាណទូទៅ.....................................................................................................៩
ក.និយមន័យ...................................................................................................................១០
ខ.គោលបំណង.................................................................................................................១១
គ.ផលប្រយោជន៍.............................................................................................................១១
កថាខណ្ឌទី២ អ្នកមានសិទ្ធិលើភាគបម្រុង..............................................................................១២
ក.បច្ឆាញាតិផ្ទាល់............................................................................................................១៣
ខ.ឪពុកម្តាយឬជីដូនជីតា.....................................................................................................១៣
គ.សហព័ទ្ធ.....................................................................................................................១៤
កថាខណ្ឌទី៣ សន្តតិកម្មជំនួស................................................................................................១៥
កថាខណ្ឌទី៤ លក្ខខណ្ឌក្លាយជាអ្នកមានសិទ្ធិ និងចំណែកមតិក
របស់អ្នកមានសិទ្ធិនោះ.............................................................................................១៦
ក.លក្ខខណ្ឌក្លាយជាអ្នកមានសិទ្ធិលើភាគបម្រុង.......................................................................១៦
ក.១. បុគ្គលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាសន្តតិជន..........................................................១៧
ក.២. មានការបំពានលើចំណែកមតិក...........................................................................................១៧
ខ.ចំណែកនៃភាគបម្រុង...........................................................................................................១៧

## ជំពូកទី ២
## វិធីសាស្ត្រក្នុងការគណនាភាគបម្រុង


**ផ្នែកទី ១ ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនា**....................................................................២០
កថាខណ្ឌទី១ ទ្រព្យដែលមានពេលចាប់ផ្តើមសន្តតិកម្ម..................................................២០
កថាខណ្ឌទី២ តម្លៃនៃផលប្រយោជន៍ពិសេស...................................................... ...........២១
កថាខណ្ឌទី៣ តម្លៃនៃប្រទានកម្ម......................................................................... ........២១
កថាខណ្ឌទី៤ ចំនួនទឹកប្រាក់នៃកាតព្វកិច្ច.............................................................. .....២២
**ផ្នែកទី២ ការគណនា**.........................................................................................................២២
កថាខណ្ឌទី១ រូបមន្តក្នុងការគណនា...........................................................................២៣
កថាខណ្ឌទី២ ចំនួនទឹកប្រាក់ដែលត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង .......................២៦
ក.រូបមន្ត.............................................................................................. ...........២៦
ខ.មូលហេតុដែលនាំឲ្យមានការគណនា
រកចំនួនទឹកប្រាក់ដើម្បីបង្គ្រប់ភាគបម្រុង.......................................................២៦


## ជំពូកទី៣
## វិធីកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង
## និងការរលត់សិទ្ធិទាមទារដើម្បីឲ្យកាត់បន្ថយ


**ផ្នែកទី១ លំដាប់នៃកម្មវត្ថុដែលត្រូវធ្វើការកាត់បន្ថយ**..........................................................៣៣
កថាខណ្ឌទី១ កម្មវត្ថុការកាត់បន្ថយអច្ច័យទាន និងការកំណត់មតិកតាមមតកសាសន៍....៣៤
ក. អច្ច័យទានចំពោះសន្តតិជន.......................................................................៣៥
ខ. អច្ច័យទានចំពោះតតិយជន.......................................................................៣៥
គ. ការទទួលស្គាល់នូវការកំណត់ជាមុនតាមមតកសាសន៍ ................................៣៧
កថាខណ្ឌទី២. ផលប្រយោជន៍ពិសេស ឬ ប្រទានកម្ម...................................................៣៨
ក. លំដាប់នៃការកាត់បន្ថយផលប្រយោជន៍ពិសេស ឬ ប្រទានកម្ម......................៣៨
ខ. ការកាត់បន្ថយចំពោះកិច្ចសន្យា ដែលត្រូវចាត់ទុកជាប្រទានកម្ម ....................៣៨
គ. ការចាត់ចែងកម្មវត្ថុនៃប្រទានកម្ម ..................................................................៣៩

**ផ្នែកទី២ វិធីផ្តល់សំណង ចំពោះការបន្ថែមភាគបម្រុង៣៩**
កថាខណ្ឌទី១ ការសងមកវិញ......៤០
កថាខណ្ឌទី ២ បន្ទុកនៃការខាតបង់ដោយអសាធនភាព......៤១
កថាខណ្ឌទី ៣ សំណងដោយបង់ថ្លៃ ......៤២
**ផ្នែកទី៣ ការរំលត់សិទ្ធិក្នុងការទាមទារឲ្យកាត់បន្ថយភាគបម្រុង**......៤៣
កថាខណ្ឌទី ១ អាជ្ញាយុកាលនៃការរំលត់សិទ្ធិ......៤៣
កថាខណ្ឌទី ២ ការបោះបង់ភាគបម្រុង......៤៤
**សេចក្តីសន្និដ្ឋាន**......៤៦
**អនុសាសន៍**......៤៨
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

មនុស្សយើងដែលកើតមកតែងតែប្រកបរបររកទទួលទានដើម្បីចិញ្ចឹមជីវិត សម្រាប់ផ្គត់ផ្គង់ទ្រទ្រង់ជីវភាពគ្រួសារ ។ ក្នុងន័យនេះ ទើបរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ញត្តិទទួលស្គាល់នូវកម្មសិទ្ធិឯកជនក្នុងគោលបំណង ដើម្បីធានាដល់សិទ្ធិកាន់កាប់ទ្រព្យសម្បត្តិដែលបុគ្គលម្នាក់ខិតខំស្វែងរកដោយលំបាកនោះ ។ ពាក្យថាកម្មសិទ្ធិគឺអាស្រ័យទៅលើសិទ្ធិក្នុងការកាន់កាប់អាស្រ័យផល និងសិទ្ធិក្នុងការចាត់ចែងដោយកម្មសិទ្ធិករ មានន័យថា កម្មសិទ្ធិករមានសិទ្ធិយ៉ាងទូលំទូលាយលើទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់ខ្លួនទាំងក្នុងពេលបច្ចុប្បន្ន ទៅអនាគត និងព្រមទាំងពេលលទទួលមរណភាពផងដែរ ។ យើងដឹងហើយភាគបម្រុងជាប្រធានបទមួយដែលទទួលការចាប់អារម្មណ៍ជាខ្លាំងពីសំណាក់សង្គមកម្ពុជានាពេលបច្ចុប្បន្ននេះ ដោយសារកម្ពុជាពុំមានច្បាប់ណាចែងពីច្បាប់ណាមួយចែងអំពីភាគបម្រុងនោះទេ ម្យ៉ាងវិញទៀតបញ្ហាមួយចំនួនដែលទាក់ទងនឹងភាគបម្រុងពុំសូវបានជួបប្រទះ ដោយសារពុំមានសាលក្រម ឬសាលដីកាអំពីភាគបម្រុងច្រើននោះទេ នេះប្រហែលជាហេតុបណ្តាលមកពីប្រជាពលរដ្ឋមិនទាន់មានការយល់ដឹងទូលំទូលាយអំពីច្បាប់មតិក ។

បច្ចុប្បន្ននេះ ប្រទេសកម្ពុជាយើងបានប្រលូកចូលទៅលើឆាកអន្តរជាតិជាច្រើនដូចជា ជាសមាជិកអាស៊ាន ជាសមាជិកអង្គការ WTO (World Trade Organization) និងទំនាក់ទំនងជាមួយប្រទេសជាច្រើននៅលើពិភពលោក ក្នុងវិស័យពាណិជ្ជកម្មដូចជាវិស័យផ្សេងៗទៀត ជាច្រើន ដោយសារប្រទេសមានការរីកចម្រើន ដូចច្នេះហើយ ទើបនៅក្នុងបណ្តាគ្រួសារក៏រកស៊ីទទួលទានមាន បាននូវទ្រព្យសម្បត្តិច្រើនហើយមនោសញ្ចេតនាមិនអាចដូចគ្នា ស្មើគ្នា ជាមូលហេតុមានការផ្តល់មកនូវទ្រព្យសម្បត្តិទៅសន្តតិជនមិនស្មើគ្នា ដោយមូលហេតុច្បាប់អាចយល់ឃើញនូវសិទ្ធិរបស់ញាតិ ដើម្បីឲ្យមានតុល្យភាពនៃសិទ្ធិទើបបង្កើតជារបបភាគបម្រុងនេះឡើង ។

ដោយគុណបំណាច់របស់រាជរដ្ឋាភិបាលកម្ពុជា បានសហការជាមួយរាជរដ្ឋាភិបាលជប៉ុន បានតាក់តែងក្រមនេះឡើងដើម្បីគ្រប់គ្រងទំនាក់ទំនងនៅក្នុងសង្គមគ្រួសារខ្មែរ ។ ហើយដោយមានការជ្រោមជ្រែងនេះ ក្រមបានចូលជាធរមាន និងប្រកាសឲ្យប្រើផងដែរ នៅខ្លឹមសារជាច្រើន ប៉ុន្តែយើងខ្ញុំលើកយកតែចំណុចដែលពាក់ព័ន្ធ គឺស្តីពីភាគបម្រុង ប៉ុន្តែដោយខ្លឹមសារភាគបម្រុងវាមិនអាចកាត់ផ្តាច់ពីសន្តតិកម្មទើបយើងខ្ញុំលើកពីសន្តតិកម្មនេះផងដែរ ដែលចាប់ពីមាត្រា ១១៩៥ ដល់ ១២៤៧ ក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ នៃព្រះរាជាណាចក្រណាចក្រកម្ពុជា។

ការលើកយកប្រធានបទស្តីពី ភាគបម្រុងដែលស្ថិតនៅគន្ថីទី ៨ ជំពូកទី៤ នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ មកធ្វើការតាក់តែងជាសារណាបញ្ចប់ការសិក្សាគឺក្នុងគោលបំណង ដើម្បីសិក្សាស្វែងយល់ឲ្យកាន់តែច្បាស់អំពីផលប្រយោជន៍ និងខ្លឹមសារនៃភាគបម្រុង ហើយលើសពីនេះទៀតនោះ ដើម្បីយល់ដឹងពីអត្ថប្រយោជន៍របស់វាឲ្យស៊ីជម្រៅនោះ តើយើងត្រូវធ្វើការគណនា និងបង្គ្រប់ភាគបម្រុងជាពិសេសចំពោះអ្នកដែលមានសិទ្ធិនោះយ៉ាងណានោះ ? យើងខ្ញុំនឹងធ្វើការបកស្រាយជា ៣ ជំពូកធំៗ ។ ដោយក្នុងជំពូកទី ១ បកស្រាយអំពីសញ្ញាណទូទៅនៃការផ្ទេរទ្រព្យសម្បត្តិនៃញាតិ ជំពូកទី២ បកស្រាយពី សន្តតិកម្មតាមមតកសាសន៍ និងជំពូកទី៣ បកស្រាយពីសិទ្ធិរបស់សន្តតិជនលើមតកសាសន៍ ។

# ជំពូកទី ១
# សញ្ញាណទូទៅនៃការផ្ទេរទ្រព្យសម្បត្តិនៃញាតិ និង ចំណែកអប្បរមាដែលធានាដោយច្បាប់

## ផ្នែកទី១ .សញ្ញាណទូទៅនៃការផ្ទេរទ្រព្យសម្បត្តិ

សន្តតិកម្មគឺសម្តៅដល់ការនូវបេតិកភ័ណ្ឌ ឬ សិទ្ធិ និងករណីយកិច្ចរបស់មតកជនដែលបាន ទទួលមរណភាពឲ្យទៅបុគ្គលដែលនៅរស់ ដែលហៅថា សន្តតិជនម្នាក់ ឬច្រើនតាមឆន្ទៈ ឬតាមច្បាប់ ។ បើឲ្យនិយមន័យតាមសន្ទានុក្រមពាក្យច្បាប់ខ្មែរ អង់គ្លេស បារាំង រដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី បោះពុម្ពលើកទី១ ឆ្នាំ ២០០៧ សន្តតិកម្ម គឺការផ្ទេរនូវបេតិកភណ្ឌរបស់មតកជន ឲ្យទៅអ្នករស់ម្នាក់ ឬច្រើនាក់តាមឆន្ទៈ ឬតាមច្បាប់ ។ នៅក្នុងក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ បានបែងចែកសន្តតិកម្មជាពីរប្រភេទធំៗ រួមមាន សន្តតិកម្មដោយផ្អែកតាមឆន្ទៈរបស់មតកជន ហៅថា សន្តតិកម្មមានបណ្តាំ ឬមតកសាសន៍ និងសន្តតិកម្មដោយផ្អែកតាមបញ្ញត្តិនៃច្បាប់ ហៅថាសន្តតិកម្មតាមច្បាប់ ។

ជាគោលការណ៍រាល់សន្តតិកម្មមិនថាតែសន្តតិកម្មតាមច្បាប់ ឬសន្តតិកម្មតាមមតកសាសន៍នោះទេ គឺតែងតែចាប់ផ្តើមនូវពេលដែលមតកជនទទួលមរណភាព។ ប្រសិនបើមតកជនបានបន្សល់ទុកនូវលិខិតបណ្តាំ នោះវាមិនមានចោទជាបញ្ហានោះទេ តែប្រសិនបើមតកជនមិនបានបង្ហាញឆន្ទៈជាក់លាក់ណាមួយទេនោះ ច្បាប់នឹងដើរតួនាទីក្នុងការបែងចែកនូវទ្រព្យទាំងនោះដោយកំណត់អំពីនរណាជាសន្តតិជន ថាតើមានសន្តតិកម្មរបស់សហព័ទ្ធ ឬ យ៉ាងណា និងប្រសិនបើមានមានវត្តមាននៃផលប្រយោជន៍ពិសេស ប្រទានកម្ម អច្ច័យទាន ត្រូវមានការសម្រួលចំណែកមតិកជាអាទ៏។ ក្រមរដ្ឋប្បវេណីថ្មីឆ្នាំ២០០៧ ធ្វើការបែងចែកប្រព័ន្ធសន្តតិកម្មជាពីរប្រភេទ ដែលរួមមានសន្តតិកម្មតាមច្បាប់និងសន្តតិកម្មតាមមតកសាសន៍ ។

ខាងក្រោមនេះនឹងធ្វើការបកស្រាយអំពីសន្តតិកម្មតាមច្បាប់ (កថាខណ្ឌទី១) សន្តតិកម្មតាមមតកសាសន៍ (កថាខណ្ឌទី២) ។

## **កថាខណ្ឌទី១ សន្តតិកម្មតាមច្បាប់**

សន្តតិកម្មតាមច្បាប់គឺជាសន្តតិកម្មដែលផ្អែកតាមបញ្ញត្តិច្បាប់ ។ ចំពោះលំដាប់សន្តតិជនក្នុងការទទួលបាននូវចំណែកមតិក តាមសន្តតិកម្មតាមច្បាប់គឺមានតែបីលំដាប់តែប៉ុណ្ណោះ ដែលលំដាប់ទី១ គឺទទួលបានសិទ្ធិអាទិភាពទៅឲ្យកូនរបស់មតកជន ។ ចំពោះកូនដែលទទួលនូវសិទ្ធិអាទិភាពក្នុងការទទួលបាននូវសន្តតិកម្មនោះ ក៏បានរាប់បញ្ចូលទាំងកូនបង្កើតនិងកូនសុំផងដែរ។ ទោះបីជាការសុំកូនធម្មតាក្តី ការសុំកូនពេញលេញក្តីគឺសុទ្ធតែទទួលបានចំណែកមតិកស្មើៗគ្នា ។[1] ប្រសិនបើមតកជនពុំមានកូនតែមានចៅនោះ ដូច្នេះ ចៅនោះនឹងត្រូវក្លាយជាសន្តតិជនជំនួសកូនរបស់មតកជន ហើយជាអ្នកទទួលចំណែកមតិកនោះ ។ ប៉ុន្តែ ប្រសិនបើមិនមានសន្តតិជនជំនួសទេនោះ សន្តតិជនលំដាប់ទី២នឹងចូលខ្លួនមកដើម្បីទទួលនូវចំណែកមតិក ដែលសន្តតិជនលំដាប់ទី២នេះ គឺជាបុព្វញាតិផ្ទាល់របស់មតកជន ។ ប្រសិនបើ មតកជនពុំមានទាំងបច្ឆាញាតិផ្ទាល់ និងបុព្វញាតិផ្ទាល់ក្នុងការទទួលសន្តតិកម្មទេនោះ សន្តតិជនលំដាប់ទី៣ គឺបងប្អូនបង្កើតរបស់មតកជននោះនឹងត្រូវក្លាយជាសន្តតិជន ។ បើបងប្អូនបង្កើតមានចំនួនច្រើននាក់ បងប្អូនបង្កើតម្នាក់ៗ ត្រូវបានចំណែកស្មើៗគ្នា ចំណែកឯសហព័ទ្ធរបស់មតកជនវិញ ត្រូវក្លាយជាសន្តតិជនជានិច្ច មានន័យថា នៅក្នុងករណីដែលសហព័ទ្ធរបស់មតកជនត្រូវក្លាយជាសន្តតិជន បើមានបុគ្គលផ្សេងទៀតក្នុងលំដាប់ណាមួយនោះ សហព័ទ្ធត្រូវទទួលសន្តតិកម្មក្នុងលំដាប់ដូចគ្នានឹងសន្តតិជននោះដែរ ។

## **កថាខណ្ឌទី២ សន្តតិកម្មតាមមតកសាសន៍**

មតកសាសន៍ គឺជាលិខិតបណ្តាំ ដែលបុគ្គលម្នាក់បានធ្វើឡើងតាមទម្រង់ ដែលកំណត់ដោយច្បាប់ ដើម្បីសម្តែងឆន្ទៈចុងក្រោយ អំពីការចាត់ចែងទ្រព្យសម្បត្តិរបស់ខ្លួនជាអាទិ៍ បន្ទាប់ពីមរណភាព ។[2] ចំពោះទម្រង់នៃលិខិតមតកសាសន៍គឺមានច្រើនប្រភេទ ប៉ុន្តែយើងមិនលើកយកមកសិក្សាឲ្យស៊ីជម្រៅនោះទេ គឺយើងសិក្សាលើតែនិយមន័យនិងសញ្ញាណខ្លះៗ នៃទម្រង់ទាំងនោះ តែប៉ុណ្ណោះ ។ ការសិក្សាលើទម្រង់ផ្សេងៗនៃលិខិតមតកសាសន៍នឹងធ្វើការបង្ហាញដូចខាងក្រោម ៖

[1] .ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា១១៥៦។

[2] .ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,សទ្ទានុក្រមផ្នែករដ្ឋប្បវេណី,១៧ ។

➢ **លក្ខណៈដាច់ខាតនៃទម្រង់មតកសាសន៍**

នៅក្នុងសង្គមកម្ពុជាតែងតែមានការអនុវត្តនៅទម្លាប់មួយគឺនៅពេលដែលឪពុក ឬម្តាយរៀបនឹងស្លាប់តែងតែហៅកូនៗ មកជុំគ្នា ដើម្បីផ្តែផ្តាំដោយផ្ទាល់មាត់អំពីការចាត់ចែងទ្រព្យសម្បត្តិរបស់គាត់ក្រោយពេលមរណភាព។ តើបណ្តាំដែលធ្វើឡើងបែបនេះមានសុពលភាពដែរឬទេ ?

មតកសាសន៍ពុំអាចមានអានុភាពឡើយ បើពុំបានផ្អែកតាមទម្រង់ដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី។ មានន័យថាមតកសាសន៍ណាដែលបានធ្វើក្រៅពីទម្រង់ដែលមានចែងក្នុងច្បាប់ត្រូវចាត់ទុកថាមោឃៈ។ ដូចនេះការធ្វើការធ្វើបណ្តាំដោយផ្ទាល់មាត់ជាដើម នឹងមិនបង្កើននូវអានុភាពឡើយ។ ហើយជនដែលមិនអាចក្លាយជាសាក្សី ឬជាអ្នកសង្កេតការ ក្នុងពេលធ្វើមតកសាសន៍បានរួមមានអនីតិជន ឬ ជននៅក្រោមអាណាព្យាបាលទូទៅ ជនដែលបានសន្មតថាជាសន្តតិជន អច្ច័យលាភី ហើយនឹងសហព័ទ្ធ និងញាតិលោហិតខ្សែផ្ទាល់របស់ជនទាំងនោះ សហព័ទ្ធ ញាតិលោហិតផ្ទាល់ និងនិយោជករបស់សាការី ក្រឡាបញ្ជី ប្រសិនបើសាការីជាអ្នកពាក់ព័ន្ធនឹងធ្វើមតកសាសន៍។

➢ **ទម្រង់ទូទៅ**

ជាទូទៅទម្រង់នៃមតកសាសន៍ត្រូវបានចែកចេញជាបីប្រភេទរួមមានៈ

- មតកសាសន៍ជាលិខិតយថាភូតៈ មតកសាសន៍ដែលធ្វើឡើងដោយលិខិតយថាភូត ត្រូវធ្វើឡើងដោយម្ចាស់បណ្តាំនៅចំពោះមុខសាការីតាមទម្រង់ដូចខាងក្រោម[3]៖
  - ត្រូវមានវត្តមានរបស់សាក្សីយ៉ាងតិច២នាក់
  - ម្ចាស់បណ្តាំត្រូវប្រាប់ដោយផ្ទាល់មាត់នូវខ្លឹមសារនៃមតកសាសន៍ទៅសាការី
  - សាការីត្រូវសរសេរនូវអត្ថន័យនៃមតកសាសន៍របស់ម្ចាស់បណ្តាំនោះ ជាលាយលក្សណ៍អក្សរ ហើយត្រូវសូត្រឲ្យម្ចាស់បណ្តាំនឹងសាក្សីនោះស្តាប់
  - បន្ទាប់ពីម្ចាស់បណ្តាំនឹងសាក្សីបានទទួលស្គាល់ថា កំណត់ហេតុជាលាយលក្សណ៍អក្សរនោះត្រឹមត្រូវហើយជននីមួយៗ ត្រូវចុះហត្ថលេខារៀងខ្លួនៗ។
  - ក្នុងករណីដែលម្ចាស់បណ្តាំមិនអាចសរសេរអក្សរ ឬ មិនអាចចុះហត្ថលេខាបានសាការីត្រូវសរសេរបន្ថែមនូវមូលហេតុទាំងនោះ
  - សាការីត្រូវសរសេរថ្ងៃ ខែ ឆ្នាំ ចុះហត្ថលេខានឹងបោះត្រា ។

---

[3] .ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៧៣។

- មតកសាសន៍ជាលិខិតឯកជន[4]

មតកសាសន៍ដែលធ្វើឡើង ដោយលិខិតឯកជនត្រូវធ្វើឡើង ដោយម្ចាស់បណ្តាំសរសេរពាក្យទាំងអស់នឹងចុះ ថ្ងៃ ខែ ឆ្នាំ ដោយដៃខ្លួនឯង ហើយត្រូវហត្ថលេខាលើលិខិតនោះ ។ មតកសាសន៍ដោយលិខិតឯកជន ដែលបានធ្វើឡើងដោយអ្នកដទៃសរសេរជំនួស ឬប្រើម៉ាស៊ីននឹងចាត់ទុកជាមោឃៈ ។ ម្ចាស់បណ្តាំអាចធ្វើការបន្ថែម ឬ លុបចោល កែប្រែ លើមតកសាសន៍លើលិខិតបាន ដោយបង្ហាញនូវកន្លែង នឹងសរសេរបន្ថែមនូវមូលហេតុនៃការកែប្រែជាពិសេសត្រូវចុះហត្ថលេខា។

- មតកសាសន៍ដោយលិខិតសម្ងាត់[5]

មតកសាសន៍ដោយលិខិតសម្ងាត់ត្រូវធ្វើដូចខាងក្រោម ៖

- ម្ចាស់បណ្តាំអាចសរសេរដោយខ្លួនឯង ឬឲ្យអ្នកដទៃសរសេរជំនួស
- ម្ចាស់បណ្តាំត្រូវចុះហត្ថលេខាលើលិខិតបណ្តាំនោះ
- ម្ចាស់បណ្តាំត្រូវដាក់លិខិតនោះក្នុងស្រោមបិទជិតហើយត្រូវចុះហត្ថលេខាឬ សរសេរ សញ្ញាសម្គាល់ឬមធ្យោបាយផ្សេងៗទៀតដើម្បីបញ្ជាក់ថា ស្រោមនោះ បានបើកឬមិនបានបើកនៅមាត់ស្រោមលិខិតនោះ
- ម្ចាស់បណ្តាំត្រូវដាក់លិខិតនោះ នៅចំពោះសាការីម្នាក់និងសាក្សី២នាក់
- ម្ចាស់បណ្តាំត្រូវប្រាប់ថា លិខិតនោះ ជាលិខិតមតកសាសន៍របស់ខ្ញុំ ហើយបើលិខិតនោះត្រូវបានសរសេរដោយអ្នកដទៃ ម្ចាស់បណ្តាំត្រូវប្រាប់អំពីឈ្មោះ នឹងអាស័យដ្ឋានរបស់ជននោះ
- សាការីត្រូវចុះថ្ងៃ ខែ ឆ្នាំ ដែលសាមីខ្លួនបានដាកលិខិតនោះ និងសរសេរអ្វីដែលម្ចាស់បណ្តាំបានប្រាប់នឹងចុះហត្ថលេខាជាមួយម្ចាស់បណ្តាំនឹងសាក្សីនៅលើលិខិតបិទជិតនោះ ។

➢ **ទម្រង់ពិសេស**

ទម្រង់ពិសេសមានមតកសាសន៍ត្រូវបានចែកចេញជា ៥ រួមមាន ៖

- មតកសាសន៍នៃជនដែលត្រូវជាប់ឃុំឃាំង[6]
- ជនដែលជាប់ឃុំឃាំងអាចធ្វើមតកសាសន៍បានត្រូវមានវត្តមានរបស់នគរបាល ឬមន្ត្រីនៃមន្ទីរឃុំឃាំងម្នាក់ និងសាក្សីយ៉ាងតិច ២ នាក់ ។

---

[4] .ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៧៤។

[5] .ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៧៥។

[6] .ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៧៨។

- ចំណែកឯបុគ្គលដែលនៅក្នុងនាវាឬ យន្តហោះ អាចធ្វើមតកសាសន៍បានត្រូវមានវត្តមានមេបញ្ជាការ បរិបាលនាវា ឬយន្តហោះ ឬបុគ្គលិកនាវា ឬយន្តហោះ ។
- ក្នុងករណីដែលធ្វើជាទម្រង់ជាលិខិតយថាភូត នគរបាល មន្ត្រីមន្ទីរឃុំឃាំង មេបញ្ជាការនគរបាល មន្ត្រី បរិបាលនាវា ឬយន្តហោះ បុគ្គលិកនាវា ឬយន្តហោះ ត្រូវមាននាទីជំនួសសាការី មានន័យថា មន្ត្រីទាំងនោះដើរតួនាទីជាសាការី នៅក្នុងកាលៈទេសៈដូចបានរៀបរាប់ខាងលើ។

- មតកសាសន៍នៃបុគ្គល ដែលមិនអាចនិយាយបាន [7]

បុគ្គលដែលមិនអាចនិយាយបានអាចធ្វើមតកសាសន៍តាមទម្រង់យថាភូត ឬ ទម្រង់លិខិតសម្ងាត់ ឬ ពេលមានគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិតបាន ដោយគោរពតាមលក្ខខណ្ឌដែលមានចែងតាមទម្រង់នីមួយៗ លើកលែងតែ ៖

- ការប្រាប់ដោយផ្ទាល់មាត់អាចជំនួសបានដោយការបកប្រែរបស់អ្នកបកប្រែ ឬសរសេរដោយដៃខ្លួនផ្ទាល់នៅចំពោះមុខ សាការី ឬសាក្សី
- ការអានម្ចាស់បណ្តាំនឹងសាក្សីស្តាប់ដោយសាការី ឬបុគ្គលផ្សេង ដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណីអាចជំនួសដោយការបកប្រែរបស់អ្នកបកប្រែក្នុងករណីដែលម្ចាស់បណ្តាំ ឬសាក្សីជាមនុស្សថ្លង់
- សាការី ឬបុគ្គលដែលបានកំណត់ក្នុងក្រមរដ្ឋប្បវេណី ត្រូវសរសេរអំពីបញ្ហាដែលម្ចាស់បណ្តាំមិនអាចនិយាយបាននិងម្ចាស់បណ្តាំនិងសាក្សីជាមនុស្សថ្លង់ចូលក្នុងលិខិតបណ្តាំនោះ ។

- មតកសាសន៍របស់ពលរដ្ឋខ្មែររស់នៅបរទេស[8]

ពលរដ្ឋ ដែលរស់នៅបរទេសហើយមានបំណងចង់ធ្វើលិខិតបណ្តាំតាមទម្រង់លិខិតយថាភូត ឬលិខិតសម្ងាត់ពលរដ្ឋនោះ អាចធ្វើបាននៅកន្លែងដែលមានកុងស៊ុលនៃព្រះរាជាណាចក្រកម្ពុជា ប្រចាំនៅទីនោះ ។ ក្នុងករណីនេះ កុងស៊ុលត្រូវអនុវត្តតួនាទីរបស់សាការី ។

[7] .ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៧៩។

[8] .ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៨១។

## កថាខណ្ឌទី៣ ភាពដូចគ្នានិងខុសគ្នារវាងសន្តតិកម្មតាមច្បាប់និងមតកសាសន៍

ថ្វីត្បិតតែ សន្តតិកម្មទាំងពីរគឺត្រូវបានធ្វើឡើងក្នុងស្ថានភាពពីរផ្សេងគ្នា ដូចបានរៀបរាប់ខាងលើក៏ពិតមែន ប៉ុន្តែសន្តតិកម្មទាំងពីរក៏មានចំណុចដូចគ្នានឹងខុសគ្នាផងដែរ ដូច្នេះដើម្បីឲ្យកាន់តែយល់ច្បាស់គឺយើងនឹងធ្វើការបង្ហាញអំពីចំណុចដូចគ្នានិងចំណុចខុសគ្នាដូចខាងក្រោម៖

❖ ចំណុចដូចគ្នា

- សន្តតិកម្មទាំងពីរចាប់ផ្តើមនៅពេលដែលមតកជនទទួលមរណភាព ឬបាត់ខ្លួន ចំពោះការបាត់ខ្លួនក៏ត្រូវចាត់ទុកថាជាការទទួលមរណភាពផងដែរ[9] ។
- មិនថាតែការបែងចែកមតិកតាមច្បាប់ ឬតាមមតកសាសន៍នោះទេ បុគ្គលដែលមានសិទ្ធិ និងករណីកិច្ចលើទ្រព្យទាំងនោះ មានសិទ្ធិស្វ័យសម្រេច ក្នុងការមិនទទួលយកទ្រព្យរបស់មតកជនក្រោយពេលស្លាប់ ឬបាត់ខ្លួនបាន ។
- សន្តតិកម្មគឺត្រូវចាប់ផ្តើមនៅលំនៅដ្ឋានរបស់មតកជននាពេលទទួលមរណភាពមានន័យថា ទ្រព្យ ដែលមតកជនបានបន្សល់ទុកគឺ នឹងត្រូវធ្វើការបែងចែកនៅក្នុងលំនៅដ្ឋានចុងក្រោយរបស់មតកជនដែលទទួលមរណភាព។
- ប្រព័ន្ធសន្តតិកម្មទាំងពីរធ្វើការទាមទារឲ្យបុគ្គលដែលមានសិទ្ធិ និងករណីកិច្ចទាំងអស់ត្រូវមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលបានសន្តតិកម្ម ដោយបុគ្គលទាំងនោះ មិនត្រូវក្លាយទៅជាអភ័ព្វបុគ្គល ឬ អ្នកដែលត្រូវផ្តាច់ចេញពីមតិកនោះទេ ។

❖ ចំណុចខុសគ្នា

- សន្តតិកម្មតាមមតកសាសន៍

- អ្នកទទួលបានចំណែកមតិកហៅថា អច្ច័យលាភី
- ជាសន្តតិកម្មមួយដែលបង្កើតឡើងតាមឆន្ទៈរបស់មតកជន
- មិនមានកំណត់អំពីបុគ្គលដែលត្រូវទទួលបានសន្តតិកម្ម
- ការបែងចែកមតិកត្រូវធ្វើតាមសន្តតិកម្មតាមមតកសាសន៍
- សន្តតិជនពេលខ្លះមិនមានភាពយុត្តិធម៌ក្នុងការបែងចែកមតិក
- សន្តតិកម្មតាមមតកសាសន៍មានទម្រង់ក្នុងការបង្កើត
- មតកជនបានបង្ហាញឆន្ទៈដើម្បីឲ្យសន្តតិជនអនុវត្តដោយបង្អង់បាន

[9] .ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ៤៣។

- មិនមានការបែងចែកមត៌កយូរទេ
- មិនមានការកំណត់ថាការប្រគល់មត៌កត្រូវតែជាសាច់ញាតិរបស់មតកជនទេ
- ទាមទារឲ្យមានសាក្សីដើម្បីបង្ហាញអំពីភាពត្រឹមត្រូវនៃលិខិតមតកសាសន៍ ។

• សន្តតិតាមច្បាប់

- អ្នកទទួលបាននូវចំណែកមត៌កហៅថា សន្តតិជន
- ជាសន្តតិកម្មមួយដែលស្ថិតនៅក្រៅឆន្ទៈរបស់មតកជន
- បានកំណត់អំពីបុគ្គលដែលត្រូវក្លាយជាសន្តតិជន
- ការបែងចែកមត៌កត្រូវធ្វើតាមសន្តតិកម្មតាមច្បាប់
- សន្តតិជនទាំងអស់ទទួលបាននូវភាពយុត្តិធម៌
- សន្តតិកម្មតាមច្បាប់គ្មានទម្រង់ក្នុងការបង្កើតទេ
- ចំពោះសន្តតិកម្មតាមច្បាប់មិនមានការអនុវត្តដោយបង្អង់ទេ
- ការបែងចែកមត៌កមានរយៈពេលយូរ
- ការផ្ទេរមត៌កត្រូវតែជាសាច់ញាតិ ឬសហព័ទ្ធរបស់មតកជន
- មិនចាំបាច់មានសាក្សីដើម្បីឲ្យបង្ហាញអំពីក្នុងការបែងចែកមត៌កទេ។

## ផ្នែកទី ២ ចំណែកទ្រព្យអប្បបរមាដែលត្រូវធានាដោយច្បាប់

### កថាខណ្ឌទី១ សញ្ញាណទូទៅ

តាមធម្មតាមានតែបុគ្គលដែលនៅរស់ទេ (មានបុគ្គលភាពគតិយុត្ត) ទើបមានសមត្ថភាពក្នុងការចាត់ចែងផ្សេងៗ លើទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់ខ្លួន។ សមត្ថភាពនេះនឹងត្រូវបាត់បង់នៅពេលបុគ្គលភាពគតិយុត្តត្រូវរលត់ ពោលគឺ នៅពេលទទួលមរណភាព។

ដោយសារក្រមរដ្ឋប្បវេណីកម្ពុជា បានទទួលស្គាល់នូវរបបសន្តតិកម្មតាមច្បាប់ផង និងសន្តតិកម្មតាមបណ្តាំផង ទើបអាចបង្កើតឲ្យមានស្ថានភាពពីរគឺ៖

១.តាមរយៈសន្តតិកម្មតាមច្បាប់ ទាយាទទាំងអស់របស់មតកជន នឹងត្រូវទទួលបាននូវចំណែកមត៌កដែលចំណែកមត៌កនេះ ត្រូវបានកំណត់ និងធានាដោយវិធានច្បាប់ ។

**២.**ចំណែកមតិករបស់ទាយាទ ដែលត្រូវបានធានាដោយវិធានច្បាប់ ដូចខាងលើនឹងត្រូវបាត់បង់ ឬបំរាមដោយសន្តតិកម្មតាមបណ្តាំមតកសាសន៍ ឬការចាត់ចែងទ្រព្យរបស់មតកជនពេលនៅរស់ ។

ហើយដើម្បីសម្របសម្រួលនូវស្ថានភាពទាំងពីរខាងលើនេះ ទើបក្រមរដ្ឋប្បវេណី បានបង្កើតនូវរបបថ្មីមួយគឺរបបភាគបម្រុងដើម្បីកំណត់នូវចំណែកមតិកអប្បរមា សម្រាប់បម្រុងទុកឲ្យសន្តតិជនមួយចំនួន ក្នុងករណី ដែលមតកជនបានធ្វើការចាត់ចែងទ្រព្យតាមឆន្ទៈរបស់ខ្លួនទៅឲ្យជនដ៏ទៃក្រៅពីសន្តតិជន ឬចាត់ចែងទ្រព្យសម្បត្តិមួយភាគធំឲ្យទៅសន្តតិជនមួយចំនួនដោយធ្វើឲ្យសន្តតិជនមួយចំនួនផ្សេងទៀតទទួលបានចំណែកមតិកក្នុងបរិមាណតិចតួចមិនសមហេតុផល ឬពុំទទួលបាននូវចំណែកនោះសោះតែម្តង។

ខាងក្រោមនេះ យើងនិងធ្វើការសិក្សាលម្អិតអំពីអ្វីទៅជារបបនៃភាគបម្រុង ដើម្បីធ្វើជាទុនបន្ថែមក្នុងការសិក្សាស្វែងយល់ឲ្យកាន់តែច្បាស់ អំពីប្រព័ន្ធសន្តតិកម្មនៃព្រះរាជាណាចក្រកម្ពុជាយើង។

**ក.និយមន័យ**

ក្រមរដ្ឋប្បវេណីកម្ពុជាបច្ចុប្បន្នមិនមានមាត្រាណាមួយ កំណត់និយមន័យឲ្យបានជាក់លាក់នោះទេ អំពីអ្វីទៅជា "ភាគបម្រុង" នោះឡើយ ។

ប៉ុន្តែបើយើងធ្វើការសិក្សាទៅលើក្រមរដ្ឋប្បវេណីឆ្នាំ ១៩៦៧ ឃើញថាគេបានឲ្យនិយមន័យដូច្នេះថា ៖ "ភាគបម្រុង" គឺជារបបមួយនៃបេតិកភណ្ឌ ដែលម្ចាស់បណ្តាំខ្លួនឯងផ្ទាល់ក៏មិនអាចនឹងចាត់ចែងយ៉ាងណាៗ ដោយសេរីបានឡើយ ។

ទោះបីជាក្រមរដ្ឋប្បវេណីមិនបានឲ្យនិយមន័យនៃរបបភាគបម្រុងនេះ ក៏ដោយតែយើងអាចកំណត់អំពីអត្ថន័យនៃរបបនេះតាមរយៈការសិក្សាលើ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ២០០៧ បានឲ្យនិយមន័យថា **ភាគបម្រុង** គឺជាសិទ្ធិភាគដែលទទួលបានមតិកជាអប្បរមាដែលត្រូវធានាដោយច្បាប់ចំពោះអ្នកមានសិទ្ធិលើភាគបម្រុង[10]។ ឬអាចឲ្យនិយមន័យថា ភាគបម្រុងគឺជាភាគនៃមតិកដែលត្រូវបានបម្រុងទុកឲ្យជន ដែលមានសិទ្ធិលើភាគបម្រុងមិនថាតែតាមសន្តតិកម្មតាមច្បាប់ ឬសន្តតិកម្មតាមបណ្តាំឡើយ ដែលភាគបម្រុងរបស់អ្នកមានសិទ្ធិនេះត្រូវបានធានាដោយមិនឲ្យមានការបំពានឡើយ សូម្បីតែមតកជនផ្ទាល់ខ្លួនឯង។

---

[10] .ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៣០។

ជាទូទៅនៅក្នុងមត៌កមានភាគពីរផ្សេងគ្នាគឺភាគទំនេរជាភាគដែលមតកជន អាចចាត់ចែងដោយសេរីតាមឆន្ទៈរបស់ខ្លួនប៉ុន្តែភាគបម្រុងវិញជាភាគដែលមិនអាចបំពាន ឬ ចាត់ចែងបានដោយបុគ្គលណាមួយនឹងសូម្បីតែមតកជនខ្លួនឯង។

**ខ.គោលបំណង**

បញ្ញត្តិស្ដីពីភាគបម្រុង ត្រូវបានបង្កើតឡើង ក្នុងគោលបំណងដូចខាងក្រោមៈ

- ធានានូវចំណែកមត៌កអប្បរមាចំពោះសន្តតិជនមួយចំនួន(ញាតិជិតស្និទ្ធិនឹងមតកជន) ។

- អនុញ្ញាតឲ្យសន្តតិជនបានមួយចំនួន អ្នកមានសិទ្ធិលើភាគបម្រុងបដិសេធនូវសេរីភាពមួយផ្នែកដែលជាឆន្ទៈរបស់មតកជននៅក្នុងមតកសាសន៍ [11]។

**គ.ផលប្រយោជន៍**

ការកំណត់អំពីភាគបម្រុង មានផលប្រយោជន៍ដូចខាងក្រោមៈ

- ផលប្រយោជន៍ការសម្របសម្រួលរវាងសន្តតិកម្មតាមច្បាប់ និងសន្តតិកម្មតាមមតកសាសន៍ដើម្បីជាប្រយោជន៍ដល់ការសម្របសម្រួលរវាងសន្តតិកម្មតាមច្បាប់ នឹងសន្តតិកម្មតាមមតកសាសន៍ នេះមានន័យថា ជាទូទៅមិនថាសន្តតិកម្មតាមច្បាប់ នឹងសន្តតិកម្មតាមមតកសាសន៍ នោះទេ តែងតែមានការបំពាននូវភាគបម្រុង។ ដូចដែលយើងដឹងហើយថា សន្តតិកម្មតាមច្បាប់ គឺជាផ្ទេរបេតិកភ័ណ្ឌពីមតកជនដែលឥតមានលិខិតបណ្ដាំ ហើយការបែងចែកចំណែកមត៌កត្រូវផ្អែក តាមបញ្ញាត្តិនៃច្បាប់ដោយមិនបានគិតពីឆន្ទៈរបស់មតកជនឡើយ ប៉ុន្តែវាអាចមានការបំពាននៅពេលដែលសន្តតិជនណាម្នាក់ ឬច្រើននាក់នោះបានទទួលនូវផលប្រយោជន៍ពិសេសឬ ប្រទានកម្មជាដើមនៅមុនពេលដែលមតកជនទទួលមរណភាពដែលវាជាហេតុធ្វើឲ្យសន្តតិជនដទៃទៀតទទួលចំណែកមត៌កតិចតួចដែលមិនគួរនឹងទទួល ឬ មិនទទួលបានសោះតែម្ដង បើប្រៀបធៀបទៅនឹងសន្តតិជន ដែលបានទទួលនូវផលប្រយោជន៍ពិសេសទាំងនោះ ។ ចំណែកឯសន្តតិកម្មតាមមតកសាសន៍គឺផ្អែកតាមឆន្ទៈ (ករណីមានលិខិតបណ្ដាំ) របស់មតកជន ដែលពេលខ្លះមតកជនបានផ្ទេរនូវទ្រព្យសម្បត្តិរបស់ខ្លួនឲ្យទៅសន្តតិជនណាម្នាក់ លើសសន្តតិជនដទៃទាំងអស់ដោយមានមូលហេតុផ្សេងៗ ឬក៏បានផ្ទេរនូវទ្រព្យសម្បត្តិទាំងនោះឲ្យទៅតតិយជនតាមរយៈការធ្វើអច្ច័យទាន

[11]. ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៣០។

ជាដើមដែលជាហេតុធ្វើឲ្យបំពានលើសន្តតិជនដទៃទៀត ។ ដោយសារតែតាមការផ្ទេរនូវបេតិកភ័ណ្ឌរបស់មតកជនពេលខ្លះវាអាចធ្វើមានការបំពានទៅសន្តតិជនដទៃទៀតដោយសន្តតិជន នោះទទួលបានតិចតួចឬក៏មិនទទួលបានមរតកទាល់តែសោះ។ ដូច្នេះ ដើម្បីជៀសវាងនូវការបំពានទាំងនោះទើបមានការកំណត់ភាគបម្រុងនេះឡើង ។

- រក្សានូវចំនែកមតិកជាក់លាក់លើទ្រព្យរបស់មតកជន ដែលបានរស់នៅក្នុងបន្ទុកហើយជៀសវាង ឬ បង្ការដើម្បីកុំឲ្យមានជម្លោះនិងគ្នារវាងបងប្អូនសាច់ញាតិដោយសារតែទ្រព្យដែលនាំឲ្យឈានទៅការបែកបាក់ក្នុងក្រុមគ្រួសារ និងមិនរាប់រកគ្នាជាបងប្អូន ឬ ចងគុំនុំនឹងគ្នា ។ ចំណែកឯនៅក្នុងក្រមរដ្ឋប្បវេណីបានចែងថា ផលប្រយោជន៍នៃការកំណត់ភាគបម្រុងគឺរក្សានូវចំណែកមតិកជាក់លាក់លើទ្រព្យរបស់មតកជន ដើម្បីការពារប្រយោជន៍អ្នកដែលជាសន្តតិជនប៉ុណ្ណោះ ដោយមិនចង់ឲ្យទ្រព្យសម្បត្តិធ្លាក់ទៅជនដែលមិនមែនជាសាច់ញាតិរបស់មតកជន។

- ដោះស្រាយនូវចំនែកមតិកជាសក្តានុពលសម្រាប់ញាតិជិតស្និទ្ធិ បញ្ហាមួយចំនួនតែងតែកើតឡើងនៅក្នុងការបែងចែកនូវចំណែកមតិក ដូច្នេះហើយ ការកំណត់ភាគបម្រុងគឺពិតជាមានសារៈសំខាន់ខ្លាំងណាស់ ចំពោះការបែងចែកនូវចំណែកមតិក សម្រាប់ញាតិជិតស្និទ្ធិ ដោយមតកសាសន៍ត្រូវធ្វើឡើងតាមឆន្ទៈរបស់មតកជន ប៉ុន្តែច្បាប់មិនអនុញ្ញាតឲ្យតតិយជនទទួលចំណែកទ្រព្យសម្បត្តិទាំងអស់ ហើយដោយមិនគិតពីសន្តតិជនឡើយ។ ដូចនេះ វិធីដោះស្រាយនូវចំណែកមតិកជាសក្តានុពលសម្រាប់ញាតិជិតស្និទ្ធិ ដែលបានចូលរួមក្នុងការបង្កើតទ្រព្យសម្បត្តិរបស់មតកជនគឺមិនចាំបាច់ពិភាក្សាអំពីការបែងចែកមតិក ដោយសហសន្តតិជនទេ។

## កថាខណ្ឌទី២ អ្នកមានសិទ្ធិលើភាគបម្រុង

ក្រមរដ្ឋប្បវេណីកម្ពុជា បានកំណត់យកជនមួយចំនួនដែលជាប់ទំនាក់ទំនងយ៉ាងជិតសិទ្ធិជាមួយមតកជនជាអ្នកមានសិទ្ធិលើភាគបម្រុង[12] ។

អ្នកមានសិទ្ធិលើភាគបម្រុងរួមមាន៖

- បច្ឆាញាតិផ្ទាល់ ឬសន្តតិជនរបស់ពួកគេ (កូនរបស់សន្តតិជនដែលអាចក្លាយជាសន្តតិជនជំនួស)

- ឪពុក ម្តាយនិងជីដូន ជីតា

[12] .ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៣០។

- សហាព័ទ្ធ ។

ដោយឡែកចំពោះបងប្អូនបង្កើត (សន្តតិជនលំដាប់ទី៣) និងសន្តតិជនតាមច្បាប់ដ៏ទៃពុំមានភ័ព្វជាអ្នកមានសិទ្ធិភាគបម្រុងនោះទេ ។

ខ្លឹមសារខាងលើនេះ គឺឆ្លុះបញ្ចាំងពីទំនាក់ទំនងនៃការកំណត់លំដាប់សន្តតិជន ដែលយើងគប្បីដឹងថា សន្តតិជនលំដាប់ណាខ្លះដែលជាអ្នកមានសិទ្ធិលើភាគបម្រុង ហើយសន្តតិជនដែលនៅលំដាប់បន្ទាប់អាចទទួលបានសិទ្ធិលើភាគបម្រុងដែរឬទេ?

នៅក្នុងចំណោមសន្តតិជនដែលរួមមានបច្ឆាញាតិផ្ទាល់ ឪពុក ម្តាយ ជីដូន ជីតា និង សហាព័ទ្ធ គឺមានតែសន្តតិជននៅក្នុងលំដាប់ ដែលត្រូវទទួលមតិកប៉ុណ្ណោះទើបមានសិទ្ធិលើភាគបម្រុង។

## ក.បច្ឆាញាតិផ្ទាល់

បច្ឆាញាតិផ្ទាល់ជាអ្នកមានសិទ្ធិលើភាគបម្រុង ។ មានន័យថា ជនមួយពួកដែលកើតចេញពីជនមួយពួកទៀត ។ ឧទាហរណ៍ កូនជាបច្ឆាញាតិផ្ទាល់របស់ឪពុកម្តាយ ចៅជាបច្ឆាញាតិរបស់ជីដូនជីតា នៅទីនេះ យើងនឹងធ្វើការបកស្រាយអំពីកូនដែលជាបច្ឆាញាតិផ្ទាល់ឪពុកម្តាយដោយមិនលើកយកចៅមកធ្វើការបកស្រាយនោះទេ ពីព្រោះចៅរបស់មតកជន ឬ អាចនិយាយបានថាកូនរបស់កូនដែលជាសន្តតិជន ហើយត្រូវជាចៅរបស់មតកជនអាចទាមទារភាគបម្រុងបានតាមរយៈសន្តតិកម្មជំនួសដែលយើងនឹងធ្វើការពន្យល់នៅក្នុងកថាខណ្ឌទាក់ទងនឹងសន្តតិកម្មជំនួស ។

## ខ.ឪពុកម្តាយឬជីដូនជីតា

ឪពុកម្តាយ ឬជីដូនជីតាត្រូវបានច្បាប់ចាត់ទុកជាសន្តតិជន ដែលមានសិទ្ធិលើភាគបម្រុងផងដែរ។ឪពុកម្តាយ ការរស់នៅក្នុងជីវភាពប្រចាំថ្ងៃទំនាក់ទំនងរវាងឪពុកម្តាយនឹងកូនមានលក្ខណៈស្មុគ្រស្មាញរវាងឪពុកម្តាយបង្កើត និងកូនបង្កើត ឬឪពុកម្តាយចិញ្ចឹមនឹងកូនសុំ ។តើទាំងឪពុកម្តាយបង្កើត និងឪពុកម្តាយចិញ្ចឹមមានសិទ្ធិលើភាគបម្រុងដូចគ្នាដែរឬទេ ?

ជាការពិតណាស់ឪពុកម្តាយបង្កើតជាសន្តតិជនដែលមានសិទ្ធិលើភាគបម្រុង ។ គ្មានអ្វីប្លែកទេព្រោះច្បាប់បានទទួលស្គាល់ឪពុកម្តាយជាសន្តតិជនលំដាប់ទី២តាមការកំណត់របស់ច្បាប់ដែរ ។ ប៉ុន្តែ មានករណីមួយដែលឪពុកម្តាយបង្កើតមិនអាចក្លាយជាសន្តតិជននឹងគ្មានសិទ្ធិលើភាគបម្រុងដែលយើងមិនត្រូវមើលរំលងនោះគឺ ឪពុកម្តាយរបស់កូនសុំពេញលេញ ។ ដូចដែលយើងដឹងហើយថា ញាតិភាពរវាងកូនសុំ នឹងឪពុកម្តាយបង្កើតព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើតនោះ

ត្រូវបានបញ្ចប់ដោយសុំកូនពេញលេញ ។ ចំពោះទំនាក់ទំនងឪពុកម្ដាយចិញ្ចឹមវិញ ទោះបីជាឪពុកម្ដាយចិញ្ចឹមរបស់កូនសុំពេញលេញ ឬធម្មតាសុទ្ធតែអាចក្លាយជាសន្តតិជននឹងមានសិទ្ធិលើភាគបម្រុងដូចគ្នា ។

ពាក់ព័ន្ធនឹងជីដូនជីតា ចំពោះជីដូនជីតានៃឪពុកម្ដាយបង្កើតរបស់កូនសុំពេញលេញ មិនក្លាយជាសន្តតិជនទេ ពីព្រោះការបញ្ចប់ញាតិភាពមិនមែនមានអានុភាពត្រឹមតែឪពុកម្ដាយបង្កើតតែប៉ុណ្ណោះទេ គឺញាតិលោហិតទាំងអស់តែម្ដង ។ ផ្ទុយទៅវិញជីដូនជីតានៃឪពុកម្ដាយចិញ្ចឹមរបស់កូនសុំមិនថាតែសុំពេញលេញ ឬធម្មតាក៏ដោយគឺដូចគ្នានឹងឪពុកម្ដាយចិញ្ចឹមដែរ ។

### **គ.សហព័ទ្ធ**

សហព័ទ្ធរបស់មតកជនជាសន្តតិជនជានិច្ច[13]។

ជាគោលការណ៍ក្រមរដ្ឋប្បវេណីទទួលអ្នកទាំងនេះ ជាសន្តិតជនដែលត្រូវទទួលបន្តនូវមតិករបស់សាច់ញាតិដែលបានស្លាប់ទៅហើយនោះ ប៉ុន្តែទោះជាយ៉ាងនេះក្ដី ក៏មិនមានន័យថាអ្នកទាំងអស់គ្នានោះក៏ទទួលបាននូវចំណែកមតិកគ្រប់គ្នានោះដែរ។ ច្បាប់បានបញ្ញត្តិនូវលំដាប់នៃការទទួលទ្រព្យសម្បត្តិ ដែលជាមតិកនៃមតកជនដោយកំណត់យកបច្ឆាញាតិផ្ទាល់របស់មតកជន ជាអ្នកមានសិទ្ធិទទួលបានមតិកមុនគេ។ ក្នុងករណីដែលមតកជនគ្មានបច្ឆាញាតិផ្ទាល់ទាល់តែសោះនោះ មតិករបស់មតកជននឹងត្រូវទទួលបន្តដោយបុព្វញាតិផ្ទាល់របស់មតកជននោះ ។ ចំពោះសន្តតិជនលំដាប់ទី៣វិញលុះត្រាតែមតកជននោះគ្មានបច្ឆាញាតិផ្ទាល់ ហើយក៏គ្មានបុព្វញាតិផ្ទាល់ដែរ នោះទើបខ្លួនអាចទទួលបានឋានៈ ជាសន្តតិជន ។

ដោយឡែកសហព័ទ្ធរបស់មតកជនជាជនដែលមានភ័ព្វទទួលបានឋានៈជាសន្តតិជនជានិច្ចទោះជាមានសន្តតិជនលំដាប់ណាក៏ដោយក៏ សហព័ទ្ធនៅតែទទួលបានឋានៈជាសន្តតិជនដ៏ដែលពោលគឺ មិនថាស្ថិតក្នុងកាលៈទេសៈណាក៏ដោយ ។

ចំពោះភាគបម្រុង អ្នកដែលមានសិទ្ធិគឺមានតែសន្តតិជនលំដាប់ទី១ ទី២ (កំណត់ត្រឹមបុព្វញាតិផ្ទាល់ថ្នាក់ទី២) និងសហព័ទ្ធតែប៉ុណ្ណោះ ។ ប៉ុន្តែទោះជាយ៉ាងនេះក៏ដោយ ក៏មិនមានន័យថា ជនទាំងអស់នោះ ទទួលបានសិទ្ធិលើភាគបម្រុងគ្រប់គ្នានោះដែរ ពោលគឺអ្នកមានសិទ្ធិលើភាគបម្រុងត្រូវអនុវត្តតាមលំដាប់នៃសន្តតិជនដូចខាងក្រោម៖

- សហព័ទ្ធមានសិទ្ធិលើភាគបម្រុងជានិច្ច ។

[13] .ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៦១។

- បើមានសន្តតិជនលំដាប់ទី១ជាអ្នកមានសិទ្ធិលើភាគបម្រុងហើយនោះ សន្តតិជនលំដាប់ទី២ពុំមានសិទ្ធិទទួលឋានៈជាអ្នកមានសិទ្ធិលើភាគបម្រុងនោះទៀតឡើយ ។

**កថាខណ្ឌទី៣ សន្តតិកម្មជំនួស**

សន្តតិកម្មជំនួសមានន័យថា ការទទួលជំនួសនូវមតិករបស់ជនដែលត្រូវក្លាយជាសន្តតិជន ប៉ុន្តែដោយសារតែមានហេតុការណ៍ណាមួយ ដែលមិនអាចឲ្យសន្តតិជនទាំងនោះមានលទ្ធភាពក្នុងការទទួលនូវបានសន្តតិកម្មទាំងនោះ ដូចជាសន្តតិជននោះ បានទទួលមរណភាពនៅមុនពេលឬដំណាលគ្នានឹងមតកជន ឬ បាត់បង់សិទ្ធិទទួលសន្តតិកម្មដោយត្រូវនឹងលក្ខខណ្ឌដែលបានបញ្ញាត្តិនៃមាត្រា ១១៥០ ( អភ័ព្វបុគ្គល) ឬការផ្តាច់ចេញពីមតិកជាដើម ។

ដូច្នេះ កូនរបស់ជនទាំងនោះ (ជនដែលបានរៀបរាប់ខាងលើ) នេះនឹងត្រូវក្លាយជាសន្តតិជនជំនួស។ ចំពោះបញ្ញាត្តិនៃមាត្រា ១២៣០ ស្តីពីភាគបម្រុងក៏ត្រូវយកមកអនុវត្តដូចគ្នាផងដែរក្នុងករណីសន្តតិកម្មជំនួស។ មានន័យថា ក្នុងករណីដែលសន្តតិជនដែលត្រូវទទួលបាននូវភាគនៃភាគបម្រុងនោះបានបាត់បង់លទ្ធភាពក្នុងការទទួល ដូច្នេះត្រូវមានអ្នកមកទទួលជំនួសដែលអាចជាកូនរបស់សន្តតិជននោះជាដើម។

ខាងក្រោមនេះគឺជាឧទាហរណ៍ខ្លះអំពីបញ្ហាទាំងអស់ខាងលើ ។

**ឧទាហរណ៍**

លោក **ក** មានកូនប្រុសម្នាក់ គឺ **គ** នឹងមាន ខ ជាសហព័ទ្ធ ។ ក្នុងករណីនេះ សន្តតិជនរបស់លោក **ក** មានតែកូនម្នាក់ គឺ **គ** និងសហព័ទ្ធ ខ ដូច្នេះនាំឲ្យភាគបម្រុងរបស់អ្នកទាំង ២ នេះ គឺ ១/២ នៃទ្រព្យសម្បត្តិដែលមូលដ្ឋានក្នុងការគណនាភាគបម្រុង ។

ហើយចំណែកភាគបម្រុងរបស់សន្តតិជនម្នាក់ៗគឺស្មើនឹង១/៤ ។ ក្នុងករណីនេះប្រសិន គ ដែលកូនទទួលមរណភាពមុនពេលចាប់ផ្តើមសន្តតិកម្ម នោះកូន របស់ គ ( ចៅរបស់មតកជន ក ) នឹងទទួលបានឋានៈជាអ្នកមានសិទ្ធិលើភាគបម្រុងផងដែរ តាមរយៈសន្តតិកម្មជំនួស[14] ។

**ឧទាហរណ៍**

ក្នុងករណីដែលលោក **ក** មាននារី **ខ** ជាសហព័ទ្ធហើយគ្មានកូន ។ ប៉ុន្តែលោក **ក** នៅមានឪពុកនិងម្តាយបង្កើតរបស់ខ្លួន ។ ក្នុងករណីនេះ មាត្រា១២៣០ ចំណុច **ខ** ត្រូវយកមកអនុវត្តដោយ

[14] .ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៥៧។

ហេតុមានសន្តតិជនផ្សេងពីឪពុកម្តាយនាំឲ្យចំណែកភាគបម្រុងដែលត្រូវធានាស្មើនឹង ១/២។ ហើយ ចំណែក ភាគបម្រុងនៃសន្តតិជនម្នាក់ៗ ត្រូវទទួលបានតាមសមាមាត្រនៃចំណែកមតិករបស់ខ្លួន សហព័ទ្ធ ១/៣ ឪពុកម្តាយ ២/៣ នាំឲ្យចំណែក ១/៦ ស្មើៗគ្នា។

○ **ករណីពិសេសទាក់ទងនឹងបងប្អូនបង្កើត**

តើបងប្អូនបង្កើតមានសិទ្ធិលើភាគបម្រុងដែរឬទេ ?

នៅក្នុងការស្រាវជ្រាវលើករណីទាក់ទងនឹងបងប្អូនបង្កើត ដែលថាគ្មានសិទ្ធិឬមានសិទ្ធិលើភាគបម្រុងនោះ វាហាក់ដូចជានូវមានភាពស្រពិចស្រពិលនៅឡើយ ។ ដោយសារបញ្ញត្តិច្បាប់បានចែងទាក់ទងករណីនេះ មិនមានលម្អិតនឹងខ្វះខាតជាច្រើន ដូចនេះទាមទារឲ្យមានការបកស្រាយនឹងពន្យល់ឲ្យស៊ីជម្រៅថែមទៀត ។

បើយើងមើលទៅលើមាត្រា ១២៣០ នៃក្រមរដ្ឋប្បវេណីដែលបានបញ្ញតិអំពីអ្នកដែលសិទ្ធិលើភាគបម្រុងនោះយើងនឹងឃើញថា មានតែបច្ឆាញាតិផ្ទាល់ ឪពុកម្តាយ ឬជីដូនជីតា និងសហព័ទ្ធរបស់មតកជនតែប៉ុណ្ណោះដែលជាអ្នកមានសិទ្ធិលើភាគបម្រុង ។ នៅក្នុងបញ្ញតិនេះ យើងអាចនិយាយបានថា បងប្អូនបង្កើតគ្មានសិទ្ធិលើភាគបម្រុងទេ ដោយសារតែច្បាប់មិនបានបញ្ញតិម្យ៉ាងទៀតទាក់ទងនឹងអ្នកសិទ្ធិលើភាគបម្រុងនេះដែរ បង្ហាញថា ជនទាំងនោះសុទ្ធតែជាសន្តតិជនតាមច្បាប់កំណត់ ។ ជាក់ស្តែងបច្ឆាញាតិជាសន្តតិជនលំដាប់ទី១ ចំណែកឯឪពុកម្តាយ ឬជីដូនជីតាជាសន្តតិជនលំដាប់ទី២ រួមទាំងសហព័ទ្ធក៏ជាសន្តតិជនជានិច្ចដែរ ។ មានន័យថា អ្នកមានសិទ្ធិលើភាគបម្រុងគឺសម្តៅដល់ជនដែលច្បាប់បានទទួលថា ជាសន្តតិជន ប៉ុន្តែជនទាំងនោះត្រូវបានរំលោភបំពាននូវចំណែកមតិករបស់ខ្លួន ។

## កថាខណ្ឌទី៤ លក្ខខណ្ឌក្លាយជាអ្នកមានសិទ្ធិ និងចំណែកមត៌ករបស់អ្នកមានសិទ្ធិនោះ

### ក.លក្ខខណ្ឌក្លាយជាអ្នកមានសិទ្ធិលើភាគបម្រុង

លក្ខណៈសម្បត្តិជាអ្នកមានសិទ្ធិលើភាគបម្រុង ពុំមានចែងនៅក្នុងក្រមរដ្ឋប្បវេណីទេ ប៉ុន្តែយើងអាចធ្វើការកត់សម្គាល់ អំពីលក្ខណៈសម្បត្តិ ដើម្បីក្លាយជាអ្នកមានសិទ្ធិលើភាគបម្រុងបានលុះត្រាតែបំពេញនូវលក្ខខណ្ឌពីរយ៉ាង គឺ ទី១ អ្នកមានសិទ្ធិលើភាគបម្រុងត្រូវតែជាសន្តតិជនដែលកំណត់ដោយច្បាប់ (ក.១) ហើយលក្ខណៈក្លាយជាសន្តតិជននេះ ក៏មានកំណត់នៅក្នុងក្រមរដ្ឋប្បវេណីផងដែរ ។ បន្ថែមពីលើនេះ ទៅទៀតភាពជាសន្តតិជនតែមួយមុខមិនអាចគ្រប់គ្រាន់នៅ

ឡើយទេ វាទាមទារឲ្យមាននូវការបំពានចំណែកមតិកមួយទៀត (ក.២) ដែលជាធាតុផ្សំដែលមិនអាចខ្វះបាន ។

### ក.១. បុគ្គលដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ជាសន្តតិជន

សន្តតិជនដែលអាចទទួលមតិកបានលុះត្រាតែបុគ្គលនោះ ជាសន្តតិជនដែលមានជីវិតនៅរស់នៅពេលចាប់ផ្តើមសន្តតិកម្មតែប៉ុណ្ណោះ ។ ប្រសិនបើជនដែលត្រូវបានសន្មតថាជាសន្តតិជននោះ បានទទួលមរណភាពភាពមុនពេល ឬតំណាលគ្នានឹងមតកជននោះ សន្តតិជនមិនអាចបំពេញលក្ខខណ្ឌមានជីវិតរស់នៅពេលចាប់ផ្តើមសន្តតិកម្មទេ ដូច្នេះ មិនអាចទទួលបានសន្តតិកម្មឡើយ ។ លើសពីនេះសន្តតិជនត្រូវតែមិនមែនជាអភ័ព្វបុគ្គលហើយនឹងមិនមែនជាជនដែលត្រូវផ្តាច់ចេញពីមតិក[15] ។

### ក.២. មានការបំពានលើចំណែកមតិក

ការបំពានលើចំណែកមតិករបស់សន្តតិជនគឺជាធាតុផ្សំមួយដ៏សំខាន់ ដែលមិនអាចខ្វះបាន ប្រសិនបើមិនមានការបំពានលើចំណែកមតិកទេនោះ សន្តតិជនមិនអាចក្លាយជាអ្នកមានសិទ្ធិលើភាគបម្រុងបានទេ ។

ឧទាហរណ៍ មតកជនមានកូន ២នាក់ និងសហព័ទ្ធដោយមតកជនបានបន្សល់ទុកនូវទ្រព្យចំនួន ១០០០ដុល្លារ ។ នៅក្នុងមតកសាសន៍បានកំណត់បែងចែកទ្រព្យសម្បត្តិ ៣០០ដុល្លារ ឲ្យទៅសហព័ទ្ធ ហើយកូនម្នាក់ៗបាន ៣០០ ដុល្លារដែរ ចំណែក ១០០ ដុល្លារដែលនៅសល់ត្រូវឲ្យទៅ បងរបស់មតកជន ។ ចំពោះករណីដែលបានលើកឡើងខាងលើ កូន ២ នាក់ នឹងសហព័ទ្ធរបស់មតកជនជាសន្តតិជនដែលកំណត់ដោយច្បាប់ ប៉ុន្តែពួកគេមិនមានសិទ្ធិលើភាគបម្រុងទេ ដោយសារតែទ្រព្យដែលទទួលនោះមិនមានការបំពាន ។

### ខ.ចំណែកនៃភាគបម្រុង

ការកំណត់ចំណែកមតិករបស់អ្នកមានសិទ្ធិលើភាគបម្រុងគឺជាអ្វីដែលមិនអាចខ្វះបានព្រោះច្បាប់បានអនុញ្ញាតឲ្យអ្នកមានសិទ្ធិលើភាគបម្រុង មានសិទ្ធិទាមទារនៅចំណែកមតិករបស់ខ្លួន តែ

[15] .ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៥០ និងមាត្រា ១១៥១។

មិនមែនទាមទារបានដោយសេរីនោះទេ ហេតុនេះហើយច្បាប់បានកំណត់ អំពីគោលការណ៍នៃចំណែកមតិក។

នៅក្នុងការបែងចែកចំណែកនៃភាគបម្រុងនេះ វាពុំមានលក្ខណៈស្មើគ្នានោះទេគឺវាអាស្រ័យទៅតាមលំដាប់ និងចំនួនសន្តិជនប៉ុណ្ណោះ។ ខាងក្រោមនេះគឺជាចំនែកដែលសន្តតិជនម្នាក់ៗ ទទួលបានយោងតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា៖

- **ករណីដែលមតកជនមានតែឪពុកម្ដាយ ឬ ជីដូនជីតាជាសន្តតិជន**

ក្នុងករណីដែលមតកជនមានតែឪពុកម្ដាយ ឬ ជីដូនជីតាជាសន្តតិជននោះភាគបម្រុងត្រូវស្មើនឹង១ ភាគ ៣ (មួយភាគបី) នៃទ្រព្យសម្បត្តិរបស់មតកជន [16] ។

**ឧទាហរណ៍៖** មតកជន មានទ្រព្យសម្បត្តិចំនួន ៣០០០ ដុល្លារ នោះភាគបម្រុងស្មើនឹង ១០០០ដុល្លារ ។

នៅក្នុងសន្តតិកម្មតាមច្បាប់បុព្វញាតិជាសន្តតិជនដែលស្ថិតនៅក្នុងលំដាប់ថ្នាក់ទី ២ ប៉ុន្តែមានតែបុព្វញាតិដែលជាឪពុកម្ដាយ ឬ ជាជីដូនជីតាទេដែលជាមានសិទ្ធិលើភាគបម្រុង ។ មានន័យថាប្រសិនបើមតកជនគ្មានប្រពន្ធ គ្មានកូន គ្មានឪពុកម្ដាយ គ្មានជីដូនជីតា មានតែយាយទួត តាទួតនោះយាយទួត តាទួតនោះគឺជាសន្តតិជន ប៉ុន្តែយាយទួត តាទួតនោះមិនមានសិទ្ធិភាគបម្រុងឡើយ ។

- **ករណីមានសន្តតិជនផ្សេងទៀតដូចជា កូន ឬសហព័ទ្ធ**

១ ភាគ២ (មួយភាគពីរ)នៃទ្រព្យសម្បត្តិរបស់មតកជនក្នុងករណីផ្សេងពីនេះ។ ក្នុងករណីដែលសន្តតិជនដែលមានសិទ្ធិលើភាគបម្រុងច្រើននាក់ អ្នកមានសិទ្ធិម្នាក់ៗ អាចទទួលបានចំណែកលើភាគបម្រុងតាមសមាមាត្រចំណែកមតិកដែលខ្លួនត្រូវទទួលបានតាមច្បាប់ [17]។

យើងឃើញថា ច្បាប់បានកំណត់យកចំណែក១ភាគ៣ជាភាគបម្រុងសម្រាប់ ឪពុក ម្ដាយ ឬជាជីដូន ជីតា ប៉ុន្តែសូមពិនិត្យមើលលើឃ្លា " ក្នុងករណីមានតែសន្តតិជនជាឪពុក ម្ដាយ ឬជីដូន ជីតា " ។ ហើយចំណែក១ភាគ២នៃទ្រព្យសម្បត្តិរបស់ មកតជនក្នុងករណីផ្សេង ។ មានន័យថា ក្នុងករណីដែលគ្មានសន្តតិជនជាសហព័ទ្ធ ហើយមានតែឪពុក ម្ដាយ ឬមានតែជីដូន ជីតា នោះចំណែក

[16] .ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៣០ ចំណុច ក។

[17] .ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៣០ ចំណុច ខ ។

ភាគបម្រុងត្រូវផ្តល់ឲ្យ ១/៣ (មួយភាគបី) តែបើមានសន្តតិជនផ្សេងទៀតដូចជា កូន ឬសហព័ទ្ធ នោះភាគនៃភាគបម្រុងត្រូវគិត ១/២ (មួយភាគពីរ) ។

# ជំពូកទី ២
# វិធីសាស្ត្រក្នុងការគណនាភាគបម្រុង

បន្ទាប់ពីបានសិក្សាអំពីអ្នកមានសិទ្ធិលើភាគបម្រុង និងចំណែកមត៌ករួចហើយ នៅពេលនេះ យើងនឹងបង្ហាញ អំពីចំនួនទឹកប្រាក់ពិតប្រាកដ ដែលមតកជនបានបំពានលើចំណែកមត៌ករបស់សន្តិជនដោយធ្វើការគណនាភាគបម្រុងដែលសន្តតិជនមានសិទ្ធិលើភាគបម្រុងអាចទាមទារបាន ។ ថាតើអ្នកមានសិទ្ធិអាចទាមទារបាននូវចំណែកមត៌ករបស់ខ្លួនប៉ុន្មាននោះ ជាដំបូង មុននឹងឈានដល់ការគណនាយើងចាំបាច់ត្រូវស្គាល់ជាមុនសិន ថាតើប្រភេទទ្រព្យណាខ្លះដែលត្រូវច្បាប់ចាត់ទុកថាជាមូលដ្ឋានក្នុងការគណនាភាគបម្រុងរួចហើយ ទើបយើងធ្វើការគណនាតាមទ្រព្យដែលមានជាក់ស្តែងនោះ ។

## ផ្នែកទី ១ ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនា

ទ្រព្យដែលមាននៅចាប់ផ្តើមគណនារួមមាន ទ្រព្យដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម (កថាខណ្ឌទី១) តម្លៃនៃផលប្រយោជន៍ពិសេស (កថាខណ្ឌទី២) តម្លៃនៃប្រទានកម្ម (កថាខណ្ឌទី៣) មិនតែប៉ុណ្ណោះកាតព្វកិច្ចក៏ត្រូវបានចាត់ទុកជាមូលដ្ឋានក្នុងការគណនាភាគបម្រុងផងដែរ (កថាខណ្ឌទី៤) ។

### កថាខណ្ឌទី១ ទ្រព្យដែលមាន នៅពេលចាប់ផ្តើមសន្តតិកម្ម

ទ្រព្យសម្បត្តិដែលមតកជនមាននៅពេលចាប់ផ្តើមសន្តតិកម្ម គឺទ្រព្យជាក់ស្តែងដែលបន្សល់ទុកដោយមតកជនក្រោយពេលទទួលមរណភាព។

**ឧទាហរណ៍៖** ទ្រព្យរបស់លោក ក រួមមាន ផ្ទះមួយល្វែង តម្លៃ ១០០០០០ ដុល្លារ ឡានមួយគ្រឿង តម្លៃ ៣០០០០ដុល្លារ លុយក្នុងធនាគារ១០០០០ដុល្លារ ក្នុងឆ្នាំចុងក្រោយដែលលោក ក ឈឺ គាត់បានលក់ឡានរបស់គាត់និងដកប្រាក់ពីធនាគារទាំងអស់មកព្យាបាលជម្ងឺក្រោយទទួលមរណភាពរបស់លោក ក នៅសល់តែផ្ទះមួយល្វែងតម្លៃ ១០០០០០ ដុល្លារតែប៉ុណ្ណោះ ដូច្នេះ ទ្រព្យជាក់ស្តែងក្រោយមរណភាពគឺផ្ទះមួយល្វែងតម្លៃ ១០០០០០ ដុល្លារ ដែលមូលដ្ឋានត្រូវយកមកគណនាភាគបម្រុង ។

## កថាខណ្ឌទី២ តម្លៃនៃផលប្រយោជន៍ពិសេស

តម្លៃនៃផលប្រយោជន៍ពិសេស គឺជាទ្រព្យដែលបុគ្គលសន្តតិជនបានទទួលជាប្រទានកម្ម នៅក្នុងឱកាសអាហ៍ពាហ៍ពិពាហ៍ ឬហេតុការផ្សេងទៀត ឬ ដើម្បីមូលធននៃជីវភាពរស់នៅ ឬ បានទទួលជាអច្ច័យទានពីមតកជន[18]។

**ឧទាហរណ៍៖** លោក ក និងអ្នកស្រី ខ បានទិញផ្ទះមួយល្វែងតម្លៃ ៨០០០០ដុល្លារ ឲ្យកូនស្រីទី២របស់គាត់ជាចំណងដៃអាពាហ៍ពិពាហ៍ ផ្ទះដែលមានតម្លៃ ៨០០០០ ដុល្លារ នេះគឺជាតម្លៃនៃផលប្រយោជន៍ពិសេស ដែលត្រូវយកមកធ្វើជា មូលដ្ឋានក្នុងការគណនាភាគបម្រុង ។

ចំណាំ៖ ប្រទានកម្មដែលធ្វើឲ្យទៅសន្តតិជនជាតម្លៃនៃផលប្រយោជន៍ពិសេស។

## កថាខណ្ឌទី៣ តម្លៃនៃប្រទានកម្ម[19]

ប្រទានកម្មគឺជាកិច្ចសន្យាដែលភាគីម្ខាងបង្ហាញឆន្ទៈផ្ដល់ឲ្យភាគីម្ខាងទៀត ឬទ្រព្យសម្បត្តិដោយមិនយកថ្លៃហើយភាគីម្ខាងទៀតយល់ព្រមទទួល ។

ប្រទានកម្មដែលត្រូវយកមកគណនាភាគបម្រុង ត្រូវអនុលោមតាមមាត្រា ១២៣២ ក្រមរដ្ឋប្បវេណីគឺជាប្រទានកម្ម ដែលធ្វើឡើងក្នុងអំឡុងពេល១ឆ្នាំ មុនពេលចាប់ផ្ដើមសន្តតិកម្មនិងប្រទានកម្មដែលបណ្ដាលឲ្យខូចខាតដល់អ្នកដែលមានសិទ្ធិលើភាគបម្រុង ៖

- ប្រទានកម្មដែលបានធ្វើក្នុងអំឡុងពេល ១ ឆ្នាំ មុនពេលចាប់ផ្ដើមសន្តតិកម្ម ៖ បានជាត្រូវធ្វើបែបនេះ ព្រោះជាគោលការណ៍ប្រទានកម្មដែលបានធ្វើក្នុងអំឡុងពេល ១ ឆ្នាំ មុនពេលចាប់ផ្ដើមសន្តតិកម្មជាកម្មវត្ថុក្នុងការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ។ កាលដែលបានកម្រិតអំឡុងពេលតែ ១ ឆ្នាំមុនពេលចាប់ផ្ដើមសន្តតិកម្មនេះ ក៏ព្រោះតែដើម្បីកុំឲ្យមានការបំពានភាពមិនត្រឹមត្រូវដល់ផលប្រយោជន៍អច្ច័យលាភី និងដើម្បីឲ្យមានសុវត្ថិភាពក្នុងកិច្ចការជំនួញ។

ឧទាហរណ៍៖ លោក ក បានឲ្យទៅក្មួយស្រីនូវ ម៉ូតូមួយគ្រឿង តម្លៃ ១៥០០ ដុល្លារ ជាការលើកទឹកចិត្តដល់នាងពេលដែលប្រឡងជាប់សញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ។ ម៉ូតូមួយគ្រឿងតម្លៃ ១៥០០ដុល្លារ ជាប្រទានកម្ម ។

---

[18] .ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១១៦៣។

[19] .ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៣២ ចំណុច ខ ។

- ប្រទានកម្មដែលបណ្ដាលឲ្យខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុង៖ ក្នុងករណីដែលភាគីទាំងសងខាងបានដឹងថាប្រទានកម្មនឹងបណ្ដាលឲ្យខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុងនោះ មិនចាំបាច់មានការកម្រិតនូវអំឡុងពេលឡើយ ពោលគឺគ្រប់ករណីទាំងអស់នេះ នឹងក្លាយជាកម្មវត្ថុនៃការកាត់បន្ថយនូវប្រទានកម្ម ។ ប៉ុន្តែប្រសិនបើប្រទានកម្មទាំងអស់នោះមិនមែនជាការបំពានទៅលើសិទ្ធិលើភាគបម្រុងនោះទេ សន្តតិជននឹងមិនអាចធ្វើការទាមទារបានឡើយ ។ ដើម្បីឲ្យដឹងថា មានការបំពាន ឬ គ្មានការបំពានទៅលើភាគបម្រុងនោះ គឺទាមទារឲ្យយើងធ្វើការប្រៀបធៀបទៅលើទ្រព្យសម្បត្តិសរុបដែលមតកជនមាន នៅពេលធ្វើប្រទានកម្ម និងតម្លៃទ្រព្យដែលបានធ្វើប្រទានកម្ម ។

**ឧទាហរណ៍៖** មតកជនមុនពេលស្លាប់បានប្រទានកម្មឲ្យបុគ្គលណាម្នាក់នូវចំនួនទឹកប្រាក់ ១០០០ដុល្លារ រីឯមតិកដែលបន្សល់ទុកមានចំនួន ៩០០០ ដុល្លារ ដែលត្រូវចែកឲ្យសន្តតិជនចំនួន ២ នាក់ ដូច្នេះ ក្នុងករណីនេះ គឺមិនមានការបំពានភាគបម្រុងនោះទេ ទោះបីជាមតិកធ្លាក់ចុះមកសល់ ត្រឹមតែ ៥០០០ ដុល្លារក៏ដោយ ក៏មិនមានការបំពានភាគបម្រុងនោះដែរ ។

### កថាខណ្ឌទី៤ ចំនួនទឹកប្រាក់នៃកាតព្វកិច្ច

ចំនួនទឹកប្រាក់នៃកាតព្វកិច្ចគឺជាចំណងតាមផ្លូវច្បាប់ដែលចងបុគ្គលពីរនាក់ ដោយឲ្យបុគ្គលម្នាក់ដែលបានកំណត់ហៅថាកូនបំណុលមានករណីកិច្ចមួយចំនួនចំពោះបុគ្គលម្ខាងទៀតដែលបានកំណត់ហៅថាម្ចាស់បំណុល។ **កាតព្វកិច្ចក្នុងករណីនេះជាកាតព្វកិច្ចដែលមតកជនត្រូវទទួលខុសត្រូវនៅពេលគាត់ស្លាប់ រួមទាំងចំណាយ សម្រាប់បុណ្យសព ។**

ឧទាហរណ៍៖ លោក ក ជាពាណិជ្ជករម្នាក់ដើម្បីពង្រីកមុខរបររបស់ខ្លួន លោក ក បានខ្ចីប្រាក់ពីលោក ខ ចំនួន ៥០០០០ដុល្លារ ដោយដាក់បញ្ចាំដីរបស់ខ្លួនមួយកន្លែង នៅខេត្តបន្ទាយមានជ័យ ជាការធានាបំណុល ។ ប្រាក់ ៥០០០០ដុល្លារជាកាតព្វកិច្ចដែលជាមូលដ្ឋានដែលត្រូវយកគណនាភាគបម្រុង ។

## ផ្នែកទី២ ការគណនា

ថាតើភាគបម្រុងត្រូវបានគណនាយ៉ាងដូចម្ដេច?

បន្ទាប់ពីបានសិក្សា ស្វែងយល់អំពីទ្រព្យដែលត្រូវយកជាមូលដ្ឋានក្នុងការគណនាភាគបម្រុងហើយនោះ យើងនឹងធ្វើការបង្ហាញអំពីវិធីគណនាវិញម្ដង ថា តើត្រូវគណនាតាមរូបមន្តណាដែរ ?

(កថាខណ្ឌទី១)គួរកត់សំគាល់ដែរថា វិធីគណនាខាងលើដើម្បីរកទឹកប្រាក់ដែលមានសិទ្ធិលើភាគបម្រុង អាចទាមទារបាននោះ នឹងមានការប្រែប្រួលកដោយសារមូលហេតុ ឬ ស្ថានភាពមួយចំនួននាំឲ្យទឹកប្រាក់ដែលទាមទារបានពីការគណនានោះ ត្រូវបានពីការកាត់បន្ថយ ហេតុនេះ ហើយយើងចាត់ទុកថា ជាចំនួនទឹកប្រាក់នៃការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង (កថាខណ្ឌទី២)។

### កថាខណ្ឌទី១ រូបមន្តក្នុងការគណនា

រូបមន្តក្នុងការគណនាភាគបម្រុង៖

ដើម្បីអាចគណនាភាគបម្រុងបានជាដំបូងយើងត្រូវរក ទ្រព្យសម្បត្តិដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុងសិន[20]។

ដោយយើងត្រូវយក

| |
|---|
| ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុងស្មើ (ទ្រព្យសម្បត្តិពេលចាប់ផ្តើមសន្តតិកម្ម បូកផលប្រយោជន៍ពិសេស បូកនឹងតម្លៃនៃប្រទានកម្ម) ដកកាតព្វកិច្ច |

បន្ទាប់មកយើងត្រូវយកទ្រព្យសម្បត្តិដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុងនេះ ទៅចែកនឹងចំណែកនៃភាគបម្រុងដែលច្បាប់បានកំណត់[21] រួចចែកនឹងចំនួនសន្តតិជន ។

$$\text{ភាគបម្រុងស្មើ} \quad \frac{\text{ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង}}{\dfrac{\text{ចំណែកនៃភាគបម្រុង}}{\text{ចំនួនសន្តតិជន}}}$$

[20] .ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៣១ ។

[21] .ចំណែកនៃភាគបម្រុងនេះ ស្មើនឹង១ភាគ២ ក្នុងករណីដែលមានបច្ឆាញាតិ ឬនិងសហព័ទ្ធជាអ្នកមានសិទ្ធិលើភាគបម្រុង ប្រសិនបើឪពុកម្តាយ ឬជីដូនជីតាជាអ្នកមានសិទ្ធិលើភាគបម្រុងនោះចំណែកនៃភាគបម្រុងគឺស្មើនឹង ១ភាគ ៣។ សូមមើលសេចក្តីពន្យល់លំអិតក្នុងផ្នែកទី២ដែលស្តីអំពី អ្នកមានសិទ្ធិលើភាគបម្រុងនឹងចំណែកមតិកនៃភាគបម្រុង ។

**ឧទាហរណ៍** មតកជនមានកូនបីនាក់ គឺ ក ខ និង គ ដោយមតកជនបានបន្សល់ទុកទ្រព្យសម្បត្តិចំនួន ៣០០០ ដុល្លារ ដោយប្រគល់ទៅឲ្យ ខ ទាំងអស់ ។ ហើយនៅពេលដែលមតកជននៅរស់បានធ្វើប្រទានកម្ម ក ចំនួន ១០០០ដុល្លារ (ផលប្រយោជន៍ពិសេស) និងបានធ្វើប្រទានកម្មទៅឲ្យមិត្តរបស់គាត់ចំនួន ២០០០ដុល្លារ ។ ថា តើភាគបម្រុងរបស់សន្តតិជនម្នាក់ មានប៉ុន្មាន?

ការគណនា

រកទ្រព្យជាមូលដ្ឋានក្នុងការគណនាភាគបម្រុង

- ដោយទ្រព្យដែលមាននៅពេលចាប់ផ្តើមគឺ ៣០០០ ដុល្លារ
- ផលប្រយោជន៍ពិសេសគឺ១០០០ដុល្លារ
- ប្រទានកម្មគឺ ២០០០
- កាតព្វកិច្ច គឺ 0

តាមរូបមន្ត នាំឲ្យទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង = (៣០០០ + ១០០០ + ២០០០) - 0 = ៦០០០ ដុល្លារ

រកភាគបម្រុងរបស់សន្តតិជនម្នាក់ៗ

តាមរូបមន្ត

ទ្រព្យសម្បត្តិដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុងនេះ ÷ ចំណែកនៃភាគបម្រុងដែលច្បាប់បានកំណត់ ÷ ចំនួនសន្តតិជន

ដោយ

៦០០០ដុល្លារ ជាទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង

២ ជាចំណែកភាគបម្រុងដែលច្បាប់បានកំណត់ (១ភាគ២នៃទ្រព្យរបស់មតកជន)

៣នាក់ ជាចំនួនសន្តតិជន

ដូចច្នេះនាំឲ្យ ភាគបម្រុងរបស់សន្តតិជនម្នាក់ៗ ស្មើនឹង

៦០០០ ÷ ២ = ៣០០០ ជាចំណែកភាគម្រុងសរុប

ដោយសន្តតិជនមាន៣នាក់ ដូចច្នេះត្រូវចែកនឹងចំនួនសន្តតិជនតទៀត

៣០០០ ÷៣ = ១០០០ ដុល្លារ ។

ដូចច្នេះភាគបម្រុងរបស់សន្តតិជនម្នាក់គឺស្មើនឹង ១០០០ដុល្លារ។

តាមរយៈការសិក្សាទៅលើឧទាហរណ៍ខាងលើ គឺមានតែសន្តតិជន គ ដែលត្រូវបានបំពានភាគបម្រុង។ ហើយចំនួនទឹកប្រាក់នេះ គឺ គ អាចធ្វើការទាមទារបានទាំងអស់តែម្តង ។

**ឧទាហរណ៍** មតកជនមាន ៣ នាក់ ដែល ក គឺជាសហព័ទ្ធ រីឯ ខ និង គ គឺជាឪពុកម្តាយរបស់មតកជន ដោយមតកជនបានបន្សល់ទុកទ្រព្យសម្បត្តិចំនួន ៣០០០ ដុល្លារ ដោយប្រគល់ទៅ ក ទាំងអស់ ។ ហើយនៅពេលដែលមតកជននៅរស់បានធ្វើប្រទានកម្ម ទៅឲ្យ ក ចំនួន ១០០០ ដុល្លារ( ផលប្រយោជន៍ពិសេស) និងបានធ្វើប្រទានកម្មទៅឲ្យ មិត្តរបស់គាត់ចំនួន ២០០០ ដុល្លារ ។ ចំណែក ខ និង គ ដែលជាឪពុកម្តាយមិនទទួលបានអ្វីទាំងអស់ ដូច្នេះ ការបំពានភាគបម្រុងគឺត្រូវបានកើតឡើងទោះជា ខ និង គ ជាសន្តតិជនដែរក៏ដោយ ។ ថាតើភាគបម្រុងរបស់សន្តតិជនម្នាក់មានប៉ុន្មានដែលត្រូវបានគេបំពានបែបនេះ ?

**ការគណនា**

រកទ្រព្យជាមូលដ្ឋានក្នុងការគណនាភាគបម្រុង

៣០០០ដុល្លារ ជាទ្រព្យមានពេលចាប់ផ្តើមសន្តតិកម្ម

១០០០ដុល្លារជាផលប្រយោជន៍ពិសេស

២០០០ដុល្លារ ជាប្រទានកម្ម

0 ជាចំនួនទឹកប្រាក់នៃកាតព្វកិច្ច

ដូចច្នេះនាំឲ្យ

(៣០០០ + ១០០០ + ២០០០) - 0 = ៦០០០ ដុល្លារ

ដូច្នេះ ភាគបម្រុងរបស់សន្តតិជនម្នាក់ៗ ស្មើនិង ៦០០០ ÷២=៣០០០ដុល្លារ

៣០០០÷ ៣ =១០០០ ដុល្លារ ។

បើយើងធ្វើការសិក្សាទៅលើឧទាហរណ៍ខាងលើគឺមានតែសន្តតិជន ខ និង គ ដែលត្រូវបានបំពានភាគបម្រុង ។ ហើយចំនួនទឹកប្រាក់នេះ គឺ ខ និង គ បានម្នាក់គឺ ១០០០ ដែលជាការទាមទារនេះអាចធ្វើការទាមទារ ទាំងអស់តែម្តង ។

## កថាខណ្ឌទី២ ចំនួនទឹកប្រាក់ដែលត្រូវកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

នៅពេលខ្លះ ដោយសារតែមានមូលហេតុមួយចំនួនទើបធ្វើឲ្យអ្នកមានសិទ្ធិលើភាគបម្រុងអាចទាមទារទឹកប្រាក់ដើម្បីបង្គ្រប់ភាគបម្រុងតែប៉ុណ្ណោះ ។ វាគ្មានអ្វីចម្លែកទេ ត្រង់ថា ហេតុអ្វីបានជា អ្នកមានសិទ្ធិភាគបម្រុងអាចទាមទារត្រឹមតែទឹកប្រាក់បង្គ្រប់នោះ ។ វាមានន័យថា មុនពេលដែល អ្នកមានសិទ្ធិលើភាគបម្រុង ទាមទារចំណែកមតិកដែលជាភាគបម្រុងនោះ បុគ្គលនោះ អាចរងនូវ ស្ថានភាពអ្វីមួយដែលជាមូលហេតុនាំឲ្យត្រូវកាត់បន្ថយនូវចំណែកទាមទារដូច្នេះ ។ ហេតុនេះហើយ នាំឲ្យអ្នកមានសិទ្ធិលើភាគបម្រុងត្រូវការតែមួយភាគទៀតប៉ុណ្ណោះ ដើម្បីបង្គ្រប់ចំនួនដែលនៅសល់ ។ ដូចនេះ តើចំនួនទឹកប្រាក់នៃការទាមទារដើម្បីបង្គ្រប់ភាគបម្រុង ត្រូវគណនាដោយយោងលើ រូបមន្ត អ្វី? (ក) ហើយមានហេតុអ្វីខ្លះដែលនាំឲ្យគណនារកចំនួនទឹកប្រាក់បង្គ្រប់ភាគបម្រុង (ខ) ?

### ក.រូបមន្ត

ចំនួនទឹកប្រាក់ដែលសន្តតិជនមានសិទ្ធិលើភាគបម្រុងអាចទាមទារបានដោយការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងគឺជាចំនួនទឹកប្រាក់ ដែលត្រូវបានគណនាដោយយកចំនួនទឹកប្រាក់នៃភាគបម្រុងដកទ្រព្យដែលអ្នកមានសិទ្ធិលើភាគបម្រុងបានទទួលដោយសន្តតិកម្ម និងចំនួននៃផលប្រយោជន៍ពិសេសហើយបូកបញ្ចូលនូវទឹកប្រាក់កាតព្វកិច្ចដែលបុគ្គលនោះ ត្រូវទទួលបន្ទុកដោយសន្តតិកម្ម ។

អាចសរសេរបានជារូបមន្តដូចខាងក្រោម ៖

| |
|---|
| ចំនួនទឹកប្រាក់នៃការទាមទារដើម្បីបង្គ្រប់ភាគបម្រុងស្មើ ចំនួនទឹកប្រាក់ភាគបម្រុង ដែលត្រូវបានគណនាដកទ្រព្យដែលអ្នកមានសិទ្ធិលើភាគបម្រុងបានទទួលដោយសន្តតិកម្ម ដកនឹងផលប្រយោជន៍ពិសេសរបស់អ្នកមានសិទ្ធិលើភាគបម្រុង បូកនឹងកាតព្វកិច្ចដែលអ្នកមានសិទ្ធិលើភាគបម្រុងត្រូវទទួលបន្ទុកដោយសន្តតិកម្ម |

### ខ.មូលហេតុដែលនាំឲ្យមានការគណនារកចំនួនទឹកប្រាក់ដើម្បីបង្គ្រប់ភាគបម្រុង

មានកត្តាជាច្រើន ដែលធ្វើឲ្យចំនួនទឹកប្រាក់នៃភាគបម្រុងត្រូវបានកាត់បន្ថយ ដោយសារក្នុងនោះអ្នកមានសិទ្ធិលើភាគបម្រុង បានទទួលផលប្រយោជន៍ពិសេស (១) ឬ មួយក៏ អ្នកមានសិទ្ធិលើភាគបម្រុង អាចទទួលបានទ្រព្យសម្បត្តិដោយសន្តតិកម្ម (២) ប៉ុន្តែ តាមរយៈការទទួលនូវ

ទ្រព្យ សម្បត្តិតាមស្ថានភាពទាំងនោះ នូវតែអាចមានការបំពាននូវចំណែកមតិក ហេតុនេះ ហើយទើបអ្នកមានសិទ្ធិលើភាគបម្រុងអាចទទួលបានចំណែកដែលនៅសល់ ក្រោយពីការដកនូវទ្រព្យទាំងអស់ នោះចេញ ។ ផ្ទុយទៅវិញ ចំនួនទឹកប្រាក់នៃការទាមទារដើម្បីបង្គ្រប់ភាគបម្រុងអាចនឹងមានការ កើនឡើងទៅវិញ ដោយសារតែមតកជនបានបន្សល់ទុកនូវកាតព្វកិច្ច ដែលជាហេតុនាំឲ្យចំនួនទឹកប្រាក់ភាគបម្រុងត្រូវបូកបន្ថែម នូវកាតព្វកិច្ចនេះ (៣) ។

**១.ផលប្រយោជន៍ពិសេសរបស់អ្នកមានសិទ្ធិលើភាគបម្រុង**

ក្នុងករណីខ្លះ ដោយសារអ្នកមានសិទ្ធិលើភាគបម្រុង បានទទួលផលប្រយោជន៍ពិសេស ហេតុនេះហើយ ការគណនារកភាគបម្រុងតែម្យ៉ាងគឺពុំគ្រប់គ្រាន់ទេ ។ វាទាមទារឲ្យមានការគណនារកទឹកប្រាក់បង្គ្រប់បន្ថែមទៀត ពីព្រោះផលប្រយោជន៍ពិសេសនេះ ត្រូវយកមកធ្វើជាមូលដ្ឋានក្នុងការគណនាភាគបម្រុងដែរ ។ គួរកត់សម្គាល់ថា ផលប្រយោជន៍ពិសេសនេះ ត្រូវតែជារបស់អ្នកមានសិទ្ធិលើភាគបម្រុង ពីព្រោះអ្នកមានសិទ្ធិលើភាគបម្រុងជាអ្នកធ្វើការទាមទារ ។

ប្រសិនបើ វាជាផលប្រយោជន៍ពិសេសរបស់សន្តតិជនធម្មតា ដែលគ្មានសិទ្ធិលើភាគបម្រុងទេនោះ មិនចាំបាច់គណនារកទឹកប្រាក់បង្គ្រប់បន្ថែមទេ ។ ចុះហេតុអ្វីបានជា អ្នកមានសិទ្ធិលើភាគបម្រុងបានទទួលផលប្រយោជន៍ពិសេស ហើយនៅតែមានការបំពានលើចំណែកមតិក ? ទាក់ទងនឹងករណីនេះ អាចដោយសារផលប្រយោជន៍ពិសេសដែលទទួលបានមានចំនួនតិចតួចពេកដែលជាហេតុនាំឲ្យទ្រព្យសម្បត្តិ ដែលទទួលបាននៅតែមិនអាចមានចំនួនសមាមាត្រទៅនឹងភាគបម្រុង ។

**ឧទាហរណ៍** សន្តតិជនមាន ២ នាក់ គឺ ក និង ខ ដែលជាកូនរបស់មតកជន ។ កាលមតកជននៅរស់បានធ្វើប្រទានកម្ម (ផលប្រយោជន៍ពិសេស) ទៅឲ្យ ខ ចំនួន ១០០០ ដុល្លារ ។ ចំណែកទ្រព្យសម្បត្តិ ពេលចាប់ផ្តើមសន្តតិកម្មមាន ១០០០០ ដុល្លារ ។ ហើយមតកជន បានធ្វើមតកសាសន៍ដោយផ្ទេរទ្រព្យសម្បត្តិទាំងអស់ឲ្យទៅកូន ក ។ ដែលជាហេតុធ្វើឲ្យ ខ មិនបានទទួលនូវទ្រព្យសម្បត្តិអ្វីសោះ ទើប ខ ដាក់ពាក្យបណ្តឹងបង្ហាញឆន្ទៈ ទាមទារចំនួនទឹកប្រាក់បង្គ្រប់ភាគបម្រុងរបស់ខ្លួនពី ក ។

ដំណោះស្រាយ តាមរូបមន្តដូចខាងក្រោម

| |
|---|
| ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនា ភាគបម្រុងស្មើ ទ្រព្យសម្បត្តិពេលចាប់ផ្តើមសន្តតិកម្ម បូកនឹងផលប្រយោជន៍ពិសេស បូកនឹងប្រទានកម្ម ដកនឹងកាតព្វកិច្ច |

នាំឲ្យទ្រព្យដែលជាមូលដ្ឋានក្នុងគណនាភាគបម្រុង = (១០០០០+១០០០+0)-0 =១១០០០ ដុល្លារ

- ដោយភាគបម្រុងស្មើ១/២(១ ភាគ ២) នៃទ្រព្យសម្បត្តិរបស់មតកជន

ដូចនេះភាគបម្រុងដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង × ១/២ នៃទ្រព្យសម្បត្តិរបស់មតកជន

ភាគបម្រុង = ១១០០០ × ១ភាគ២= ៥៥០០ដុល្លារ

- ដោយសន្តតិជនមានគ្នា២នាក់ទើបភាគបម្រុងត្រូវធ្វើការបែងចែកជា ២ ទៀតគឺ

ទ្រព្យសម្បត្តិដែលជាភាគបម្រុងសម្រាប់ម្នាក់ៗគឺ= ៥៥០០÷ ២= ២៧៥០ដុល្លារ

ក្នុងករណីនេះ ខ មានសិទ្ធិលើភាគបម្រុងចំនួន២៧៥០ដុល្លារ ដែលចំនួននេះ ខ មិនអាចទាមទារបានទាំងអស់តែម្តងពី ក បានទេ ពីព្រោះ ខ បានទទួលផលប្រយោជន៍ពិសេស។ ហេតុនេះហើយចាំបាច់គណនារកទឹកប្រាក់ដើម្បីបង្គ្រប់ ភាគបម្រុងទៀត

តាមរូបមន្ត

> ចំនួនទឹកប្រាក់នៃការទាមទារដើម្បីបង្គ្រប់ភាគបម្រុង ស្មើនឹងចំនួនទឹកប្រាក់ភាគបម្រុងដែលត្រូវគណនា ដកនឹងទ្រព្យដែលអ្នកមានសិទ្ធិលើភាគបម្រុងបានទទួល ដោយសន្តតិកម្មដកនឹងផលប្រយោជន៍ពិសេសរបស់អ្នកមានសិទ្ធិលើភាគបម្រុង បូកនឹងកាតព្វកិច្ច ដែលអ្នកមានសិទ្ធិលើភាគបម្រុងត្រូវទទួលបន្ទុកដោយសន្តតិកម្ម

- ដោយចំនួនទឹកប្រាក់ភាគបម្រុងដែលត្រូវបានគណនា = ២៧៥០ ដុល្លារ
- ខ ជាអ្នកមានសិទ្ធិលើភាគបម្រុងហើយបានទទួលផលប្រយោជន៍ពិសេស=១០០០ ដុល្លារ

  ចំនួនទឹកប្រាក់នៃការទាមទារដើម្បីបង្គ្រប់ភាគបម្រុង = (២៧៥ -0-១០០០ ) + 0 = ១៧៥០ ដុល្លារ

  ដូចនេះ ខ អាចទាមទារចំនួនទឹកប្រាក់ដើម្បីបង្គ្រប់ភាគបម្រុង = ១៧៥០ ដុល្លារ ពី ក ។

## ២.ទ្រព្យសម្បត្តិរបស់អ្នកមានសិទ្ធិលើភាគបម្រុង បានទទួលដោយសន្តតិកម្ម

ចំពោះករណីនេះវិញ វាមិនខុសគ្នាប៉ុន្មានទៅនឹងផលប្រយោជន៍ដែលអ្នកមានសិទ្ធិលើភាគបម្រុងបានទទួលនោះទេ ។ បើទោះបីជាសន្តតិជន ដែលមានសិទ្ធិលើភាគបម្រុងបានទទួលទ្រព្យសម្បត្តិដោយសន្តតិកម្ម (ទាំងតាមច្បាប់និងតាមមតកសាសន៍) ក៏ដោយក៏

នៅពេលខ្លះការទទួលបាននូវចំណែកមតិករបស់ខ្លួននោះ គឺវានៅតែមានការបំពាន ។ ប៉ុន្តែ ដោយសារតែសន្តតិជននោះបានទទួលទ្រព្យសម្បត្តិមួយភាគដែរ ហេតុនេះហើយ ទើប យើងត្រូវធ្វើការគណនារកចំនួនទឹកប្រាក់ដើម្បីបង្គ្រប់ភាគបម្រុងដែលនៅសេសសល់ ។ **ឧទាហរណ៍** មតកជនមានប្រពន្ធ ក និងកូន ២នាក់ គឺ ខ និង គ ដោយបន្សល់ទុកនូវទ្រព្យ សម្បត្តិ ចំនួន ៦០០០ ដុល្លារ ។ មុនពេលទទួលមរណភាព មតកជនបានធ្វើមតកសាសន៍ ដោយ ធ្វើការបែងចែកទ្រព្យសម្បត្តិ ដូចខាងក្រោម៖

- ឲ្យប្រពន្ធ ក ចំនួន ៥០០០ ដុល្លារ
- ឲ្យកូន ខ និងគ ក្នុងម្នាក់ៗ ចំនួន ៥០០ ដុល្លារ ។

កូន ខ និង គ បានធ្វើការទាមទារនូវទឹកប្រាក់បង្គ្រប់ភាគបម្រុងរបស់ខ្លួនពី ក ។

ដំណោះស្រាយ

| |
|---|
| ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុងស្មើទ្រព្យសម្បត្តិពេលចាប់ផ្តើម សន្តតិកម្ម បូកនឹងផលប្រយោជន៍ពិសេសបូកនឹងប្រទានកម្ម ដកនឹងកាតព្វកិច្ច |

នាំឲ្យទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង=(៦០០០+0+0)-0=៦០០០ ដុល្លារ

- ➢ ដោយភាគបម្រុងស្មើ ១/២នៃទ្រព្យសម្បត្តិរបស់មតកជន

ដូចនេះ ភាគបម្រុង=ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង ×១/២ នៃ ទ្រព្យសម្បត្តិរបស់មតកជន

ភាគបម្រុង = ៦០០០ × ១/២ = ៣០០០ដុល្លារ

- ➢ ដោយសន្តតិជនមានគ្នាបីនាក់ ទើបភាគបម្រុងត្រូវធ្វើការបែងចែកជា ៣ ទៀតគឺ ទ្រព្យសម្បត្តិដែលជាភាគបម្រុងសម្រាប់ម្នាក់ៗ គឺ = ភាគបម្រុង ÷ ចំនួនសន្តតិជន នាំឲ្យ

៣០០០ ÷៣= ១០០០ដុល្លារ

ជាក់ស្តែង កូន ខ និង គ បានទទួលចំណែកមតិកក្នុងម្នាក់ តែ ៥០០ ដុល្លារ ប៉ុណ្ណោះ មានន័យថា ក បានបំពានចំណែកលើភាគបម្រុងរបស់ពួកគេ ។ ក៏ប៉ុន្តែទ្រព្យសម្បត្តិដែល ជាភាគបម្រុងសម្រាប់ម្នាក់ៗ ដែលបានគណនាឃើញនោះ ចំនួន ១០០០ ដុល្លារ គឺមិនអាច ទាមទារ បានទាំងស្រុងទេ ដោយសារតែ ខ និង គ បានទទួលចំណែកទ្រព្យសម្បត្តិ ដោយ

សន្តតិកម្មដែរ ទើបពួកគេអាចទាមទារត្រឹមតែទឹកប្រាក់ដើម្បីបង្គ្រប់ភាគបម្រុងដោយគណនាដូចខាងក្រោម ៖

| |
|---|
| ចំនួនទឹកប្រាក់នៃការទាមទារដើម្បីបង្គ្រប់ភាគបម្រុង ស្មើនឹងចំនួនទឹកប្រាក់ភាគបម្រុងដែលត្រូវបានគណនា ដកទ្រព្យដែលអ្នកមានសិទ្ធិលើភាគបម្រុងបានទទួលដោយសន្តតិកម្មដកនឹងផលប្រយោជន៍ពិសេសរបស់អ្នកមានសិទ្ធិលើភាគបម្រុង បូកកាតព្វកិច្ច |

- ដោយចំនួនទឹកប្រាក់ភាគបម្រុងដែលត្រូវបានគណនា = ១000 ដុល្លារ
- ទ្រព្យដែលអ្នកមានសិទ្ធិលើភាគបម្រុងបាន ទទួលដោយសន្តតិកម្ម ខ = គ = ៥00 ដុល្លារ

  ចំនួនទឹកប្រាក់នៃការទាមទារដើម្បីបង្គ្រប់ភាគបម្រុងរបស់ ខ = (១000-៥00-0)+0 = ៥00 ដុល្លារ

  ចំណែក គ = (១000-៥00-0)+0 = ៥00 ដុល្លារ

  ដូចនេះ ខ និង គ អាចទាមទារទឹកប្រាក់ដើម្បីបង្គ្រប់ភាគបម្រុងចំនួនក្នុងម្នាក់ ៗ ៥00 ដុល្លារ ពី ក ។

**៣. កាតព្វកិច្ចដែលអ្នកមានសិទ្ធិលើភាគបម្រុង ត្រូវទទួលបន្ទុកដោយសន្តតិកម្ម**

ពាក់ព័ន្ធទៅនឹងកាតព្វកិច្ច ដែលសន្តតិជនមានសិទ្ធិលើភាគបម្រុងត្រូវទទួលបន្ទុកតាមរយៈសន្តតិកម្ម នាំឲ្យទឹកប្រាក់នៃភាគបម្រុងមានការកើនឡើង នៅពេលដែលធ្វើការគណនារកប្រាក់បង្គ្រប់ ព្រោះដោយសារតែទឹកប្រាក់បង្គ្រប់នេះ ត្រូវបូកបន្ថែមជាមួយកាតព្វកិច្ច ដែលសន្តតិជនត្រូវទទួលបន្ទុក ។ ជាក់ស្តែងសន្តតិជន មិនមែនទទួលតែទ្រព្យសកម្មតែប៉ុណ្ណោះទេ ប៉ុន្តែត្រូវទទួលបន្ទុកសងបំណុលរបស់មតកជនផងដែរ ។

**ឧទាហរណ៍** មតកជនមានកូន ២ នាក់ គឺ លោក សុខ និង សៅ ដោយទ្រព្យសម្បត្តិពេលចាប់ផ្តើម សន្តតិកម្ម មានចំនួន ៨000 ដុល្លារ និងកាតព្វកិច្ចចំនួន ៤000 ដុល្លារ ។ (មតកជនមិន បានបន្សល់ទុកមតកសាសន៍ទេ) ប៉ុន្តែមុនពេលចាប់ផ្តើមសន្តតិកម្ម លោក សុខ បានទទួល ប្រទានកម្ម ចំនួន ១៥000 ដុល្លារ (ផលប្រយោជន៍ពិសេស) ។ លោក សៅ បានធ្វើការទាមទារនូវទឹកប្រាក់បង្គ្រប់ភាគបម្រុងរបស់ខ្លួនពី លោកសុខ ។

**ដំណោះស្រាយ**

រកទ្រព្យជាមូលដ្ឋានក្នុងការគណនាភាគបម្រុង

| |
|---|
| ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង ស្មើទ្រព្យសម្បត្តិពេលចាប់ផ្តើមសន្តតិកម្ម បូកផលប្រយោជន៍ពិសេស បូកនឹងប្រទានកម្ម ដកនឹងកាតព្វកិច្ច |

នាំឲ្យ ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនា = (៨០០០+១៥០០០+០)-៤០០០= ១៩០០០ ដុល្លារ

➢ ដោយភាគបម្រុងស្មើ ១ ភាគ ២នៃទ្រព្យសម្បត្តិរបស់មតកជន

ដូចនេះ ភាគបម្រុង = ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនា ភាគបម្រុង ÷ ១ភាគ២ នៃ ទ្រព្យសម្បត្តិរបស់មតកជន

ភាគបម្រុង= ១៩០០០ ÷ ១ភាគ២ = ៩៥០០ដុល្លារ

➢ ដោយសន្តតិជនមានគ្នា ២ នាក់ ទើបភាគបម្រុងត្រូវធ្វើការបែងចែកជា ២ ទៀត គឺ

ទ្រព្យសម្បត្តិដែលជាភាគបម្រុងសម្រាប់ម្នាក់ៗ = ៩៥០០÷ ២ = ៤៧៥០ ដុល្លារ

ក្នុងករណីនេះ សៅ មានសិទ្ធិលើភាគបម្រុងចំនួន ៤៧៥០ ដុល្លារ ដែលចំនួននេះ សៅមិនអាចទាមទារបានទាំងអស់ពី សៅបានទេ ពីព្រោះ សុខ បានទទួលចំណែកទ្រព្យសម្បត្តិដោយសន្តតិកម្ម ហើយមតកជនបានបន្សល់ទុកនូវកាតព្វកិច្ចទៀតផង ។ ហេតុនេះ ហើយ ចាំបាច់គណនារកទឹកប្រាក់ដើម្បីបង្គ្រប់ភាគបម្រុងទៀត ៖

| |
|---|
| ចំនួនទឹកប្រាក់នៃការទាមទារដើម្បីបង្គ្រប់ភាគបម្រុង ស្មើចំនួនទឹកប្រាក់ភាគបម្រុងដែលត្រូវបានគណនា ដកទ្រព្យដែលអ្នកមានសិទ្ធិលើភាគបម្រុងបានទទួលដោយសន្តតិកម្ម ដកនឹងផលប្រយោជន៍ពិសេសរបស់អ្នកមានសិទ្ធិលើភាគបម្រុង បូកនឹងកាតព្វកិច្ចដែលអ្នកមានសិទ្ធិលើភាគបម្រុងត្រូវទទួលបន្ទុកដោយសន្តតិកម្ម |

➢ ចំនួនទឹកប្រាក់ភាគបម្រុងដែលត្រូវបានគណនា = ៤៧៥០ ដុល្លារ

➢ ទ្រព្យដែលអ្នកមានសិទ្ធិលើភាគបម្រុងបានទទួលដោយសន្តតិកម្ម ៖ ដោយសារតែមតកជនមិនបានបន្សល់ទុកមតកសាសន៍ទេ ហេតុនេះហើយ ទ្រព្យសម្បត្តិត្រូវបែងចែកតាមសន្តតិកម្មតាមច្បាប់ នាំឲ្យសន្តតិជនម្នាក់ៗ ទទួលបានចំណែកស្មើៗគ្នា

= ៨០០០÷ ២ = ៤០០០ ដុល្លារ

- ផលប្រយោជន៍ពិសេសរបស់អ្នកមានសិទ្ធិលើភាគបម្រុង(គ្មាន[22])។
- កាតព្វកិច្ចដែលអ្នកមានសិទ្ធិលើភាគបម្រុងត្រូវទទួលបន្ទុកដោយសន្តតិកម្ម = ៤០០០÷២ = ២០០០ ដុល្លារ

  នាំឲ្យ ចំនួនទឹកប្រាក់នៃការទាមទារដើម្បីបង្គ្រប់ភាគបម្រុងរបស់ សៅ = ៤៧៥០ – ៤០០០ –០ + ២០០០ = ២៧៥០ដុល្លារ ។

  ដូចនេះ សៅ អាចធ្វើការទាមទារទឹកប្រាក់ដើម្បីបង្គ្រប់ភាគបម្រុងរបស់ខ្លួនពី សុខ ចំនួន ២៧៥០ដុល្លារ ដោយចំនួននេះត្រូវបានត្រូវបានទូទាត់កាតព្វកិច្ចរួចរាល់ហើយ។

[22] សុខមិនមែនជាអ្នកមានសិទ្ធិលើភាគបម្រុងទេពីព្រោះ សុខ មិនរងនូវការបំពានចំណែកមត៌ក ដូចនេះ ផលប្រយោជន៍ពិសេសដែល សុខ ទទួលមិនអាចចាត់ទុកជារបស់អ្នកមានសិទ្ធិលើភាគបម្រុងទេ ។ ចំណែក សៅ ជាសន្តិជនដែលមានសិទ្ធិលើភាគបម្រុង ។ ប៉ុន្តែ សៅ មិនបានទទួលផលប្រយោជន៍ពិសេសទេ ។

# ជំពូកទី៣
# វិធីកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង
# និងការរលត់សិទ្ធិទាមទារដើម្បីឲ្យកាត់បន្ថយ

ជាការពិតណាស់ថា ភាគបម្រុងគឺមិនមែនចេះតែធ្វើការទាមទារ ដោយមិនបានកំណត់អំពីនីតិវិធីក្នុងការទាមទារនោះទេ គឺមានន័យថា ក្នុងការទាមទារភាគបម្រុងត្រូវធ្វើទៅតាមបញ្ញត្តិដែលកំណត់ដោយច្បាប់ ។ ការធ្វើបែបនេះ វានឹងផ្តល់ភាពយុត្តិធម៌ សម្រាប់អ្នកមានសិទ្ធិទាមទារ និងអ្នកដែលត្រូវបានគេទាមទារ ។ ដូចដែលយើងដឹងហើយការកាត់បន្ថយភាគបម្រុងគឺជាការទាមទារនូវចំណែកមតិករបស់បុគ្គលម្នាក់ឬច្រើននាក់ដែលបុគ្គលទាំងនោះ បានទទួលពីមតកជនមុនពេលស្លាប់ ឬក្រោយពេលស្លាប់ តាមរយៈទម្រង់ ឬកម្មវត្ថុផ្សេងៗគ្នា ដែលជាហេតុនាំឲ្យបំពានទៅលើសិទ្ធិអ្នកដែលមានសិទ្ធិទៅលើភាគបម្រុង ដូច្នេះ ដើម្បីធ្វើការទាមទារឲ្យកាត់បន្ថយភាគបម្រុងបាននោះ គឺទាមទារឲ្យយើងសិក្សាលើលំដាប់នៃកម្មវត្ថុ (ផ្នែកទី១) ដែលនឹងត្រូវធ្វើការកាត់បន្ថយ នឹងអំពីវិធីផ្តល់សំណង ចំពោះការបង្គ្រប់ភាគបម្រុង (ផ្នែកទី២) ។ ទាក់ទងទៅនឹងបញ្ហានៃការផ្តល់សំណងនេះ មិនមែនប្រាកដថា អ្នកមានសិទ្ធិលើភាគបម្រុងអាចនឹងទាមទារភាគបម្រុងបានគ្រប់ពេលវេលានោះទេ ដោយសិទ្ធិទាមទារ នេះក៏នឹងត្រូវរលត់ដោយអាជ្ញាយុកាលផងដែរ (ផ្នែកទី៣) ។

## ផ្នែកទី១ លំដាប់នៃកម្មវត្ថុដែលត្រូវធ្វើការកាត់បន្ថយ

អ្នកមានសិទ្ធិលើភាគបម្រុង និងអ្នកទទួលបន្តអាចទាមទារឲ្យធ្វើការកាត់បន្ថយអច្ច័យទានដែលទទួលបាននូវទ្រព្យសម្បត្តិ ឬ ផលប្រយោជន៍ពិសេស ដែលជាកម្មវត្ថុនៃការកាត់បន្ថយ ដើម្បីបង្គ្រប់ភាគបម្រុងបានត្រឹមកម្រិតចាំបាច់ដើម្បីរក្សាភាគបម្រុងនោះប៉ុណ្ណោះ[23]។

សិទ្ធិក្នុងការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងនេះ គឺជា "សិទ្ធិបង្កើតទំនាក់ទំនងគតិយុត្ត" ដូច្នេះអច្ច័យទាន ឬប្រទានកម្មត្រូវបាត់បង់អនុភាពដោយស្វ័យប្រវត្តក្នុងកម្រិត ដែលបានបំពានភាគបម្រុងនោះ ក្នុងករណីដែលអ្នកមានសិទ្ធិលើភាគបម្រុងបានអនុវត្តសិទ្ធិរបស់ខ្លួន។

ការកំណត់បែបនេះគឺដើម្បីទុកសិទ្ធិឲ្យជនដែលត្រូវបានបំពានភាគបម្រុងអាចយកសិទ្ធិដែលជាកម្មវត្ថុនៃការកាត់បន្ថយនោះមកធ្វើជារបស់ខ្លួនបាន ដោយធ្វើការទាមទារ ឲ្យកាត់បន្ថយពីអច្ច័យទាន។

[23] .ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៣៥។

ទោះបីជាយ៉ាងណាក៏ដោយ ក៏ច្បាប់មិនបានចាប់បង្ខំដែរប្រសិនបើអ្នកដែលមានសិទ្ធិលើភាគបម្រុងនោះ មិនបានធ្វើការទាមទារសិទ្ធិនោះទេ មតកសាសន៍នេះនិងមានអានុភាពពេញលេញ។

ការទាមទារគឺធ្វើត្រឹមតែការបង្ហាញឆន្ទៈ ជាការគ្រប់គ្រាន់ហើយលើកលែងតែពុំមានការយល់ព្រមពីភាគីម្ខាងទៀតនោះអ្នកត្រូវបានបំពានអាចដាក់ពាក្យបណ្ដឹងទៅតុលាការ។

ទ្រព្យសម្បត្តិដែលជាកម្មវត្ថុក្នុងការកាត់ភាគបម្រុងរួមមាន អច្ច័យទាន ការកំណត់មតិក តាមមតកសាសន៍ ការទទួលផលប្រយោជន៍ពិសេសនិងប្រទានកម្ម។ ដើម្បីយល់ដឹងថា តើការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងយ៉ាងដូចម្ដេចនោះ ច្បាប់ក៏បានកំណត់អំពីការកាត់បន្ថយផងដែរ។

ប្រទានកម្ម និងការទទួលនូវផលប្រយោជន៍ពិសេស មិនអាចកាត់បន្ថយបានឡើយប្រសិនបើអច្ច័យទាន និងការកំណត់ចំណែកមតិកមិនទាន់បានកាត់បន្ថយជាមុននោះទេ។

ជាគោលការណ៍ ប្រសិនបើមតិកដែលមាននៅពេលចាប់ផ្ដើមសន្តតិកម្មគ្រប់គ្រាន់ ក្នុងការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងនោះប្រទានកម្ម និងការចាត់ចែងពិសេសរបស់មតកជន (ផលប្រយោជន៍ពិសេស) កាលនៅរស់មិនចាំបាច់លើកយកមកពិចារណានោះទេ ប៉ុន្តែប្រសិនបើក្នុងករណីដែលការកាត់បន្ថយចំណែកមតិកនាំឲ្យវាទៅជាការបំពានទៅលើភាគបម្រុង ដោយសារការធ្វើប្រទានកម្មកាលនៅរស់របស់មតកជន ដូច្នេះប្រទានកម្មក៏ជាកម្មវត្ថុនៃការកាត់បន្ថយផងដែរ។

### កថាខណ្ឌទី១ កម្មវត្ថុការកាត់បន្ថយអច្ច័យទាន និងការកំណត់មតិកតាមមតកសាសន៍

លំដាប់នៃការកាត់បន្ថយអច្ច័យទាន និងការការកំណត់មតិកតាមមតកសាសន៍មានពីរគឺ៖

ទី១ ការកាត់បន្ថយអច្ច័យទាន និងចំណែកមតិកដែលបានកំណត់ចំពោះសន្តតិជន

ទី២ ការកាត់បន្ថយពីអច្ច័យទាន និងចំណែកមតិកដែលបានកំណត់ចំពោះបុគ្គលដែលក្រៅពីសន្តតិជន។

ទី៣ ការទទួលស្គាល់នូវការកំណត់ជាមុនតាមមតកសាសន៍

មូលហេតុដែលនាំឲ្យមានការកាត់ន្ថយពីសន្តតិជនជាដំបូងនេះ គឺដោយសារតែសន្តតិជនជាជនដែលត្រូវទទួលបាននូវសន្តតិកម្មក្នុងឋានៈជាកូនបំណុលនៃអច្ច័យទានពីមតកជន ដូច្នេះជាបឋមត្រូវសម្រួលផ្ទៃក្នុងនៃសន្តតិជនជាមុនសិន ហើយប្រសិននៅតែមិនទាន់គ្រប់ទៀតនោះទើបអាចកាត់បន្ថយពីអ្នកក្រៅ។ ក្នុងការកាត់បន្ថយអច្ច័យទានគឺត្រូវតែទៅតាមទៅតាមសមាមាត្រនៃតម្លៃនៃកម្មវត្ថុនោះ។

**ក. អច្ច័យទានចំពោះសន្តតិជន**[24]

បានជាច្បាប់បានបញ្ញត្តិឲ្យធ្វើការកាត់បន្ថយអច្ច័យទានពីសន្តតិជនជាមុនបែបនេះ ក៏ព្រោះតែសន្តតិជនដែលទទួលសន្តតិជននូវឋានៈជាកូនបំណុលនៃអច្ច័យទានពីមតកជន ដូច្នេះ ដំបូងត្រូវសម្រួលផ្ទៃក្នុងសន្តតិជនជាមុនសិន ប្រសិនបើមានការបំពានភាគបម្រុងទៅលើសន្តតិជន ណាមួយនោះ ។

**ឧទាហរណ៍** សន្តតិជនមានចំនួន ២ នាក់ គឺ **ក** និង **ខ** ដែលជាកូនរបស់មតកជន ដែលមតកជនធ្វើការបែងចែកមតិកទៅកូនៗ នីមួយៗ ដូចខាងក្រោម ៖

**ក** ទទួលបាន ១០០ ដុល្លារ

**ខ** ទទួលបាន ៥០០ ដុល្លារ

ហើយមតកជន បានបែងចែកទ្រព្យដែលជាមតិកទៅឲ្យមិត្តភក្តិ **គ** ចំនួន ២០០ ដុល្លារ ។

**ដោយ**

ទ្រព្យមាននៅពេលចាប់ផ្តើមសន្តតិកម្ម ៨០០ដុល្លារ (១០០+៥០០+២០០)

ចំណែកភាគបម្រុងដែលកំណត់ដោយច្បាប់ ១ភាគ២នៃទ្រព្យរបស់មតកជន (៨០០÷២)

ចំនួនសន្តតិជន ២នាក់

$$\text{ក្នុងករណីនេះ ភាគបម្រុងសរុប} = \frac{(១០០+៥០០+២០០)}{២} = ៤០០ \text{ ដុល្លារ}$$

$$\text{សន្តតិជនម្នាក់ៗ} = \frac{៤០០}{២} = ២០០ \text{ ដុល្លារ}$$

ដូចនេះ មានន័យថា **ក** ត្រូវបានបំពានភាគបម្រុងចំនួន ១០០ដុល្លារ ដោយចំនួនទឹកប្រាក់នេះ **ក** អាចធ្វើការទាមទារពី **ខ** បានតែម្នាក់ប៉ុណ្ណោះ ដោយសារ **ខ** ជាសន្តតិជន រីឯ **គ** វិញមិនមែនជាសន្តតិជនទេ ដូច្នេះ **ក** មិនមែនទាមទារពី **គ** បានទេ លុះត្រាតែការកាត់បន្ថយភាគបម្រុងពី **ខ** មិនទាន់គ្រប់ទៅនឹងចំនួនទ្រព្យសម្បត្តិដែលត្រូវធ្វើការទាមទារដើម្បីបង្គ្រប់ភាគបម្រុងនោះ ។

**ខ. អច្ច័យទានចំពោះតតិយជន**[25]

[24] .ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៣៧ កថាខណ្ឌទី ១ ។

ប្រសិនបើការកាត់បន្ថយចំពោះអច្ច័យទានដែលធ្វើឡើងចំពោះសន្តតិជន នៅតែមិនគ្រប់ដើម្បីបង្គ្រប់ភាគបម្រុងរបស់អ្នកមានសិទ្ធិទាមទារលើភាគបម្រុងនោះ នោះយើងនឹងត្រូវធ្វើការកាត់បន្ថយចំពោះអច្ច័យទានដែលមិនមែនជាសន្តតិជនទៀត ។

**ឧទាហរណ៍** សន្តតិជនមាន ២ នាក់ **ក** និង **ខ** ដែលជាកូនរបស់មតកជន ដោយមតកជនការបែងចែកមតិកទៅឲ្យកូននីមួយៗដូចខាងក្រោម ៖

**ក** ទទួលបាន១០០០ ដុល្លារ

**ខ** ទទួលបាន ២៥០០ដុល្លារ

មតកជនបានបែងចែកទ្រព្យដែលជាមតិកទៅឲ្យប្អូនរបស់ខ្លួន គឺ **ឃ** ចំនួន ៤៥០០ ដុល្លារ ។

ក្នុងករណីនេះ ភាគបម្រុងសន្តតិជនម្នាក់ៗ គឺ

$$\text{ភាគបម្រុង} = \frac{\text{១០០០ ដុល្លារ +២៥០០ ដុល្លារ+៤៥០០ ដុល្លារ}}{\text{២}}$$

$$= \text{៤០០០ ដុល្លារ}$$

$$\text{ភាគបម្រុងនៃសន្តតិជនម្នាក់} = \frac{\text{៤០០០}}{\text{២}}$$

$$= \text{២០០០ ដុល្លារក្នុងម្នាក់}$$

ដូចនេះ មានន័យថា **ក** ត្រូវបានបំពានភាគបម្រុងរបស់ចំនួន ១០០០ដុល្លារ ដោយ ចំនួនទឹកប្រាក់នេះ **ក** មិនអាចទាមទារពី **ខ** តែម្នាក់នោះ ទេ ទោះបីជាកាត់បន្ថយដើម្បីបង្គ្រប់ភាគ បម្រុងចាប់ផ្តើមពី អច្ច័យទានចំពោះសន្តតិជនជាមុនក៏ដោយ ព្រោះប្រសិនបើ **ក** ទាមទារពី **ខ** ១០០០ដុល្លារនោះ **ខ** នឹងត្រូវបានបំពានភាគបម្រុងរបស់ខ្លួនវិញចំនួន ៥០០ ដុល្លារ ។ ដូចនេះ **ក** ត្រូវធ្វើការទាមទារឲ្យកាត់បន្ថយពីអច្ច័យទានដែលធ្វើចំពោះតតិយជនគឺ **ឃ** ចំនួន ៥០០ ដុល្លារ ទៀតដែលនៅសល់ ដើម្បីបង្គ្រប់ភាគបម្រុងរបស់ខ្លួន ។

[25] .ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៣៧ កថាខណ្ឌទី ២ ។

### គ. ការទទួលស្គាល់នូវការកំណត់ជាមុនតាមមតកសាសន៍[26]

ទោះបីជាច្បាប់បានបញ្ញត្តិអំពីលំដាប់នៃជន ដែលត្រូវបានទទួលការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងក៏ដោយក៏ច្បាប់បានទទួលស្គាល់ផងដែរ ក្នុងករណីដែលម្ចាស់បណ្តាំបានបង្ហាញឆន្ទៈពិសេសផ្សេងក្នុងមតកសាសន៍ មានន័យថា ច្បាប់បានទទួលនូវការកំណត់ជាមុនតាមមតកសាសន៍ ។

**ឧទាហរណ៍** សន្តតិជនមាន បី នាក់ គឺ **ក ខ គ** ដែលនៅក្នុងមតកសាសន៍បានបែងចែកទ្រព្យសម្បត្តិឲ្យសន្តតិជនដូចខាងក្រោម ៖

ក ទទួលបាន ១២០០ ដុល្លារ

ខ ទទួលបាន៦០០ ដុល្លារ

គ មិនទទួលបាន អ្វីសោះ

នៅក្នុងមតកសាសន៍បានបន្ថែមទៀតថា ក្នុងករណីដែលមានការទាមទារកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងនោះ ត្រូវធ្វើការកាត់បន្ថយពី ក ទាំងអស់ ។ គ ក៏បានបង្ហាញឆន្ទៈទាមទារភាគបម្រុងរបស់ខ្លួន ។

ដំណោះស្រាយ

$$\text{ភាគបម្រុង} = \frac{(១២០០+៦០០)}{២} = ៩០០ \text{ ដុល្លារ}$$

$$\text{ភាគបម្រុងរបស់ គ} = \frac{៩០០}{៣} = ៣០០\text{ដុល្លារ}$$

ក្នុងករណីប្រសិនបើគ្មានមតកសាសន៍កំណត់ជាមុនទេ **គ** អាចទាមទារទឹកប្រាក់ចំនួន ២០០ ដុល្លារ ពី **ក** និង ១០០ ដុល្លារ ពី **ខ** (សរុប ៣០០ ដុល្លារ)។ ប៉ុន្តែ ដោយសារមតកសាសន៍បានតម្រូវឲ្យអ្នក ដែលមានសិទ្ធិភាគបម្រុងធ្វើការទាមទារភាគបម្រុងរបស់ខ្លួនពី **ក** ដូច្នេះ **ក** គឺជាអ្នកដែលមាន កាតព្វកិច្ចក្នុងការផ្តល់នូវភាគបម្រុងទៅឲ្យ **គ** ទាំងអស់ចំនួន ៣០០ ដុល្លារ ដោយ **ខ** មិនចាំបាច់បង់ ប្រាក់ចំនួន ១០០ ដុល្លារ ទៅឲ្យ **គ** ទេ ។

[26] .ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៣៧ កថាខណ្ឌទី៤ ។

## កថាខណ្ឌទី២. ផលប្រយោជន៍ពិសេស ឬ ប្រទានកម្ម

ប្រសិនបើការធ្វើអច្ច័យទានមិនបណ្តាលឲ្យមានការបំពានភាគបម្រុងទេនោះ គឺយើងត្រូវធ្វើការសិក្សាទៅលើផលប្រយោជន៍ពិសេស ឬ ប្រទានកម្មប្រសិនបើយើងរកឃើញថាការផ្តល់ផលប្រយោជន៍ពិសេស ឬ ប្រទានកម្មពីសំណាក់មតកជនទៅឲ្យជនណាម្នាក់ ឬ ច្រើននាក់ដែលធ្វើឲ្យមានការបំពានភាគបម្រុងនោះគឺសន្តតិជន ដែលត្រូវបានបំពានភាគបម្រុងនោះមានសិទ្ធិក្នុងការទាមទារនូវភាគបម្រុងរបស់ខ្លួន។ ប៉ុន្តែការទាមទារនេះមិនមែនចេះតែធ្វើការទាមទារតាមទំនើងចិត្តរបស់អ្នកមានសិទ្ធិលើភាគបម្រុងនោះទេ គឺមានន័យថាការទាមទារភាគបម្រុងគឺត្រូវធ្វើការទាមទារទៅតាមលំដាប់នៃការកាត់បន្ថយផលប្រយោជន៍ពិសេស ឬ ប្រទានកម្មនោះ ដោយការកាត់បន្ថយនេះត្រូវធ្វើឡើងចំពោះកិច្ចសន្យាដែលត្រូវបានចាត់ទុកជាប្រទានកម្ម រួមនិងការចាត់ចែងកម្មវត្ថុនៃប្រទានកម្មផងដែរ។

### ក. លំដាប់នៃការកាត់បន្ថយផលប្រយោជន៍ពិសេស ឬ ប្រទានកម្ម

ការកាត់បន្ថយប្រទានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេសត្រូវចាប់ផ្តើមពីប្រទានកម្មឬការទទួលផលប្រយោជន៍ពិសេសដែលបានធ្វើក្រោយគេ បន្ទាប់មកត្រូវធ្វើចំពោះប្រទានកម្ម ឬ ការទទួលផលប្រយោជន៍ពិសេសដែលបានធ្វើមុនមកជាបន្តបន្ទាប់[27]។

ប៉ុន្តែបើការធ្វើប្រទានកម្ម ឬ ទទួលផលប្រយោជន៍ពិសេសលើសពី ២០ ឆ្នាំនៅមុនពេលចាប់ផ្តើមសន្តតិកម្មបដិគ្គាហក ឬសន្តតិជនដែលបានទទួលផលប្រយោជន៍ពិសេសនោះអាចបដិសេធការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងនេះបាន។

### ខ. ការកាត់បន្ថយចំពោះកិច្ចសន្យា ដែលត្រូវចាត់ទុកជាប្រទានកម្ម

របបភាគបម្រុងគឺជារបប ដែលការពារជនដែលមានសិទ្ធិលើភាគបម្រុងពីការចាត់ចែងដោយគ្មានកម្រៃ ដូច្នេះកិច្ចសន្យា ដែលមានតម្លៃមិនត្រឹមត្រូវជាអាទិ៍ ក៏គួរយកមកធ្វើជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងផងដែរ។ កិច្ចសន្យា ដែលបានធ្វើឡើងដោយយកតម្លៃថ្នូរមិនត្រឹមត្រូវ ត្រូវចាត់ទុកថាជាប្រទានកម្ម តែក្នុងករណី ដែលត្រូវធ្វើឡើងដោយភាគីទាំងសងខាងបានដឹងថានឹងបណ្តាលឲ្យខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុងប៉ុណ្ណោះ។ ក្នុងករណីនេះ បើអ្នកមាន

[27] .ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៣៦។

សិទ្ធិលើភាគបម្រុងទាមទារឲ្យធ្វើការកាត់បន្ថយនោះ អ្នកនោះ ត្រូវសងតម្លៃថ្នូរនោះ មកវិញចំពោះការកាត់បន្ថយកិច្ចសន្យាដែលត្រូវចាត់ទុកជាប្រទានកម្មក៏ត្រូវបានរាប់បញ្ចូលទាំងការលើកលែងកាតព្វកិច្ចដោយយកតម្លៃថ្នូរមិនត្រឹមត្រូវផងដែរ [28]។

**គ. ការចាត់ចែងកម្មវត្ថុនៃប្រទានកម្ម**

អ្នកមានសិទ្ធិលើភាគបម្រុង អាចធ្វើបានចំពោះករណី ដែលសហសន្តតិជនត្រូវទទួលការកាត់បន្ថយនោះ បានធ្វើអនុប្បទានកម្មវត្ថុនៃប្រទានកម្មឲ្យទៅអ្នកដទៃ ឬបានបង្កើតផលុបភោគ ឬសិទ្ធិប្រាតិភោគ ប្រត្យក្ស សម្រាប់អ្នកដទៃ ។ បើសហសន្តតិជន អច្ច័យលាភី បដិគ្គាហក ដែលត្រូវទទួលការកាត់បន្ថយបានធ្វើអនុប្បទាននូវកម្មវត្ថុនៃប្រទានកម្មឲ្យទៅអ្នកដទៃជននោះត្រូវសងចំនួនទឹកប្រាក់ក្នុងកម្រិតនៃតម្លៃនៅពេលបានចាត់ចែងនោះ ឲ្យទៅអ្នកមានសិទ្ធិលើភាគបម្រុង ។ ប៉ុន្តែបើអនុប្បទានិកនោះ បានដឹងថានឹងបណ្ដាលឲ្យខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុង នៅពេលធ្វើអនុប្បទានអ្នកមានសិទ្ធិលើភាគបម្រុងអាចទាមទារឲ្យកាត់បន្ថយ ចំពោះអនុប្បទានិកនោះបានដែរ ។ អ្វីដែលបានរៀបរាប់ខាងលើ ក៏យកមលអនុវត្តដូចគ្នាផងដែរ ចំពោះករណីដែលសហសន្តតិជន អច្ច័យលាភី បដិគ្គាហក បានបង្កើតសិទ្ធិលើកម្មវត្ថុនៃប្រទានកម្មនោះ ។ ដូច្នេះ អ្នកមានសិទ្ធិលើភាគបម្រុង និងអ្នកទទួលបន្តអាចធ្វើការទាមទារឲ្យកាត់បន្ថយអច្ច័យទានចំពោះជនដែលបានទទួលទ្រព្យសម្បត្តិ ឬផលប្រយោជន៍ដែលកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងបាន ត្រឹមកម្រិតដែលចាំបាច់ដើម្បីរក្សាភាគបម្រុងនោះ ។ ហេតុដូចនេះ លក្ខណៈតាមផ្លូវច្បាប់នូវសិទ្ធិទាមទារកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងគឺជាសិទ្ធិបង្កើតទំនាក់ទំនងគតិយុត្តហេតុនេះហើយបានជាអច្ច័យទាន ឬ ប្រទានកម្មត្រូវបាត់បង់អានុភាពដោយស្វ័យប្រវត្តិក្នុងកម្រិតដែលបានបំពាន ដល់ភាគបម្រុងនោះ ដោយការអនុវត្តសិទ្ធិរបស់អ្នកមានសិទ្ធិលើភាគបម្រុងនោះ ។

## ផ្នែកទី២ វិធីផ្ដល់សំណង ចំពោះការបង្គ្រប់ភាគបម្រុង

នៅពេលដែលសន្តតិជន ដែលមានសិទ្ធិលើភាគបម្រុងបានទាមទារទ្រព្យសម្បត្តិ ដែលជាចំណែកមតិករបស់ខ្លួនពីសហសន្តតិជន ឬ អច្ច័យលាភី ឬ បដិគ្គាហក នៅពេលនោះ បុគ្គលទាំងនោះ

[28] .ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៤២។

ត្រូវសងផលមកវិញផងដែរ ។ ប៉ុន្តែប្រសិនបើអ្នកទាំងអស់នោះ មិនអាចសងបានដោយសារតែអសាធនភាព តើបន្ទុកនៃការខាតបង់ត្រូវធ្លាក់ទៅលើអ្នកណា ? ស្របពេលជាមួយគ្នានេះដែរ ទ្រព្យដែលអ្នកមានសិទ្ធិលើភាគបម្រុងបានទាមទារមិនមែនសុទ្ធជាប្រាក់នោះទេ ពីព្រោះពេលខ្លះ មត៌កដែលមតកជនបានបន្សល់ទុកអាចជាចលនវត្ថុ ឬ អចលនវត្ថុជាដើម ហេតុនេះ បញ្ហានឹងចោទឡើងថាក្នុងករណីមត៌កមិនមែនជាប្រាក់តើការសងអាចធ្វើឡើងដោយបង់តម្លៃបានដែរឬទេ ?

### កថាខណ្ឌទី១ ការសងមកវិញ

សហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក ក្រៅពីទ្រព្យសម្បត្តិ ឬប្រាក់សំណង ដែលត្រូវសងមកវិញនោះ ត្រូវសងមកវិញផងដែរនូវផលដែលកើតឡើងក្រោយពីថ្ងៃ ដែលបានទាមទារឲ្យធ្វើការកាត់បន្ថយ មានន័យថាផលដែលជាកម្មវត្ថុនៃសំណងនេះ មិនត្រូវកម្រិតត្រឹមតែផលដែលបានធ្វើលទ្ធកម្មពិតប្រាកដ ក្រោយថ្ងៃដែលបានធ្វើការទាមទារទេ គឺត្រូវមានករណីយកិច្ចសងសំណងនូវតម្លៃនៃផលដែលត្រូវបានខូចខាត ឬ ធ្វេសប្រហែសក្នុងការទទួលដោយកំហុស ចាប់ពីថ្ងៃដែលបានទទួលការទាមទារឲ្យកាត់បន្ថយ[29] ។

**ឧទាហរណ៍៖**

មតកជនបានបន្សល់ទុកទ្រព្យសម្បត្តិនូវដីមួយកន្លែងដែលមានតម្លៃ ២៥០០ ដុល្លារ ដែលបានប្រគល់ដីនោះ ឲ្យទៅកូន **ក** ( ដែលនៅក្នុងដីនោះមានដំណាំហូបផ្លែជាច្រើន នៅពេលដែល **ក** បានទទួលដីនោះ បានលក់ដំណាំទាំងឲ្យទៅអ្នកម៉ៅការ ១០០ ដុល្លារ ) ក្នុងចំណោម សហសន្តតិជន ២ នាក់ គឺ **ក** និង **ខ** ។ មិនតែប៉ុណ្ណោះ កាលនៅរស់មតកជនបានធ្វើប្រទានកម្មនូវប្រាក់ចំនួន ៧៥០០ ដុល្លារ ទៅឲ្យ **ក** ទៀតផង ដែលជាហេតុបណ្តាលឲ្យ **ខ** មិនទទួលបានអ្វីសោះ ទើបដាក់ពាក្យបណ្តឹងទាមទារពាក្យបណ្តឹងរបស់ខ្លួន ។

**ដំណោះស្រាយ**

ក្នុងករណីភាគបម្រុងរបស់ ខ គឺ

$$\text{ភាគបម្រុង} = \frac{៧៥០០+២៥០០}{២}$$

$$= ៥០០០ \text{ ដុល្លារ}$$

[29] .ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៣៩។

ភាគបម្រុងរបស់ ខ = ៥០០០ ដុល្លារ / ២

= ២៥០០ ដុល្លារ

ដូចនេះ មានន័យថា **ខ** អាចទាមទារដីដែលជាទ្រព្យសម្បត្តិដែលមតកជនបានបន្សល់ទុក តែ ម្តងក៏ប៉ុន្តែដោយសារច្បាប់បានកំណត់អំពីការសងផលមកវិញដែលជាហេតុធ្វើឲ្យ **ក** មានកាតព្វកិច្ច សងទាំងដី និងប្រាក់ដែលបានពីការលក់ដំណាំហូបផ្លែ ចំនួន ១០០ ដុល្លារថែមទៀត ។ ហេតុនេះ ហើយភាគបម្រុងដែល **ខ** អាចទាមទារបានសរុប ២៥០០+ ១០០ = ២៦០០ ដុល្លារ។

### កថាខណ្ឌទី ២ បន្ទុកនៃការខាតបង់ដោយអសាធនភាព

ការខាតបង់ដែលកើតឡើងដោយសារអសាធនភាព របស់សហសន្តតិជន អគ្គាហាក អច្ច័យលាភី ឬ បដិគ្គាហាក ដែលត្រូវទទួលការកាត់បន្ថយ ត្រូវធ្លាក់ជាបន្ទុករបស់អ្នកមានសិទ្ធិលើភាគបម្រុង ។ ក្នុងករណីដែលភាគីម្ខាងទៀតនៃសិទ្ធិទាមទារឲ្យសង ស្ថិតក្នុងអសាធនភាព តាមសមាមាត្រតាមគោលការណ៍នៃក្រមរដ្ឋប្បវេណីអ្នកមានសិទ្ធិ ជាអ្នកទទួលបន្ទុកនូវការខាតបង់នោះ មានន័យថា ទោះបីអ្នកមានកាតព្វកិច្ចជាអ្នកអសាធនក៏ដោយ ក៏អ្នកមានសិទ្ធិលើភាគបម្រុងនោះមិនអាចទាមទារឲ្យអ្នកមានកាតព្វកិច្ចក្នុងលំដាប់បន្តបន្ទាប់ សងនូវចំណែកដែលទាមទារមិនបានគ្រប់នោះទេ [30]។

**ឧទាហរណ៍៖**

ក្នុងករណីមតកជនមានសហព័ទ្ធ **ក** និងកូន **ខ** និង **គ** ។ ដោយ ៣ ឆ្នាំមុនបានទទួលមរណភាព មកតជនបានធ្វើប្រទានកម្មក្នុងទឹកប្រាក់ ៨៥០ ដុល្លារ ឲ្យទៅ **ខ** ហើយកន្លះឆ្នាំ មុននឹងទទួលមរណភាពបានធ្វើប្រទានកម្មឲ្យសហព័ទ្ធ **ក** ចំនួន ២៥០ ដុល្លារ ។ (ប៉ុន្តែក្រោយមក **ក** ក្លាយជាអ្នកអសាធន) ជាក់ស្តែងមតិកដែលមាននៅពេលចាប់ផ្តើមសន្តតិកម្មគឺមានត្រឹមតែ ១០០ ដុល្លារប៉ុណ្ណោះ ហេតុនេះ **គ** អាចធ្វើការទាមទារភាគបម្រុង ។

**ដំណោះស្រាយ**

ក្នុងករណីនេះ ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុងគឺ

[30] .ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៤០។

ទ្រព្យជាមូលដ្ឋានក្នុងការគណនាភាគបម្រុង = ទ្រព្យមានពេលចាប់ផ្ដើមសន្តតិកម្ម + ផលប្រយោជន៍ពិសេស + ប្រទានកម្ម - កាតព្វកិច្ច

នាំឲ្យទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង = (១០០ដុល្លារ + ៨៥០ ដុល្លារ + ២៥០ដុល្លារ +0 ប្រទានកម្ម)- 0 កាតព្វកិច្ច = ១២០០ ដុល្លារ

ដោយភាគបម្រុង= ១/២ នៃទ្រព្យសម្បត្តិរបស់មតកជន

ដូចនេះ ភាគបម្រុង= ទ្រព្យដែលជាមូលដ្ឋាននៃភាគបម្រុង ÷ ១/២នៃទ្រព្យរបស់មតកជន

ភាគបម្រុង = ១២០០ ÷ ១/២ = ៦០០ ដុល្លារ

ដោយសន្តតិជនមានគ្នា បី នាក់ទើបភាគបម្រុងត្រូវធ្វើការបែងចែកជាបីចំណែកទៀតគឺ

ទ្រព្យដែលជាភាគបម្រុងសម្រាប់ម្នាក់ៗ = ភាគបម្រុង ÷ ចំនួនសន្តតិជន

នាំឲ្យ = ៦០០ដុល្លារ ÷ ៣នាក់ = ២០០ ដុល្លារ

មានន័យថា **គ** ទទួលបានមតិកនៅពេលចាប់ផ្ដើមសន្តតិកម្មទាំងអស់ ១០០ ដុល្លារក៏ដោយក៏នូវតែត្រូវបានបំពានភាគបម្រុងរបស់ខ្លួនចំនួន ១០០ ដុល្លារទៀតដែរ ។

ដូច្នេះ **គ** អាចទាមទារពី **ក** បានត្រឹមតែ ៥០ ដុល្លារតែប៉ុណ្ណោះ (ពីព្រោះលំដាប់នៃការកាត់បន្ថយត្រូវកាត់បន្ថយពីសន្តតិជន ដែលទទួលផលប្រយោជន៍ក្រោយគេ) ប្រសិនបើទាមទារ១០០ ដុល្លារពី **ក** នោះនឹងត្រូវបំពានភាគបម្រុងរបស់ **ក** ហេតុដូចនេះ ហើយ ៥០ ដុល្លារទៀត ត្រូវកាត់បន្ថយពី **ខ** ។ ក៏ប៉ុន្តែដោយសារ **ក** ជាជនអាសាធន ហើយមិនអាចសង ៥០ ដុល្លារឲ្យ **គ** បានទេ ដូចនេះ ការខាតបង់ ដោយសារអសាធនភាពរបស់សហសន្តតិជនត្រូវធ្លាក់ជាបន្ទុករបស់អ្នកមានសិទ្ធិលើភាគបម្រុង គឺ **គ** ។ ហើយ **គ** មិនអាចទាមទារឲ្យ **ខ** សងលើសពី ៥០ ដុល្លារបានដែរ ទោះបីជា **គ** មានភាគបម្រុងរបស់ខ្លួនចំនួន ២០០ដុល្លារ ក៏ដោយ ។ ជាក់ស្ដែង **គ** ទទួលបានទ្រព្យសម្បត្តិត្រឹម តែ ១៥០ ដុល្លារតែប៉ុណ្ណោះ ។

### កថាខណ្ឌទី ៣ សំណងដោយបង់ថ្លៃ

សហសន្តតិជន អច្ច័យលាភី ឬ បដិគ្គាហក អាចរួចផុតពីកាតព្វកិច្ចនៃការសងបានដោយបង់តម្លៃនៃចំណែកមតិកដែលបានកំណត់ តម្លៃនៃកម្មវត្ថុនៃអច្ច័យទាន ចុះថ្លៃនៃកម្មវត្ថុនៃប្រទានកម្មទៅឲ្យអ្នកដែលមានសិទ្ធិលើភាគបម្រុងត្រឹមកម្រិតដែលត្រូវទទួលការកាត់បន្ថយ ។ មានន័យថា អ្នក

មានកាតព្វកិច្ចនៃការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង អាចរួចផុតពីកាតព្វកិច្ចនៃការសងដោយបង់តម្លៃនៃកម្មវត្ថុនោះទៅអ្នកមានសិទ្ធិលើភាគបម្រុង[31] ។

ប្រសិនបើអ្នកមានកាតព្វកិច្ចអះអាងថា និងសងថ្លៃហើយបានសងថ្លៃក្រោយពីការព្រមព្រៀងគ្នានោះសិទ្ធិទាមទារឲ្យកាត់បន្ថយ និងរលត់ដោយស្វ័យប្រវត្តិ។ ប៉ុន្តែបើអ្នកមានកាតព្វកិច្ចមិនបានអះអាងថានឹងសងដោយបង់តម្លៃទេ អ្នកមានសិទ្ធិលើភាគបម្រុងមិនអាចទាមទារឲ្យសងជាប្រាក់បានទេ គឺអាចត្រឹមតែទាមទារឲ្យសងជាវត្ថុនោះតែប៉ុណ្ណោះ ។

ក្នុងករណីដែលមានការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ចំពោះអនុប្បទានិកដែលជាជនទុច្ចរិតអំពីការបង្ករឲ្យកាត់បន្ថយ ដើម្បីបង្គ្រប់ភាគបម្រុងក៏អនុប្បទានិកនោះអាចសងដោយប្រាក់បានដែរ ។

## ផ្នែកទី៣ ការរំលត់សិទ្ធិក្នុងការទាមទារឲ្យកាត់បន្ថយភាគបម្រុង

ចំពោះសិទ្ធិ ក្នុងការទាមទារលើភាគបម្រុងគឺមានអាជ្ញាយុកាលកំណត់ច្បាស់លាស់ ដោយសន្តតិជន ដែលអ្នកមានសិទ្ធិលើភាគបម្រុងមិនអាចទាមទារបានតាមអំពើចិត្តគ្រប់ពេលវេលានោះទេ ដូចនេះដើម្បីដឹងថាតើអ្នកមានសិទ្ធិលើភាគបម្រុងអាចទាមទារឲ្យកាត់បន្ថយបាននៅពេលណានោះ យើងត្រូវធ្វើការសិក្សាអំពីអាជ្ញាយុកាលនៅការរំលត់សិទ្ធិ (កថាខណ្ឌទី ១) ។ ហើយនៅក្នុងផ្នែកទី ៣ នេះក៏ធ្វើការសិក្សាផងដែរ អំពីការបោះបង់ភាគបម្រុង (កថាខណ្ឌទី ២) ។

### កថាខណ្ឌទី ១ អាជ្ញាយុកាលនៃការរំលត់សិទ្ធិ

ជាគោលការណ៍ការរំលត់សិទ្ធិក្នុងការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងនិងកើតឡើងដោយការមិនអនុវត្តសិទ្ធិក្នុងអំឡុងពេលដែលបានចែងក្នុងច្បាប់ ។ ក្រមរដ្ឋប្បវេណី លេខ នស/ រកម / ១២០៧/ ០៣០ ចុះថ្ងៃទី ០៨ ខែ ធ្នូ ឆ្នាំ ២០០៧ បានចែងថា ៖ សិទ្ធិទាមទារឲ្យកាត់បន្ថយត្រូវរលត់ដោយគ្មានអាជ្ញាយុកាល បើអំឡុងពេល១ឆ្នាំកន្លងហួសគិតចាប់ពីពេលដែលអ្នកមានសិទ្ធិលើភាគបម្រុងបានដឹងអំពីការចាប់ផ្តើមសន្តតិកម្ម និងការកំណត់ ចំណែកមតិក អច្ច័យទាន ប្រទានកម្ម ឬការទទួលផលប្រយោជន៍ពិសេសដែលត្រូវបានកាត់បន្ថយ។ សិទ្ធិទាមទារឲ្យកាត់បន្ថយក៏ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល៥ឆ្នាំ បានកន្លងហួស គិត ចាប់ពីពេលចាប់ផ្តើមសន្តតិកម្ម [32]។

---

[31] .ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៤៤។

[32] .ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៤៥។

ការរលត់ដោយអាជ្ញាយុកាលមានសិទ្ធិទាមទារឲ្យកាត់បន្ថយ ដើម្បីបង្គ្រប់ភាគបម្រុងរបស់សន្តតិជនម្នាក់ ឬការបោះបង់ភាគបម្រុងដោយសហសន្តតិជនណាម្នាក់ ពុំមានឥទ្ធិពលទៅលើសហសន្តតិជនផ្សេងទៀតទេ ។ មានន័យថាភាគបម្រុងរបស់សហសន្តតិជនមានផ្សេងពីគ្នា ដូចច្នេះការរលត់សិទ្ធិ ដោយអាជ្ញាយុកាលនៃសិទ្ធិទាមទារឲ្យកាត់បន្ថយ ដើម្បីបង្គ្រប់ភាគបម្រុងរបស់សហសន្តតិជនណាម្នាក់ ពុំមានឥទ្ធិពលទៅលើសហសន្តតិជនផ្សេងទៀតឡើយ[33]។

ចំពោះប្រទានកម្ម ក្នុងករណីដែលបានធ្វើប្រទានកម្ម ឬទទួលផលប្រយោជន៍ពិសេសលើសពី២០ឆ្នាំនៅមុនពេលចាប់ផ្តើមសន្តតិកម្ម បដិគ្គាហក ឬសន្តតិជនដែលបានទទួលផលប្រយោជន៍ពិសេសនោះអាចបដិសេធនូវការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងបាន។

## កថាខណ្ឌទី ២ ការបោះបង់ភាគបម្រុង

ស្របពេលដែលច្បាប់អនុញ្ញាតឲ្យសន្តតិជនមានសិទ្ធិលើភាគបម្រុង ទាមទារនូវចំណែកមតិករបស់ខ្លួន ច្បាប់ក៏បានអនុញ្ញាតផងដែរចំពោះសន្តតិជនដែលមានបំណងចង់បោះបង់ភាគបម្រុងអាចបោះបង់ចោលទាំងអស់ ឬ មួយផ្នែកបាន [34]។ ការបោះបង់នូវភាគបម្រុងអាចធ្វើបានដោយការបង្ហាញឆន្ទៈតែម្ខាងចំពោះអ្នកមានកាតព្វកិច្ច ។ ដើម្បីបោះបង់នូវភាគបម្រុងមុនពេលពេលចាប់ផ្តើមសន្តតិកម្ម ចាំបាច់ត្រូវមានការអនុញ្ញាតពីតុលាការ ។ ដើម្បីកុំឲ្យមានការបោះបង់សិទ្ធិនេះទុកជាមុនដោយសារតែការចាញ់អំណាចរបស់ឪពុកម្តាយជាអាទិ៍ ចាំបាច់ត្រូវមានការពិនិត្យតាងនាមជាអាណាព្យាបាលដោយតុលាការ។ តុលាការដែលទទួលពាក្យសុំឲ្យអនុញ្ញាតត្រូវធ្វើការវិនិច្ឆ័យដោយពិនិត្យថា តើការបោះបង់នោះជាឆន្ទៈពិតរបស់ជនដែលមានសិទ្ធិលើភាគបម្រុងដែរ ឬទេ ? តើការបោះបង់មានភាពសមហេតុផលដែរឬទេ ? តើចាំបាច់បោះបង់ដែរ ឬ ទេ? តើមានតម្លៃ ជាថ្នូរដែរឬទេជាអាទិ៍ ។ ម្យ៉ាងទៀតការចាប់ផ្តើមសន្តតិកម្មដោយការទទួលអនុញ្ញាតពីតុលាការក៏ដោយក៏អ្នកមានសិទ្ធិលើភាគបម្រុងនោះ អាចដាក់ពាក្យសុំទៅតុលាការឲ្យលុបចោលនូវការអនុញ្ញាតនោះបានដែរ នៅមុនពេលចាប់ផ្តើមសន្តតិកម្ម ប្រសិនបើស្ថានភាពមានការផ្លាស់ប្តូរនៅក្រោយពេលបោះបង់សិទ្ធិនោះ។ នេះ យោងតាមការបកស្រាយថា តុលាការអាចលុបចោលនូវការអនុញ្ញាតមុនតាមពាក្យសុំបាន។ ក្នុងករណីដែលមានសហសន្តតិជនភាគបម្រុងរបស់សន្តតិជនម្នាក់ៗមានផ្សេងពីគ្នា ។

---

[33] .ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៥៣។

[34] .ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៤៦។

ដូច្នេះ ការរំលត់ដោយអាជ្ញាយុកាលមានសិទ្ធិទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងរបស់សហសន្តតិជនណាម្នាក់ពុំមានឥទ្ធិពលលើភាគបម្រុងរបស់សហសន្តតិជនទៀតឡើយ [35]។

[35] .ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧,មាត្រា ១២៤៧។

# សេចក្តីសន្និដ្ឋាន

ឆ្លងកាត់ធ្វើការសិក្សាស្រាវជ្រាវទៅលើរបបនៃភាគបម្រុងរួចមក យើងអាចសន្និដ្ឋានបានថា របបនៃភាគបម្រុងពិតជាមានសារៈសំខាន់ខ្លាំងណាស់ នៅក្នុងជីវភាពរស់នៃសង្គមគ្រួសារកម្ពុជាក៏ដូចជាទំនាក់ទំនងអន្តរជាតិផងដែរ ។ ការប្រាស្រ័យទាក់ទងគ្នា និងការរស់នៅរបស់មនុស្សមានទំនាក់ទំនងយ៉ាងស្អិតរមួតទៅនឹងបេតិកភ័ណ្ឌ ព្រោះមនុស្សប្រើប្រាស់វាដោយខាងតែបាន ដើម្បីដោះដូរនៃដំណើរជីវិតជីវភាពប្រចាំថ្ងៃ។ យ៉ាងណាមិញរបបភាគបម្រុងគឺជារបបធានាមួយភាគនៃចំណែកមតិកដែលកំណត់ដោយច្បាប់ ចំពោះសន្តតិជនដែលច្បាប់បានកំណត់មួយចំនួន (មិនមែនសន្តតិជនតាមច្បាប់កំណត់ទាំងអស់សុទ្ធតែជាអ្នកមានសិទ្ធិទាមទារលើភាគបម្រុងនោះទេ ជាក់ស្តែងសន្តតិជនលំដាប់ទី៣ គឺបងប្អូនបង្កើតមិនមានសិទ្ធិទាមទារលើភាគបម្រុងក្នុងករណីដែលមានការបំពានទេ បើទោះបីជាបងប្អូនបង្កើតនោះទទួលឋានៈជាសន្តតិជនលំដាប់ទី៣ក៏ដោយ) ដែលទ្រព្យមួយភាគនៃចំណែកមតិកនេះ គឺជាទ្រព្យក្នុងកម្រិតអប្បរមាមួយ ដែលសន្តតិជនមានសិទ្ធិលើភាគបម្រុងអាចទាមទារបានមានន័យថា ទ្រព្យដែលជាចំណែកមតិកដែលអាចទទួលតិចបំផុត ត្រូវស្មើនឹងភាគបម្រុងរបស់សន្តតិជនម្នាក់ៗ គឺមិនអាចតិចជាងនេះទៀតទេលើក លែងតែករណីមួយតែប៉ុណ្ណោះគឺអ្នកដែលមានកាតព្វកិច្ចផ្តល់ភាគបម្រុងនោះ មិនអាចសងនូវតម្លៃនៃទ្រព្យនោះបានដោយសារតែខ្លួនទទួលរងនូវអសាធនភាព ដែលបន្ទុកនោះត្រូវធ្លាក់ទៅលើអ្នកមានសិទ្ធិលើភាគបម្រុងវិញ ។ បន្ថែមពីលើនេះ របបនៃភាគបម្រុងត្រូវបានបង្កើតឡើងក្នុងគោលគំនិតនៃការដើរតួនាទី ក្នុងការសម្របសម្រួលរវាងសន្តតិកម្មតាមច្បាប់ និងសន្តតិកម្មតាមមតកសាសន៍ព្រមទាំងមានតួនាទីការពារសិទ្ធិដល់ជនមួយចំនួនដែលជាសាច់ញាតិក្នុងទំហំកំណត់ណាមួយ ។ តាមរយៈគោលគំនិតខាងលើនេះ ភាគបម្រុងមានទំនាក់ទំនងយ៉ាងស្អិតរមួតជាមួយនឹងប្រព័ន្ធសន្តតិកម្ម (សន្តតិកម្ម តាមច្បាប់ និងសន្តតិកម្មតាមមតកសាសន៍)។ ភាពផ្តាច់មុខនៃសន្តតិកម្មតាមការកំណត់របស់ច្បាប់ ដែលមិនផ្តល់សេរីភាពពេញបរិបូរណ៍ក្នុងការធ្វើបណ្តាំដែលពុំមាន ឬផាត់ចេញនូវភាគបម្រុង។ អាចនិយាយបានថាភាពចាំបាច់នៃភាគទំនេរត្រូវបានស្វាគមន៍ តែភាគបម្រុងគឺជាចំណុចដែលមិនអាចរំលងបាន និងជាចំណុចដែលគួរពិភាក្សា។ ប្រសិនបើ គ្មានវត្តមាននៃរបបភាគបម្រុងនេះទេ យើងឃើញថានឹងមានបញ្ហាកើតមានរវាងបងប្អូននៅក្នុងរង្វង់គ្រួសារក៏ដូចជាសង្គមដោយសារការបំពានផ្សេងៗ ពីព្រោះតែការបង្ហាញឆន្ទៈរបស់មតកជន អាចនឹងកើតមានភាពលំអៀងមិនស្មើភាពគ្នារវាងសន្តតិជន និងសន្តតិជនដោយវាបង្កឲ្យមានការបំពានសិទ្ធិ និងបាត់បង់ផលប្រយោជន៍ដែលខ្លួនត្រូវទទួលបាន ។ ជាមួយគ្នានេះផងដែរ វាក៏ជាមធ្យោបាយក្នុងការទប់ទល់ទៅនឹងគ្រោះកាចទាំងឡាយដែលកើតឡើង

ជាយថាហេតុ បណ្តាលមកពីម្ចាស់បណ្តាំបានប្រើសិទ្ធិក្នុងលក្ខណៈបំពាន។ ប៉ុន្តែអ្វីដែលគួរឲ្យកត់សម្គាល់មួយទៀតនោះគឺ ទោះបីជាមានការបំពាននូវភាគបម្រុងក៏ដោយប្រសិនបើជនដែលត្រូវបានគេបំពាននោះ មិនបានបង្ហាញឆន្ទៈក្នុងការទាមទារទេនោះក៏មិនចាំបាច់មានការកាត់បន្ថយ ដើម្បីបង្គ្រប់ភាគបម្រុងនោះដែរ។

សរុបសេចក្តីមក របបភាគបម្រុងនេះពិតជាមានសារៈសំខាន់ខ្លាំងណាស់ ចំពោះសន្តតិជនដែលច្បាប់បានកំណត់ដើម្បីជៀសវាងនូវការរំលោភបំពាន បាត់បង់ផលប្រយោជន៍ដោយសារតែមតកជន៕

# អនុសាសន៍

យោងតាមការសិក្សាស្រាវជ្រាវលើប្រធានបទរួចមក យើងឃើញអំពីចំនុចអវិជ្ជមាន (កង្វះខាត)មួយចំនួន ដោយសូមផ្តល់អនុសាសន៍ដូចខាងក្រោម

ទាក់ទងទៅនឹងអ្នកមានសិទ្ធិលើភាគបម្រុងបានបង្ហាញថា ជនទាំងនោះ សុទ្ធតែជាសន្តតិជនតាមច្បាប់កំណត់ទាំងអស់ លើកលែងតែបងប្អូនបង្កើតរបស់មតកជន ដែលជាសន្តតិជនដែលច្បាប់បានកំណត់ដែរ តែបែរជាគ្មានវត្តមាន ក្នុងនាមជាអ្នកមានសិទ្ធិលើភាគបម្រុងទៅវិញ ។ នេះគឺជាបញ្ហាត្រូវពិចារណាដោយសារតែបងប្អូនបង្កើត ក៏ត្រូវបានច្បាប់ទទួលស្គាល់គាត់ថាជាសន្តតិជនដែរ។ ចុះហេតុអ្វីមិនផ្តល់ឲ្យសិទ្ធិបង្កើតជាអ្នកមានសិទ្ធិលើភាគបម្រុង ? ក្នុងករណីដែលមានការបំពានលើចំណែកមតិករបស់គាត់ធ្វើឲ្យបងប្អូនបង្កើតរបស់មតកជនគ្មានអ្វីជាមូលដ្ឋានច្បាស់លាស់ ដើម្បីការពារលើចំណែកមតិករបស់ខ្លួនប្រការនេះ ហើយដែលច្បាប់ហាក់បីដូចជាមើលរំលងករណីនេះ ហើយគ្មានវិធានការណាមួយដើម្បីការពារផលប្រយោជន៍របស់បងប្អូនបង្កើតសោះ ។

ហេតុនេះ ហើយទាក់ទងនឹងមាត្រាច្បាប់ដែលចែងអំពីអ្នកមានសិទ្ធិលើភាគបម្រុង គួរតែត្រូវធ្វើវិសោធនកម្មដោយបើកសិទ្ធិឲ្យបងប្អូនបង្កើតរបស់មតកជនអាចទាមទារនូវភាគបម្រុងរបស់ខ្លួន នៅពេលដែលមានការបំពានលើចំណែកមតិករបស់ពួកគាត់ ។

ចំពោះបញ្ហាមួយទៀតពាក់ព័ន្ធទៅនឹង ការវាយតម្លៃលើទ្រព្យសម្បត្តិ ដែលមតកជនបានបន្សល់ទុកឬ បានធ្វើប្រទានកម្មជាចលនទ្រព្យ ឬអចលនទ្រព្យ ។ ពីព្រោះដោយសារតែការវាយតម្លៃលើទ្រព្យសម្បត្តិនឹងចោទជាបញ្ហាខ្លាំង នៅពេលដែលធ្វើការគណនារកភាគបម្រុង ព្រោះភាគបម្រុងដែលត្រូវធ្វើការគណនាជាទឹកប្រាក់ ហេតុនេះហើយប្រសិនបើការវាយតម្លៃលើអចលនទ្រព្យ ឬ ចលនទ្រព្យមិនបានត្រឹមត្រូវ ឬខុសពីតម្លៃពិតនោះ វានឹងអាចធ្វើឲ្យទឹកប្រាក់នៃភាគបម្រុងមានការថយចុះ និងខាតបង់យ៉ាងខ្លាំង ។

# ឯកសារយោង

## អត្ថបទច្បាប់ ៖

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣
- ក្រមរដ្ឋប្បវេណីចាស់ឆ្នាំ ១៩៦៧
- ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧
- សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគទី ៦ គន្ថីទី៨ –ទី៩

## ឯកសារផ្សេងៗ ៖

- ➢ សាស្ត្រាចារ្យ ច្បាប់គាម ម៉ារិទ្ធីយ៉ា, ឆ្នាំ ២០១៥ *នីតិរដ្ឋប្បវេណី*
- ➢ លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ,ឆ្នាំ ២០០៥ *នីតិបេតិកភណ្ឌគ្រួសារ*
- ➢ *សន្ទានុក្រម ខ្មែរ អង់គ្លេស បារាំង នៃពាក្យច្បាប់* រដ្ឋប្បវេណី និងនីតិវិធីរដ្ឋប្បវេណី បោះពុម្ពដោយឧត្តម្ពពីឯកឧត្តម សុខ ផេង អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល ឆ្នាំ ២០០៧។
- ➢ សាស្ត្រាចារ្យ ស្រី វណ្ណធី , ឆ្នាំ ២០១១ *នីតិបេតិកភណ្ឌគ្រួសារ*
- ➢ មេធាវី ហ៊ុត គឹមឡេង, ឆ្នាំ ២០១២*នីតិបេតិកភណ្ឌគ្រួសារ*
- ➢ សាស្ត្រាចារ្យសាកលវិទ្យាល័យច្បាប់នៃសាកលវិទ្យាល័យ កិយយ៉ូ និងជាសមាជិកនៃក្រុមប្រឹក្សាវិទ្យាសាស្ត្ររបស់ប្រទេសជប៉ុន អ៊ីកិដា ម៉ាសាអ៊ូ ប្រែសម្រួលដោយ គង់ ទេលី, បោះពុម្ពឆ្នាំ២០០៦*សៀវភៅណែនាំសិក្សា ច្បាប់រដ្ឋប្បវេណី ករណីប្រទេសជប៉ុន*
- ➢ មេធាវី អ៊ីវ ប៉ូលី, ឆ្នាំ២០១០*មេរៀនសង្ខេបសន្តតិកម្ម*
- ➢ កិច្ចការស្រាវជ្រាវ ក្រុមនិស្សិត បរិញ្ញាបត្រនីតិសាស្ត្រ ជំនាន់ទី១១ ថ្នាក់ L3A4 ឆ្នាំ ២០១២ – ២០១៣ *សេចក្តីសម្រេចមាត្រានៃបទប្បញ្ញត្តិជាធរមានក្រោយប្រកាសឲ្យប្រើប្រាស់ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ឆ្នាំ ២០១១*

**ឯកសារធ្វើបទបង្ហាញ ៖**

- គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា , ២៤ តុលា ឆ្នាំ២០១៣ *សិក្ខាសាលាស្តីពីអច្ច័យទាន និងភាគបម្រុង*
- សាស្ត្រាចារ្យ បណ្ឌិត ហាប់ ផល្លី លោកស្រីសាស្ត្រាចារ្យ ប៉ូលី បញ្ញា សាស្ត្រាចារ្យ គង់ សុភ័ក្ត្រ,២៩ មិថុនា ឆ្នាំ២០១៦ *សិក្ខាសាលាស្តីពីមូលដ្ឋានគ្រឹះនៃសន្តតិកម្ម (ផ្នែក២)*

**គេហទំព័រ ៖**

https://www.youtube.com/watch? កម្មវិធីនាទីច្បាប់ ប្រធានបទ៖ ភាគបម្រុងរបស់ទូរទស្សន៍ BTV ឬតាម www.facebook// BTV Cambodia. ចូលមើលថ្ងៃទី ២២ ខែមិថុនា ឆ្នាំ ២០១៦

- Google ➞ km.rfi.fr/inheritance-in-khmer-law នាទីយល់ដឹងអំពីច្បាប់ និងជំនួញ ចូលមើលថ្ងៃទី ២២ ខែមិថុនា ឆ្នាំ ២០១៦

RULE-JICA Seminar 5

# សិក្ខាសាលាស្តីពី

# មូលដ្ឋានគ្រឹះនៃសន្តតិកម្ម (ផ្នែក២)

វាគ្មិន៖ បណ្ឌិត ហាប់ ផល្លី, លោកស្រី ប៉ូលី បញ្ញា
លោក គង់ សុភ័ក្ត្រ

កាលបរិច្ឆេទ៖ ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦

ទីកន្លែង៖ សហសាលG1, សភតវិស

1

# មាតិកា

1. សន្តតិកម្មតាមមតកសាសន៍
   1.1. គំនិតជាមូលដ្ឋាននៃសន្តតិកម្ម
   1.2. ទម្រង់នៃមតកសាសន៍
   1.3. ចំណុចនៃមតកសាសន៍
   1.4. ភាគបម្រង
   1.5. ការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រង
   1.6. ទ្រព្យជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រង
   1.7. អានុភាពនៃការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង
2. ការបោះបង់សន្តតិកម្ម និងការយល់ព្រមដោយកម្រិត
   2.1. ការបោះបង់សន្តតិកម្ម
   2.2. ការយល់ព្រមដោយមានកម្រិត

2

## 1.1. គំនិតជាមូលដ្ឋាននៃសន្តតិកម្ម

មតកជន អាចសម្រេចអំពីវិធីបែងចែកទ្រព្យសម្បត្តិ ក្រោយពេលខ្លួនមរណភាព ដោយខ្លួនឯងបាន តាមរយៈការធ្វើមតកសាសន៍។ សន្តតិជន ត្រូវតែគោរពតាមមតកសាសន៍របស់មតកជន។ ក្រមរដ្ឋប្បវេណី បញ្ញត្តនូវវិធានយ៉ាងលម្អិតអំពីទម្រង់នៃមតកសាសន៍ និង ខ្លឹមសារនៃមតកសាសន៍។

សន្តតិកម្មតាមមតកសាសន៍ មិនមែនមានន័យថា ជាសន្តតិកម្មដែលខុសគ្នាទាំងស្រុងពីសន្តតិកម្មតាមច្បាប់ទេ។ ក្នុងករណីសន្តតិកម្មតាមមតកសាសន៍ ខ្លឹមសារនៃមតកសាសន៍ មានអាទិភាពជាង ប៉ុន្តែចំណុចក្រៅពីនេះ ត្រូវអនុវត្តតាមវិធានសន្តតិកម្មតាមច្បាប់។

3

## 1.2. ទម្រង់នៃមតកសាសន៍ (1)

មតកសាសន៍ មានអានុភាពក្រោយពេលមតកជនទទួលមរណភាព។ នៅពេលមតកជនបានទទួលមរណភាព ប្រសិនបើខ្លឹមសារមតកសាសន៍មិនមានភាពច្បាស់លាស់ ហើយទោះបីជាមានបញ្ហានៅត្រង់ថា មតកសាសន៍ពិតជាស្របតាមឆន្ទៈរបស់មតកជនមែន ឬយ៉ាងណានោះ មិនអាចសួរទៅកាន់មតកជនបានទេ។ ហេតុនេះ នៅក្នុងក្រមរដ្ឋប្បវេណី បញ្ញត្តនូវវិធានយ៉ាងតឹងរ៉ឹងអំពីទម្រង់នៃមតកសាសន៍ ដើម្បីកុំឲ្យមានបញ្ហាកើតឡើងក្រោយពេលមតកជនទទួលមរណភាព (មាត្រា១១៧០-១១៨១) ។

4

## 1.2. ទម្រង់នៃមតកសាសន៍ (2)

- មតកសាសន៍ដោយលិខិតយថាភូត (មាត្រា១១៧៣)
- មតកសាសន៍ដោយលិខិតឯកជន (មាត្រា១១៧៤)
- មតកសាសន៍ដោយលិខិតសម្ងាត់ (មាត្រា១១៧៥)
- មតកសាសន៍នៃជននៅក្រោមអាណាព្យាបាលទូទៅ (មាត្រា១១៧៦)
- មតកសាសន៍របស់ជនដែលកំពុងជួបប្រទះគ្រោះថ្នាក់បន្ទាន់ដល់អាយុជីវិត (មាត្រា១១៧៧)
- មតកសាសន៍នៃជនដែលត្រូវជាប់ឃុំឃាំង (មាត្រា១១៧៨)

5

## 1.3. ចំណុចនៃមតកសាសន៍

ខ្លឹមសារដែលអាចបង្កើតមតកសាសន៍បានមានដូចខាងក្រោម៖

- ការកំណត់ចំណែកមត៌ក (មាត្រា១១៨២)
- ការកំណត់នូវវិធីបែងចែកដោយមតកសាសន៍ (មាត្រា១១៨៣)
- អច្ច័យទាន (មាត្រា១១៩៩)

6

## 1.3.1. ការកំណត់ចំណែកមត៌ក (មាត្រា១១៨២)

ការកំណត់ចំណែកមត៌ក គឺជាការផ្លាស់ប្តូរភាគនៃចំណែកសន្តតិកម្មតាមច្បាប់។




មតកសាសន៍

មត៌កពាក់កណ្តាលឲ្យទៅកូន A

7

## 1.3.2. ការកំណត់នូវវិធីបែងចែកមត៌ក (មាត្រា១១៨៣)

ជាការសម្រេចថា ត្រូវផ្តល់ប្រភេទទ្រព្យសម្បត្តិបែបណាទៅឲ្យសន្តតិជនមួយណា។




មតកសាសន៍

ឲ្យផ្ទះទៅកូន A។ ឲ្យរថយន្ត និងសាច់ប្រាក់ចំនួន ៤០០០ ដុល្លារទៅកូន B។ ឲ្យសាច់ប្រាក់ចំនួន៥០០០ ដុល្លារទៅកូន C។

8

## ការកំណត់ចំណែកមត៌ក និងការកំណត់នូវវិធីបែងចែកមត៌ក

អាចធ្វើឡើងក្នុងពេលព្រមគ្នាបាន។




9

## 1.3.3. អច្ច័យទាន

អច្ច័យទាន គឺជាការធ្វើប្រទានកម្មទ្រព្យសម្បត្តិតាមរយៈមតកសាសន៍របស់មតជន។ ការកំណត់ចំណែកមត៌ក និងការកំណត់វិធីបែងចែកចំណែកមត៌ក ជាកម្មវត្ថុចំពោះតែសន្តតិជនប៉ុណ្ណោះ ប៉ុន្តែ អច្ច័យទានអាចជាកម្មវត្ថុចំពោះតតិយជន ក្រៅពីសន្តតិជនបាន។ អច្ច័យទានមានអច្ច័យទានសកល និងអច្ច័យទានមានកំណត់ (មាត្រា១១៩៩)។

10

## 1.3.3. អច្ច័យទាន

អច្ច័យទានសកល គឺជាការធ្វើប្រទានកម្មនូវទ្រព្យសម្បត្តិទាំងអស់ ឬមួយផ្នែកដែលកំណត់ទៅតាមភាគ (មាត្រា១១៩៩)។

អច្ច័យលាភីសកល មានសិទ្ធិ និងករណីកិច្ច ដូចគ្នានឹងសន្តតិជន (មាត្រា១២១២(១))។

11

## អច្ច័យទានសកល (មាត្រា១១៩៩)




12

# អច្ច័យទានសកល (មាត្រា១១៩៩)




កូន A និង B ត្រូវបាត់ទុកថា មិនបានទទួលសន្តតិកម្ម (មាត្រា ១២១២(២))។

※ ស្តីអំពីភាគបម្រុង យើងនឹងធ្វើការពន្យល់តាមក្រោយ ។

ផ្ទះតម្លៃ ៥០០០ ដុល្លារ
រថយន្តតម្លៃ ១០០០ ដុល្លារ
សាច់ប្រាក់ចំនួន ១០០០០ ដុល្លារ

13

# អច្ច័យទានមានកំណត់

ការប្រទានកម្មដែលកំណត់ទ្រព្យសម្បត្តិជាក់លាក់ ទៅឱ្យមនុស្សម្នាក់ ឬច្រើននាក់ ដោយមតកជន។




14

## 4.1. ភាគបម្រុង

ដូចដែលបានរៀបរាប់ពីខាងលើមកដល់ត្រឹមចំណុចនេះ មតកជនអាចសម្រេចចិត្តដោយខ្លួនឯងអំពីវិធីនៃការបែងចែកទ្រព្យសម្បត្តិក្រោយពីទទួលមរណភាព តាមរយៈការធ្វើមតកសាសន៍បាន។ ប៉ុន្តែ ដោយសារតែអ្នកដែលត្រូវបានបញ្ញត្តទុកថា អាចទទួលទ្រព្យសម្បត្តិរបស់មតកជនដោយសន្តតិកម្ម (អ្នកដែលត្រូវបានសន្មតថាជាសន្តតិជន) មានដូចជា សហព័ទ្ធ និងកូនរបស់មតកជនជាដើម រំពឹងទុកចំពោះការធ្វើសន្តតិកម្ម ហេតុនេះចាំបាច់ត្រូវតែមានការការពារលើការរំពឹងទុកបែបនោះ។ ដូច្នេះ នៅក្នុងក្រមរដ្ឋប្បវេណីបញ្ញត្តអំពីប្រព័ន្ធមួយដែលហៅថា ភាគបម្រុង។ នៅក្នុងចំណោមបំណែកមតិករបស់សន្តតិជន ភាគបម្រុង គឺជាផ្នែកមួយដែលមិនអាចធ្វើការបំពានដោយមតកសាសន៍ជាអាទិ៍បានឡើយ។

15

## អ្នកមានសិទ្ធិលើភាគបម្រុង (មាត្រា១២៣០)

អ្នកមានសិទ្ធិលើភាគបម្រុង គឺបច្ឆាញាតិផ្ទាល់ ឬឪពុកម្តាយ ឬជីដូនជីតា និងសហព័ទ្ធរបស់មតកជន។ មានន័យថា អ្នកដែលត្រូវបានកំណត់ទុកថានឹងក្លាយជាសន្តតិជនផ្អែកតាមបញ្ញត្តិនៃបំណែកមតិកដែលច្បាប់បានកំណត់ នឹងក្លាយជាអ្នកមានសិទ្ធិលើភាគបម្រុង។ ប៉ុន្តែ បងប្អូនបង្កើតមិនអាចក្លាយជាអ្នកមានសិទ្ធិលើភាគបម្រុងបានទេ ទោះបីជាត្រូវបានកំណត់ទុកថានឹងក្លាយជាសន្តតិជនក៏ដោយ។

16




# ភាគនៃភាគបម្រុង (មាត្រា១២៣០)

១ភាគ៣ នៃទ្រព្យរបស់មតកជន ក្នុងករណីដែលមានតែសន្តតិជនជាឪពុកម្ដាយ ឬជីដូន ជីតាប៉ុណ្ណោះ (មាត្រា១២៣០(១) ចំណុច ក)។




18

# ភាគនៃភាគបម្រុង (មាត្រា១២៣០)

ក្រៅពីករណីនេះ ភាគបម្រុង គឺ១ភាគ២ នៃទ្រព្យសម្បត្តិរបស់មតកជន។




មតកសាសន៍
ឲ្យទ្រព្យសម្បត្តិទាំងអស់ទៅមិត្តភក្តិ D

ភាគបម្រុងសរុបរបស់សន្តតិជន
១២០០០ ÷ ២ = ៦០០០
ដូច្នេះ ត្រូវបែងចែកជា៣ចំណែកមានដូចជា ប្រពន្ធ A, កូន B និងកូន C។

19

# ភាគនៃភាគបម្រុង (មាត្រា១២៣០)

ក្រៅពីករណីនេះ ភាគបម្រុង គឺ១ភាគ២ នៃទ្រព្យសម្បត្តិរបស់មតកជន។




មតកសាសន៍
ឲ្យទ្រព្យសម្បត្តិទាំងអស់ទៅកូន B

ភាគបម្រុងសរុបរបស់សន្តតិជន
១២០០០ ÷ ២ = ៦០០០
ដូច្នេះ ត្រូវបែងចែកជា ៣ ចំណែកមានដូចជា ប្រពន្ធ A, កូន B និង កូន C។

20

## 4.3.1. ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង

ទ្រព្យដែលជាមូលដ្ឋាននៅពេលគណនាភាគបម្រុង មិនមែនមានត្រឹមតែមតិកតែប៉ុណ្ណោះទេ។ ភាគបម្រុងត្រូវគណនាដោយយក តម្លៃនៃមតិកដែលមតកជនមាននៅពេលទទួលមរណភាព បូកតម្លៃនៃផលប្រយោជន៍ពិសេស និង តម្លៃទ្រព្យសម្បត្តិប្រទានកម្មដែលបានកំណត់ក្នុងអំឡុងពេលនៅរស់ ហើយដកនូវចំនួនប្រាក់សរុបនៃកាតព្វកិច្ច (មាត្រា១២៣១)។

តម្លៃទ្រព្យប្រទានកម្មដែលបានកំណត់ក្នុងអំឡុងពេលនៅរស់ មានដូចខាងក្រោម (មាត្រា១២៣២(១))៖

- ប្រទានកម្មដែលបានធ្វើក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ នៅមុនពេលចាប់ផ្តើមសន្តតិកម្ម។
- ក្រៅពីប្រទានកម្មនេះ ប្រទានកម្មដែលត្រូវបានធ្វើឡើង ដោយភាគីទាំងសងខាងបានដឹងថា នឹងបណ្តាលឲ្យខូចខាតដល់អ្នកមានសិទ្ធិលើភាគបម្រុង។

21

## 4.3.1. ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង




ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង
៣០០០០+១២០០០−៦០០០=៣៦០០០

22

## 4.3.1. ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង




ភាគបម្រុងរបស់សន្តតិជនទាំងអស់
៣៦០០០÷២=១៨០០០

23

## 4.3.1. ទ្រព្យដែលជាមូលដ្ឋានក្នុងការគណនាភាគបម្រុង




ភាគបម្រុងរបស់សន្តតិជន១នាក់
១៨០០០÷២=៩០០០

24

## 4.3.2. វិធីគណនានៃចំនួនដែលបំពានភាគបម្រុង

ចំនួនដែលបំពានភាគបម្រុង គឺត្រូវគណនាដោយយក ភាគបម្រុងរបស់បុគ្គលនោះ ដកចំនួនសរុបនៃទ្រព្យសម្បត្តិដែល បុគ្គលនោះទទួលបានដោយសន្តតិកម្ម និងផលប្រយោជន៍ពិសេស ហើយ បូកបញ្ចូលនូវចំនួនទឹកប្រាក់នៃកាតព្វកិច្ចដែល បុគ្គលនោះត្រូវទទួលបន្ទុកដោយសន្តតិកម្ម (មាត្រា១២៣៤)។

25

## 4.3.2. វិធីគណនានៃចំនួនដែលបំពានភាគបម្រុង




26

## 1.5. ការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

ឧទាហរណ៍៖ ទោះបីជាអ្នកមានសិទ្ធិលើភាគបម្រុងក៏ដោយ ក៏មិនមែនមានន័យថាទ្រព្យសម្បត្តិនឹងត្រូវបានបែកទៅឲ្យបុគ្គលនោះដោយស្វ័យប្រវត្តិនោះដែរ។ ក្នុងករណី មតកសាសន៍ដែលធ្វើឲ្យបំពានភាគបម្រុងរបស់បុគ្គលណាម្នាក់ត្រូវបានកើតឡើង អ្នកមានសិទ្ធិលើភាគបម្រុងត្រូវតែអនុវត្តការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង (មាត្រា១២៤៥)។

សិទ្ធិទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ១ ឆ្នាំបានកន្លងហួស គិតចាប់ពីពេលដែលអ្នកមានសិទ្ធិលើភាគបម្រុងបានដឹងថា ភាគបម្រុងរបស់ខ្លួនត្រូវបានបំពានដោយអច្ច័យទានជាដើម។ ម៉្យាងវិញទៀត សិទ្ធិទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង ក៏ត្រូវរលត់ដោយអាជ្ញាយុកាល បើអំឡុងពេល ៥ឆ្នាំ បានកន្លងហួសគិតចាប់ពីពេលចាប់ផ្តើមសន្តតិកម្ម (មាត្រា១២៤៥)។

27

## 1.6. ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង គឺអច្ច័យទាន ការកំណត់ចំណែកមត៌កតាមមតកសាសន៍ ការទទួលផលប្រយោជន៍ពិសេស និងប្រទានកម្មជាក់លាក់ក្នុងអំឡុងពេលនៅរស់ដែលបានកំណត់នៅក្នុងមាត្រា១២៣២នៃក្រមរដ្ឋប្បវេណី (មាត្រា១២៣៣)។

ករណី ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុងមានច្រើន លំដាប់អាទិភាពនៃការកាត់បន្ថយ មានដូចខាងក្រោម (មាត្រា១២៣៦-១២៣៨)៖

លំដាប់ទី១ អច្ច័យទាន និងចំណែកមត៌កដែលបានកំណត់ចំពោះសន្តតិជន។

លំដាប់ទី២ អច្ច័យទានដែលត្រូវបានធ្វើចំពោះបុគ្គលផ្សេងក្រៅពីសន្តតិជន។

លំដាប់ទី៣ ប្រទានកម្ម ឬផលប្រយោជន៍ពិសេស។ ចំពោះប្រទានកម្ម ឬផលប្រយោជន៍ពិសេសគឺជាវត្ថុថ្មី មានន័យថា ជាវត្ថុដែលត្រូវបានកើតឡើងតាមក្រោយដូច្នេះវានឹងមានអាទិភាពជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង។

28

## 1.6. ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង




គណនាភាគបម្រុងរបស់កូន B

ភាគបម្រុងរួម៖ ១៨០០០+១៥០០០+៧០០០=៤០០០០

ភាគបម្រុងសម្រាប់សន្តតិជនម្នាក់ៗ៖ ៤០០០០÷២÷២=១០០០០

ដូចនេះ ភាគបម្រុងរបស់កូន B មានចំនួន១០០០០ដុល្លារ

29

## 1.6. ទ្រព្យសម្បត្តិដែលជាកម្មវត្ថុនៃការកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង




ចំនួនដែលបំពានភាគបម្រុងរបស់កូន B = ១០០០០−១០០០ = ៩០០០ដុល្លារ

30

## ការកាត់បន្ថយភាគបម្រុងតាមលំដាប់អាទិភាព




**លំដាប់នៃការកាត់បន្ថយភាគបម្រុង**

ទី១៖ អច្ច័យទានទៅកូនត្រឹមផ្នែកដែលលើសភាគបម្រុងរបស់កូន A៖ 14,000 – 10,000 = $4,000

ទី២៖ អច្ច័យទានទៅ មិត្តភក្តិ C ចំនួន $3,000 = $3,000

ទី៣៖ ប្រទានកម្មនៃវត្ថុបីក្នុងអំឡុងពេលនៅរស់ឲ្យកូន A ចំនួន $7,000 = $2,000

31

## 1.7. អានុភាពនៃការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង

នៅពេលដែលមានការទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង អច្ច័យទាន និងចំណែកមត៌កដែលបានកំណត់ជាដើម នឹងបាត់បង់អានុភាពភ្លាមត្រឹមកម្រិតបំពានភាគបម្រុង ហើយសិទ្ធិនៃផ្នែកទាំងនោះ គឺជារបស់អ្នកដែលបានទាមទារឲ្យកាត់បន្ថយដើម្បីបង្គ្រប់ភាគបម្រុង។

32

## 2. ការបោះបង់សន្តតិកម្ម និងការយល់ព្រមដោយមានកម្រិត
### 2.1. ការបោះបង់សន្តតិកម្ម

សន្តតិជនអាចបោះបង់សន្តតិកម្មបាន (មាត្រា១២៦០)។ បុគ្គលដែលបានបោះបង់សន្តតិកម្ម ត្រូវចាត់ទុកថា បុគ្គលនោះមិនមែនជាសន្តតិជនតាំងពីដំបូងមក (មាត្រា១២៦១)។

ឧទាហរណ៍៖ ករណី មតកជន x មានកាតព្វកិច្ចច្រើន នៅពេលទទួលសន្តតិកម្ម សន្តតិជននឹងទទួលការខូចខាត។ ហេតុនេះ សន្តតិជនអាចបោះបង់សន្តតិកម្មនោះបាន។

គោលគំនិតនៃមាត្រាទាំងពីរខាងលើ គឺ៖

- ការពារផលប្រយោជន៍សន្តតិជន
- គោរពឆន្ទៈរបស់សន្តតិជន។

33

### 2.2. ការយល់ព្រមដោយមានកម្រិត

សន្តតិជនអាចយល់ព្រម ដោយបម្រុងទុកនូវសំណង កាតព្វកិច្ច និង អច្ច័យទានរបស់មតកជន ត្រឹមកម្រិតនៃទ្រព្យសម្បត្តិដែលខ្លួនបានទទួលតាមរយៈសន្តតិកម្មតែប៉ុណ្ណោះ (មាត្រា១២៥៦)។ ករណីនេះហៅថា ការយល់ព្រមដោយមានកម្រិត។

34

## 2.2. ការយល់ព្រមដោយមានកម្រិត




មាន ដី, រថយន្ត, ត្បូង និងសាច់ប្រាក់ជាដើមច្រើន។

ប្រសិនបើ មតិកដែលបានប្រើប្រាស់ក្រោយពីសងបំណុល មានមតិកនៅសល់ សន្តតិជនប្រាកដជាចង់ធ្វើសន្តតិកម្ម។ ទោះបីជាបំណុលច្រើនជាងមតិក ក៏ដោយក៏ សន្តតិជន មិនចង់សងបំណុលដោយប្រើប្រាស់ប្រាក់របស់ខ្លួនទេ។

→ នៅក្នុងករណីបែបនេះ គឺអាចយល់ព្រមដោយមានកម្រិតបាន។

35

## 2.2. ការយល់ព្រមដោយមានកម្រិត




នៅពេលដែលធ្វើការយល់ព្រមដោយមានកម្រិត ជាដំបូងត្រូវប្រើប្រាស់មតិករបស់មតកជន មកសងកាតព្វកិច្ចសិន។ បន្ទាប់មក ប្រសិនបើ មានមតិកនៅសល់ សន្តតិជន អាចធ្វើការបែងចែកមតិកទាំងនោះ ហើយអាចធ្វើលទ្ធកម្មបាន។

36

## 2.2. ការយល់ព្រមដោយមានកម្រិត




ប្រសិនបើ មតិកដែលបានប្រើប្រាស់ក្រោយពីសងកាតព្វកិច្ច ទោះបីជាកាតព្វកិច្ចនៅសល់ក៏ដោយ ក៏សន្តតិជនមិនចាំបាច់សងកាតព្វកិច្ចនោះដែរ។

37

# សូមអរគុណ!!!

# Q & A

## ឯកសារពិគ្រោះ

ក្រមរដ្ឋប្បវេណីកម្ពុជាឆ្នាំ២០០៧។

សេចក្តីកំណត់ចំពោះមាត្រានីមួយៗនៃឆ្នាំ២០០៩។

38